សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# គោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់របស់អយ្យការ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **មង្គ្លឹម សុនណារូ**
កញ្ញា **ហាន ផនម៉ារីសា**

សាស្ត្រាចារ្យណែនាំ
លោក **ជួន ប៊ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

**សារណាបញ្ចប់ការសិក្សា**

# គោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់របស់អយ្យការ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **មជ្ឈឹម សុនណារូ**

កញ្ញា **ហាន ផនម៉ារីសា**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ប៊ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **មជ្ឈឹម សុនណារុ** និងនាងខ្ញុំឈ្មោះ **ហាន ផនម៉ារីសា** ជានិស្សិតផ្នែកនីតិសាស្ត្រនៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំសិក្សា ២០១៧-២០២១ ជំនាន់ទី ២១។

ជាដំបូងយើងខ្ញុំទាំងពីរសូមសម្តែងនូវកតញ្ញូ និងដឹងគុណដ៏ជ្រាលជ្រៅដែលមិនអាចកាត់ថ្លៃបាន ចំពោះលោកអ្នកមានគុណទាំងបួនពោលគឺ លោកឪពុក **ខួន សុនមជ្ឈឹម** និងអ្នកម្តាយ **ចឲ្យ សុខា** និងលោកឪពុក **ឈឹម ចាន់ណា** និងអ្នកម្តាយ **ជា លក្ខិណា** ដែលបានផ្តល់កំណើតដល់រូបយើងខ្ញុំ និងបានចិញ្ចឹមបីបាច់ ថែរក្សា ផ្គត់ផ្គង់ អប់រំទូន្មាន ប្រៀនប្រដៅ ផ្តល់ដំបូន្មានល្អៗ ព្រមទាំងផ្តល់កម្លាំងចិត្ត និងកម្លាំងកាយដោយមិនគិតពីការនឿយហត់របស់លោកឡើយ តាំងពីយើងខ្ញុំនូវកុមារភាព រហូតដល់បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រប្រកបដោយជោគជ័យ។ ពិសេសជាងនេះនាងខ្ញុំ **ហាន ផនម៉ារីសា** សូមធ្វើការអរគុណជាអនេកចំពោះលោកតា **លៀង ផន** និងលោកយាយ **ឈឹម ណារី** ដែលលោកទាំងពីរបានមើលថែទាំ និងផ្គត់ផ្គង់ដល់នាងខ្ញុំតាំងតែពីតូច រហូតដល់នាងខ្ញុំបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះបានយ៉ាងរលូន។ យើងខ្ញុំសូមធ្វើការគោរពដឹងគុណជាទីបំផុត និងពុំអាចកាត់ថ្លៃបានឡើយរាល់សកម្មភាពដែលលោកអ្នកមានគុណទាំងអស់មានចំពោះយើងខ្ញុំទាំងពីរ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ **ក្រសួងអប់រំ យុវជន និងកីឡា** រួមទាំង **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** បានផ្តល់នូវកន្លែងបណ្តុះបណ្តាលចំណេះដឹង សមត្ថភាពការស្រាវជ្រាវ ក្នុងផ្នែកនីតិសាស្ត្រ ចាប់តាំងពីឆ្នាំទីមួយរហូតមកដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រប្រកបដោយភាពជោគជ័យ និងសមទ្ធិផលចំណេះដឹងយ៉ាងគាប់ប្រសើរ។

យើងខ្ញុំទាំងពីររូបសូមថ្លែងអំណរគុណដល់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង និងលោក លោកស្រី សាស្ត្រាចារ្យ** ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានធ្វើការយកចិត្តទុកដាក់ ក្នុងការអប់រំ ផ្តល់ចំណេះដឹង និងសីលធម៌ដល់យើងខ្ញុំទាំងពីររូបអស់រយៈពេលបួនឆ្នាំកន្លងមកនេះ ក៏ដូចជាជួយសម្របសម្រួលក្នុងការស្រាវជ្រាវ ឯកសារនានា។

ជាពិសេស យើងខ្ញុំទាំងពីររូបសូមថ្លែងអំណរគុណដល់ លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យណែនាំ បានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ ពន្យល់ ពិនិត្យ អប់រំ និងកែតម្រូវនូវចំណុចខ្វះខាតនៃសារណានេះ តាំងពីពេលចាប់ផ្តើមសរសេរសារណាបញ្ចប់ការសិក្សានេះ រហូតដល់ពួកយើងទទួលបានលទ្ធផលស្កាពរ។ លោកសាស្ត្រាចារ្យ បានខិតខំទាំងកម្លាំងកាយ កម្លាំងចិត្ត និងយកចិត្តទុកដាក់ក្នុងការតម្រង់ទិស

ផ្តល់អនុសាសន៍ល្អៗ ក៏ដូចជាផ្តល់ឯកសារពាក់ព័ន្ធនានា ដល់ពួកយើងទាំងពីររូបក្នុងការតាក់តែងសារណាមួយនេះឡើង។

ព្រមទាំងថ្លែងអំណរគុណចំពោះ លោកសាស្ត្រាចារ្យ **ឯកឧត្តម ហ៊ី សោភា** ដែលបានចែករំលែកនូវចំណេះដឹងលើក្រមទាំងបួន រួមមាន ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងការផ្តល់ដំបូន្មានល្អៗក្នុងការអប់រំ  រួមទាំងផ្តល់នូវបទពិសោធន៍ជាច្រើនក្នុងវិស័យច្បាប់  យើងខ្ញុំនឹងចងចាំជានិច្ចនូវគុណបំណាច់ដ៏ធំនេះ។

ជាចុងក្រោយ យើងខ្ញុំទាំងពីររូបសូមប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ និងបួងសួងដល់វត្ថុស័ក្តសិទ្ធិក្នុងលោកយើងនេះ  មេត្តាតាមថែរក្សាដល់អ្នកមានគុណទាំងបួន លោកតា លោកយាយ ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង និងលោក លោកស្រី សាស្ត្រាចារ្យ រួមទាំងសិស្សច្បង ជាពិសេស លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ព្រមទាំងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

## អារម្ភកថា

ជាបឋម ខ្ញុំបាទ **មជ្ឈឹម សុនណារ៉ូ** និង នាងខ្ញុំ **ហាន ផនម៉ារីសា** សូមធ្វើការស្វាគមន៍ចំពោះប្រិយមិត្តអ្នកអានគ្រប់រូប ជាពិសេសសិស្ស និស្សិតជាទីរាប់អាន និងសាស្រ្តាចារ្យជាទីគោរព។ ក្រោយពីបានឆ្លងកាត់ការសិក្សានិងក្រេបជញ្ជក់ចំណេះដឹងចាប់តាំងពីឆ្នាំទីមួយរហូតដល់បញ្ចប់ការសិក្សានៅ "**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច**" ពួកយើងពិតជាមានកិត្តិយសដ៏ក្រៃលែង ដែលសាកលវិទ្យាល័យ បានផ្តល់នូវឱកាសដល់រូបយើងខ្ញុំ ក្នុងការតាក់តែងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្តនេះ។ ក្នុងរយៈពេលបួនឆ្នាំនេះ យើងខ្ញុំបានសិក្សាជាច្រើនមុខ ក្នុងនោះមុខវិជ្ជាដែលយើងខ្ញុំយកមកតាក់តែងសារណានោះគឺ មុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ។ ដូចនេះ យើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទសារណាមួយស្តីពី "**គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់របស់អយ្យការ**"។ ការជ្រើសរើសនេះ យើងបានឆ្លងកាត់នូវការពិភាក្សា ពិគ្រោះ និងផ្តល់យោបល់ពីសំណាក់ លោកសាស្រ្តាចារ្យយ៉ាងហ្មត់ចត់ និងយល់ឃើញថាគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់នេះ ពិតជាមានប្រយោជន៍ និងសារៈសំខាន់ណាស់ ព្រោះការអនុវត្តនៅក្នុងនីតិវិធីនៃរឿងក្តីព្រហ្មទណ្ឌ សុទ្ធសឹងពាក់ព័ន្ធនឹងការចោទប្រកាន់ ឬការតម្កល់រឿងទុកឥតចាត់ការ ដែលទាមទារឲ្យមានចំណេះដឹង និង ភាពច្បាស់លាស់លើ ការអនុវត្ត លក្ខខណ្ឌ នីតិវិធី ទម្រង់ការ។ល។

យើងខ្ញុំពិតជាមានមោទនភាពយ៉ាងខ្លាំង ដែលបានតាក់តែងសារណាក្រោមប្រធានបទស្តីពី "**គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់របស់អយ្យការ**" ដែលមានលោកសាស្រ្តាចារ្យណែនាំ **ជួន ម៉ុនធី** ដែលផ្តល់ជាជំនួយដល់យើងខ្ញុំទាំងពីររូបក្នុងការតាក់តែងសារណានេះយ៉ាងរលូន ទាំងការផ្តល់យោបល់ណែនាំ និងផ្តល់ឯកសារពាក់ព័ន្ធ។ យើងខ្ញុំទាំងពីររូប សង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា សារណាមួយនេះ នឹងក្លាយជាឯកសារចម្បងក្នុងការស្រាវជ្រាវដល់សិស្ស និស្សិតជំនាន់ក្រោយៗ ដើម្បីជាជំនួយផ្នែកស្មារតី និងចំណេះដឹង។ ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ យើងខ្ញុំទាំងពីររូបប្តេជ្ញាថានឹងប្រើប្រាស់នូវចំណេះដឹងនេះឱ្យបានជាប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍ដល់សង្គមជាតិនាពេលអនាគត។

ទោះជាបីជាមានការខិតខំស្រាវជ្រាវ ការត្រួតពិនិត្យ និងការកែតម្រូវយ៉ាងណា ក៏សារណានេះនៅតែមានចំណុចដែលខ្វះខាតផ្នែកខ្លឹមសារ និងកំហុសខុសឆ្គងផ្នែកខាងអក្ខរាវិរុទ្ធជាក់ជាមិនខាន។ ដូច្នេះយើងខ្ញុំទាំងពីររូប ធ្វើការលំអោនកាយសូមការអធ្យាស្រ័យ និងសូមអភ័យទោស ចំពោះកំហុសខុសឆ្គងទាំងឡាយ ពីសំណាក់លោក លោកស្រី សាស្រ្តាចារ្យ និងសិស្ស និស្សិតអ្នកអានគ្រប់មជ្ឈដ្ឋាន។ យើងខ្ញុំទាំងពីររូបរងចាំទទួលនូវការរិះគន់ និងកែតម្រូវ ក្នុងន័យស្ថាបនា ដើម្បីឱ្យសមិទ្ធិផលមួយនេះ កាន់តែប្រសើរឡើង និងសូមគោរពអរគុណចំពោះការរិះគន់។

ជាទីបញ្ចប់នេះ សូមជូនពរដល់ អស់លោក លោកស្រី សាស្ត្រាចារ្យ និងសិស្ស និស្សិត មិត្តអ្នកអានគ្រប់រូបឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ និងជៀសឆ្ងាយផុតពីជំងឺកាចសាហាវទាំងពួង។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** ........ ១

**ជំពូកទី១៖ សញ្ញាណទូទៅ**

**ផ្នែកទី១៖ អំពីអង្គការអយ្យការ** ........ ៣

**ផ្នែកទី២៖ អង្គការអយ្យការ** ........ ៤

កថាខណ្ឌទី១៖ សមាសភាពក្នុងអង្គការអយ្យការ ........ ៤

១. ព្រះរាជអាជ្ញា ........ ៤

២. ព្រះរាជអាជ្ញារង ........ ៤

៣. ក្រឡាបញ្ជី ........ ៤

កថាខណ្ឌទី២៖ សមត្ថកិច្ច តួនាទី ភារកិច្ច សិទ្ធិអំណាចរបស់តំណាងអង្គការអយ្យការ ........ ៥

១. សមត្ថកិច្ចរបស់តំណាងអយ្យការ ........ ៥

២. តួនាទីរបស់តំណាងអយ្យការ ........ ៥

៣. ភារកិច្ចរបស់តំណាងអយ្យការ ........ ៦

៤. អំណាចរបស់តំណាងអយ្យការ ........ ៦

**ផ្នែកទី៣៖ គោលការណ៍របស់អង្គការអយ្យការ** ........ ៧

កថាខណ្ឌទី១៖ គោលការណ៍ឯកភាព ........ ៧

កថាខណ្ឌទី២៖ គោលការណ៍អវិភាគ ........ ៧

កថាខណ្ឌទី៣៖ គោលការណ៍ឯករាជ្យ ........ ៨

កថាខណ្ឌទី៤៖ គោលការណ៍មិនអាចប្ដឹងជំទាស់ ........ ៨

កថាខណ្ឌទី៥៖ គោលការណ៍មិនទទួលខុសត្រូវ ........ ៩

**ជំពូកទី២៖ ការលានុវត្តភាពនៃការចោទប្រកាន់**

**ផ្នែកទី១៖ ការបើកការស៊ើបសួរ** ........ ១០

កថាខណ្ឌទី១៖ លក្ខខណ្ឌនៃការបើកការស៊ើបសួរ ........ ១១
១. ការបើកការស៊ើបសួរករណីបទឧក្រិដ្ឋ ........ ១១
២. ការបើកការស៊ើបសួរករណីបទមជ្ឈិម ........ ១២
កថាខណ្ឌទី២៖ នីតិវិធីនៃការបើកការស៊ើបសួរ ........ ១៣
១. ការបើកការស៊ើបសួរតាមរយៈពាក្យបណ្តឹងបញ្ជូនមកដោយផ្ទាល់ ឬបណ្តឹងសាមញ្ញ ........ ១៣
២. ការបើកការស៊ើបសួរចំពោះពាក្យបណ្តឹងដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ........ ១៤
២.១ ការបញ្ជូនបណ្តឹងទៅកាន់ព្រះរាជអាជ្ញា ........ ១៥
២.២ ការបង់ប្រាក់តម្កល់ទុក ........ ១៦
២.៣ ទណ្ឌកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ........ ១៧
៣. ទម្រង់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ........ ១៧
៤. អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ........ ១៨
៤.១ ការផុតរលត់អាជ្ញាយុកាលនៃបទល្មើស ........ ១៨
៤.២ ការកំណត់ពីវិសាលភាពនាំការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ........ ១៩
កថាខណ្ឌទី៣៖ ការបិទការស៊ើបសួរ ........ ២០
**ផ្នែកទី២៖ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់** ........ ២១
កថាខណ្ឌទី១៖ លក្ខខណ្ឌនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ២២
១. ប្រភេទនៃបទល្មើស ........ ២២
១.១ ចំពោះបទល្មើសជាបទលហុ ........ ២២
១.២ ចំពោះបទល្មើសជាបទមជ្ឈិម ........ ២៣
២. សារតារបស់ជនល្មើស ........ ២៣
កថាខណ្ឌទី២៖ នីតិវិធីនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ២៣
១. ថិរវេលានៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ២៤
២. របៀបនៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ២៥

កថាខណ្ឌទី៣៖ ទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ២៦
កថាខណ្ឌទី៤៖ អានុភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់........ ២៧
១. ការផុតរលត់អាជ្ញាយុកាលនៃបទល្មើស........ ២៧
២. វិសាលភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់........ ២៨
**ផ្នែកទី៣៖ ការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម** ........ ២៨
កថាខណ្ឌទី១៖ លក្ខខណ្ឌនៃនីតិវិធីបង្ហាញខ្លួនភ្លាម........ ២៨
កថាខណ្ឌទី២៖ នីតិវិធីនៃការបង្ហាញខ្លួនភ្លាម........ ៣០
១. ការបង្ហាញខ្លួនភ្លាមធ្វើនៅចំពោះមុខព្រះរាជអាជ្ញា........ ៣០
២. ការបង្ហាញខ្លួនភ្លាមធ្វើនៅចំពោះមុខតុលាការជំនុំជម្រះ........ ៣១
កថាខណ្ឌទី៣៖ អានុភាពនៃការបង្ហាញខ្លួនភ្លាម ........ ៣២
**ជំពូកទី៣៖ ការតម្កល់រឿងទុកឥតចាត់ការ**
**ផ្នែកទី១៖ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ**........ ៣៣
កថាខណ្ឌទី១៖ ការរលត់បណ្តឹងអាជ្ញា ........ ៣៣
កថាខណ្ឌទី២៖ នត្ថិភាពនៃបទល្មើស ........ ៣៨
កថាខណ្ឌទី៣៖ មូលហេតុគតិយុត្តិផ្សេងទៀត........ ៣៩
កថាខណ្ឌទី៤៖ ការចោទប្រកាន់មិនផ្តល់ប្រយោជន៍ ........ ៤២
**ផ្នែកទី២៖ នីតិវិធី ទម្រង់ការ និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ**........ ៤៣
កថាខណ្ឌទី១៖ នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ........ ៤៣
កថាខណ្ឌទី២៖ ទម្រង់នៃការតម្កល់រឿងទុកឥតចាត់ការ ........ ៤៣
កថាខណ្ឌទី៣៖ អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ ........ ៤៤
**ផ្នែកទី៣៖ យន្តការជម្រុញឱ្យមានការចោទប្រកាន់ឡើងវិញ**........ ៤៥
កថាខណ្ឌទី១៖ ការកែប្រែសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា........ ៤៥
កថាខណ្ឌទី២៖ ការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍........ ៤៦

កថាខណ្ឌទី៣៖ អំណាចអធិបញ្ញាដោយនាយឋានានុក្រមនៃអង្គការអយ្យការ ........................................ ៤៧

កថាខណ្ឌទី៤៖ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ .............................. ៤៨

**សេចក្តីសន្និដ្ឋាន** ........................................................................................................................ ៥០

**អនុសាសន៍** ................................................................................................................................ ៥២

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

ដើម្បីគ្រប់គ្រងប្រទេសជាតិមួយ ឱ្យប្រកបទៅដោយសន្តិសុខ សណ្ដាប់ធ្នាប់ សុវត្ថិភាព តម្លាភាព និងយុត្តិធម៌ទៅបាន លុះត្រាតែប្រទេសមួយនោះមានវិធានច្បាប់ និងបទដ្ឋានគតិយុត្តនានា ហើយថែមទាំងធានាឱ្យបាននូវប្រសិទ្ធិភាពក្នុងការអនុវត្តច្បាប់នៅក្នុងប្រទេសនោះផងដែរ។ ធានានូវប្រសិទ្ធភាពក្នុងការអនុវត្តនេះ ក៏ទាមទារឱ្យមានការសហការក្នុងការអនុវត្តពីសំណាក់ប្រជាពលរដ្ឋផងដែរ បើមិនដូច្នេះទេ វិធានច្បាប់ និងបទដ្ឋានគតិយុត្តនឹងមិនអាចមានប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តឡើយ។ ចំពោះជនដែលបានប្រព្រឹត្តប៉ះពាល់ទៅដល់សន្តិសុខ សណ្ដាប់ធ្នាប់ សុវត្ថិភាព តម្លាភាព និងយុត្តិធម៌សាធារណៈ នោះវិធានច្បាប់ និងបទដ្ឋានគតិយុត្ត នឹងដាក់ទណ្ឌកម្មចំពោះជននោះ។

ក្រោយពីបានរួចផុតពីរបបកម្ពុជាប្រជាធិបតេយ្យ វិធានច្បាប់ និងបទដ្ឋានគតិយុត្តិស្ទើរតែទាំងស្រុងត្រូវបានបំផ្លិចបំផ្លាញ។ ហេតុនេះទើបក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តដោយសម្លេង៨៣/៨៣ នៅថ្ងៃទី ៧ ខែមិថុនា ឆ្នាំ២០០៧ ហើយត្រូវបានព្រឹទ្ធសភាអនុម័តដោយសម្លេង ៥១/៥១ នៅថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០០៧ និងត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។ ក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាវិធានច្បាប់មួយដែលកំណត់អំពី កិច្ចនីតិវិធីទាំងឡាយក្នុងការបង្ហាញឱ្យច្បាស់នូវនត្ថិភាពនៃបទល្មើស។ ក្រមនីតិវិធីព្រហ្មទណ្ឌតាក់តែងឡើង មានគោលបំណងដើម្បីកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រតិបត្តិតាមដោយហ្មត់ចត់ ដើម្បីកំណត់ឱ្យច្បាស់នូវនត្ថិភាពនៃបទល្មើសណាមួយ។ ដូចនេះក្រមនីតិវិធីព្រហ្មទណ្ឌ មានភាពចាំបាច់ក្នុងការស្វែងយល់ឱ្យមានភាពច្បាស់លាស់ នូវដំណាក់កាលនីមួយៗនៃក្រមនេះ។ តួយ៉ាង នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមាន ៤ដំណាក់កាលគឺៈ ដំណាក់កាលស៊ើបអង្កេត ដំណាក់កាលចោទប្រកាន់ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលចោទប្រកាន់។ ចំពោះ ***គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់របស់អយ្យការ*** គឺស្ថិតក្នុងដំណាក់កាលចោទប្រកាន់ដែលជាដំណាក់កាលមួយយ៉ាងសំខាន់ក្នុងចំណោមដំណាក់កាលផ្សេងទៀត។ ហើយដំណាក់កាលនេះ សំដៅលើការចោទប្រកាន់របស់តំណាងអយ្យការទៅលើអំពើល្មើសណាមួយ ដើម្បីផ្ដន្ទាទោសតាមច្បាប់ជាធរមាន។

***គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់របស់អយ្យការ*** គឺជាប្រព័ន្ធមួយដែលមានលក្ខណៈបត់បែន និងទន់ភ្លន់ ដោយការផ្ដល់សិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការសម្រេចចោទប្រកាន់ ឬមិនចោទប្រកាន់ និងប្រើប្រាស់នូវនីតិវិធីផ្សេងៗទៀត។ ដូចនេះយើងខ្ញុំនឹងធ្វើការបកស្រាយទៅលើ ប្រធានបទមួយនេះឱ្យកាន់តែស៊ីជម្រៅថែមទៀត។ ដោយយល់ឃើញថា ប្រធានបទមួយនេះមានសារៈសំខាន់ និងលក្ខណៈចាំបាច់ក្នុងការដំណើរការ

នីតិវិធីព្រហ្មទណ្ឌ ដែលជាបុព្វហេតុនាំឱ្យយើងខ្ញុំ សម្រេចជ្រើសរើសប្រធានបទនេះមកធ្វើការសិក្សា ដើម្បីទទួលបាននូវចំណេះដឹង និងស្វែងយល់បន្ថែមឱ្យកាន់តែច្បាស់។

ដើម្បីធ្វើការបកស្រាយនូវចំណុចសំខាន់នៃប្រធានបទនេះ ឱ្យកាន់ស៊ីជម្រៅ ជាដំបូងយើងត្រូវសិក្សាថា តើស្ថាប័នអយ្យការមានអំណាច តួនាទី ភារកិច្ច និងសមាសភាពដូចម្តេច? តើព្រះរាជអាជ្ញាមានអំណាចចោទប្រកាន់ ឬមិនចោទប្រកាន់ដូចម្តេច? តើការចោទប្រកាន់ និងការមិនចោទប្រកាន់មានមូលហេតុ នីតិវិធី លក្ខខណ្ឌ និងអានុភាពយ៉ាងដូចម្តេច?

ដើម្បីឆ្លើយតបនឹងចំណោទបញ្ហាខាងលើ សារណានេះត្រូវសរសេរ និងតាក់តែងឡើងជា ៣ជំពូក ដែលជំពូកនីមួយៗបានបកស្រាយ និងបញ្ជាក់អំពីខ្លឹមសារនៃប្រធានបទនេះ។ ជំពូកទី១ សញ្ញាណទូទៅ ដែលរៀបរាប់ពីសមាសភាព សមត្ថកិច្ច តួនាទី ភារកិច្ច សិទ្ធិអំណាច និងគោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ។ ចំពោះជំពូកទី២ កាលានុវត្តភាពនៃការចោទប្រកាន់ បកស្រាយលើ លក្ខខណ្ឌ និងនីតិវិធីនៃការចោទប្រកាន់ គឺការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។ រីឯជំពូកទី៣ ការតម្កល់រឿងទុកឥតចាត់ការ សិក្សា និងពិភាក្សាលើមូលហេតុ លក្ខខណ្ឌ នីតិវិធី អានុភាព និងយន្តការជម្រុញឱ្យមានការចោទប្រកាន់ឡើងវិញ។

# ជំពូកទី១៖ សញ្ញាណទូទៅ

## ផ្នែកទី១៖ អំពីអង្គការអយ្យការ

ដោយផ្អែកតាមច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ សាលាជម្រះក្ដីនៃព្រះរាជណាចក្រកម្ពុជា មានបីគឺ សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។[1] សាលាជម្រះក្ដី ត្រូវបានបែងចែកជា ២ ជាន់ និង ៣ ថ្នាក់។ ពោលគឺសាលាដំបូង ជាសាលាជម្រះក្ដីជាន់ទាប ហើយសាលាឧទ្ធរណ៍ និងតុលាការកំពូលជាសាលាជម្រះក្ដីជាន់ខ្ពស់។ លើសពីនេះទៅទៀត នៅគ្រប់សាលាជម្រះក្ដី គឺមានអង្គការមួយនៅអម គឺអង្គការអយ្យការ។ ពោលគឺនៅសាលាដំបូង មានអង្គការអយ្យការមួយ ហៅថា អយ្យការអមសាលាដំបូង ហើយនៅសាលាឧទ្ធរណ៍ ក៏មានអង្គការអយ្យការមួយ ហៅថា មហាអយ្យការអមសាលាឧទ្ធរណ៍ និងនៅតុលាការកំពូល មានអង្គការអយ្យការមួយ ហៅថាមហាអយ្យការអមតុលាការកំពូល។[2]

អយ្យការអមសាលាដំបូង មានមុខងារធ្វើបណ្ដឹងអាជ្ញា និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ព្រមទាំងអនុវត្តមុខងារផ្សេងទៀតតាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។[3] មានន័យថា អយ្យការមានមុខងារចំបងក្នុងការធ្វើបណ្ដឹងអាជ្ញា និងជាគូរក្ដីដើមនៃសំណុំរឿងព្រហ្មទណ្ឌ។ ម្យ៉ាងទៀត អយ្យការក៏ជាអ្នកចោទប្រកាន់ ចំពោះអំពើដែលក្រមព្រហ្មទណ្ឌសន្មតថាជាបទល្មើស និងស្នើសុំឱ្យយុត្តាធិការស៊ើបសួរធ្វើការស៊ើបសួរចំពោះអំពើនោះ និងស្នើសុំឱ្យយុត្តាធិការជំនុំជម្រះ ធ្វើការជម្រះចំពោះសំណុំរឿងព្រហ្មទណ្ឌនោះ។ ទាំងនេះគឺស្ដែងឱ្យឃើញពីភាពចាំបាច់ ដែលមិនអាចខ្វះបាននូវអង្គការអយ្យការក្នុងរឿងក្ដីព្រហ្មទណ្ឌ ដែលជាកត្តាជម្រុញឱ្យដំណើរការនៃសំណុំរឿងព្រហ្មទណ្ឌ អាចដំណើរការទៅបាន ដើម្បីផ្ដន្ទាទោសជនល្មើស បង្ក្រាបបទល្មើស និងផ្ដល់យុត្តិធម៌ពិតប្រាកដដល់ជនរងគ្រោះនៃអំពើល្មើសនោះ។ ដើម្បីជាឈ្នាន់ឈានដល់ការបកស្រាយចំពោះ តួនាទីរបស់អយ្យការក្នុងការចោទប្រកាន់ គួរគប្បីស្វែងយល់អំពីសញ្ញាណទូទៅរបស់អង្គការនេះជាមុនសិន។ តើអង្គការអយ្យការមានសមាសភាព សមត្ថកិច្ច តួនាទី និងអំណាចដូចម្ដេច? តើដំណើរការនៃអង្គការអយ្យការផ្អែកលើគោលការណ៍ដូចម្ដេច?

---

[1] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ឆ្នាំ២០១៤, មាត្រា ៣
[2] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ឆ្នាំ២០១៤, មាត្រា ៨
[3] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ឆ្នាំ២០១៤, មាត្រា ៣០ កថាខណ្ឌទី ១

## ផ្នែកទី២៖ អង្គការអយ្យការ

### កថាខណ្ឌទី១៖ សមាសភាពក្នុងអង្គការអយ្យការ

ផ្អែកតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ សមាសភាពនៃអង្គការអយ្យអមសាលាដំបូងរួមមាន៖ ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល និងមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅអង្គការអយ្យអមសាលាដំបូង។[4]

**១. ព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញាអមសាលាដំបូង គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង[5] ពោលគឺជាប្រមុខដឹកនាំរបស់អង្គការអយ្យការអមសាលាដំបូងនីមួយៗ ហើយជាតំណាងនៃអង្គការអយ្យការ[6] ហើយមានសិទ្ធិប្រើប្រាស់អំណាចដែលក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិផ្សេងទៀតប្រគល់ឱ្យ។ ការប្រើប្រាស់អំណាចទាំងនេះគឺក្នុងគោលបំណងដើម្បីធ្វើសកម្មភាពតំណាងនៃអង្គការអយ្យការ។ ម្យ៉ាងទៀត អង្គការអយ្យការនីមួយៗដឹកនាំដោយព្រះរាជអាជ្ញាម្នាក់ គឺជាមន្ត្រីដែលស្ថិតនៅក្នុងស្ថាប័នអយ្យការ ដែលផ្តួចផ្តើមធ្វើបណ្តឹងអាជ្ញាក្នុងការចោទប្រកាន់បទល្មើសណាមួយ ទទួលបន្ទុកស្វែងរកបទល្មើសព្រហ្មទណ្ឌ ធ្វើការចោទប្រកាន់ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជំម្រះ ក្នុងនាមផលប្រយោជន៍សង្គម។

**២. ព្រះរាជអាជ្ញារង**

អយ្យការអមសាលាដំបូងនីមួយៗ គឺត្រូវដឹកនាំដោយព្រះរាជអាជ្ញាមួយរូប និងព្រះរាជអាជ្ញារងមួយចំនួនតាមការចាំបាច់។ ព្រះរាជអាជ្ញារង គឺជាឋានានុក្រមថ្នាក់ក្រោមរបស់ព្រះរាជអាជ្ញា ដែលត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួម របស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។ ពោលគឺ ព្រះរាជអាជ្ញារង ស្ថិតក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមាន ក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស។[7] ចំពោះចំនួនព្រះរាជអាជ្ញារងនៅតាមអង្គការអយ្យការអមសាលាដំបូងនានា គឺមិនអាចកំណត់បាននោះទេ ពោលគឺអាស្រ័យតាមភាពចាំបាច់លើតម្រូវការការងារ និងភាពចាំបាច់ជាក់ស្តែង។ ចំពោះរាល់សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារង ត្រូវតែធ្វើការបញ្ជូនទៅព្រះរាជអាជ្ញាពិនិត្យជាមុនសិន ក្នុងករណីដែល

[4] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ឆ្នាំ២០១៤, មាត្រា ២៩

[5] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ឆ្នាំ២០១៤, មាត្រា ៧៥ កថាខណ្ឌទី ១

[6] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៦ កថាខណ្ឌទី ១

[7] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៨

ព្រះរាជអាជ្ញាមិនយល់ព្រមលើសេចក្តីសន្និដ្ឋាននោះទេ ហើយព្រះរាជអាជ្ញារងមិនព្រមធ្វើតាមនោះទេ ព្រះរាជអាជ្ញាមានសិទ្ធិក្នុងការចាត់តាំងព្រះរាជអាជ្ញារងផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងក៏បាន។

ដូច្នេះ ព្រះរាជអាជ្ញារង គឺមានសិទ្ធិអំណាចដូចទៅនឹងព្រះរាជអាជ្ញាដែរ ប៉ុន្តែសិទ្ធិអំណាចទាំងនោះ ត្រូវស្ថិតនៅក្រោមការពិនិត្យ និងសម្រេចដោយព្រះរាជអាជ្ញា។

**៣. ក្រឡាបញ្ជី**

ក្រឡាបញ្ជី គឺជាអ្នកបច្ចេកទេសផ្នែកនីតិវិធីដែលជួយសម្រួលដល់ព្រះរាជអាជ្ញា នៅក្នុងសកម្មភាពសាលាជម្រះក្តីទៅតាមលក្ខខណ្ឌដែលមានកំណត់ក្នុងអត្ថបទច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។ ម្យ៉ាងទៀត ក្រឡាបញ្ជីត្រូវស្ថិតនៅក្រោមបង្គាប់ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង សម្រាប់កិច្ចការផ្នែកយុត្តាធិការ។[8] នៅគ្រប់អង្គការតុលាការ និងអង្គការអយ្យការ ត្រូវមានក្រឡាបញ្ជី ហើយមានតួនាទីជួយព្រះរាជអាជ្ញានៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ និងអយ្យការ។ ក្រឡាបញ្ជី មិនអាចធ្វើការសម្រេច ឬសន្និដ្ឋានណាមួយដែលជាសមត្ថកិច្ចរបស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងបានឡើយ។

សរុបជារួម ក្រឡាបញ្ជី គឺមាននៅគ្រប់អង្គការអយ្យការ ហើយជាលេខាធិការផ្ទាល់របស់ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងក្នុងការជួយសម្រួលនូវការងារបច្ចេកទេសផ្នែកនីតិវិធីរឿងក្តី ដែលច្បាប់តម្រូវជាចាំបាច់ត្រូវតែមាន។

**កថាខណ្ឌទី២៖ សមត្ថកិច្ច តួនាទី ភារកិច្ច សិទ្ធិអំណាចរបស់តំណាងអង្គការអយ្យការ**

**១. សមត្ថកិច្ចរបស់តំណាងអយ្យការ**

នៅពេលដែលមានបទល្មើសណាមួយកើតឡើង ការស្រាវជ្រាវនៃបទល្មើសនោះអាចនឹងមាននៅច្រើនកន្លែងផ្សេងៗពីគ្នា ដែលអាចជាទីកន្លែងប្រព្រឹត្តបទល្មើស ទីលំនៅរបស់ជនល្មើស និងទីកន្លែងចាប់ខ្លួនជនសង្ស័យជាអាទិ៍។ ដោយហេតុថា កន្លែងនៃការស្រាវជ្រាវបទល្មើសអាចមានច្រើន ដែលបណ្តាលឱ្យមានភាពស្មុគស្មាញ។ ដូចនេះបទប្បញ្ញត្តិច្បាប់បានបែងចែកសមត្ថកិច្ចរបស់ព្រះរាជអាជ្ញាទៅតាមសមត្ថកិច្ចដែនដី៖

–ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស

–ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស

–ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើស។[9]

**២. តួនាទីរបស់តំណាងអយ្យការ**

នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាពិតជាមានតួនាទីយ៉ាងសកម្មក្នុងចំណាត់ការលើរឿងក្តី។ តួនាទីទាំងនោះ អាចជាការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ពិនិត្យនីត្យានុកូលភាពនៃបទល្មើស ពិនិត្យការអនុវត្ត

[8] សេចក្តីព្រៀងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី នៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ២

[9] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៩

សេចក្ដីសម្រេចរបស់តុលាការ និងតួនាទីផ្សេងៗទៀត។ សម្គាល់ ចំណាត់ការរបស់ព្រះរាជអាជ្ញាក្នុងរឿងក្ដីព្រហ្មទណ្ឌ គឺក្នុងនាមតំណាងឱ្យផលប្រយោជន៍សាធារណៈ។ លើសពីនេះទៅទៀត ព្រះរាជអាជ្ញា ក៏រួមចំណែកក្នុងការធានាដល់កិច្ចដំណើរការ និងការប្រព្រឹត្តទៅដោយរលូន និងធានាដល់ភាពយុត្តិធម៌ឆាប់រហ័សលើផ្នែកព្រហ្មទណ្ឌ តាមរយៈការបំពេញតួនាទីរបស់ខ្លួនខ្ជាប់ខ្ជួន ម៉ឺងម៉ាត់ និងឆាប់រហ័ស ប្រកបដោយការគោរព និងការពារសេចក្ដីថ្លៃថ្នូររបស់មនុស្ស។

**៣. ភារកិច្ចរបស់តំណាងអយ្យការ**

ក្នុងការបំពេញតួនាទីរបស់ខ្លួន ព្រះរាជអាជ្ញាត្រូវ៖

–អនុវត្តមុខនាទីរបស់ខ្លួន ដោយមិនលំអៀង និងជៀសវាងរាល់ការរើសអើងពូជសាសន៍ ពណ៌សម្បុរ វប្បធម៌ សាសនាជាអាទិ៍។

–ការពារផលប្រយោជន៍សាធារណៈ យកចិត្តទុកដាក់ចំពោះជនសង្ស័យ និងជនរងគ្រោះដោយមិនលំអៀង និងប្រុងប្រយ័ត្នគ្រប់ស្ថានភាព បើទោះជាមាន ឬគ្មានផលប្រយោជនដល់ជនសង្ស័យក៏ដោយ។

–រក្សារឿងក្ដីជាការសម្ងាត់ លើកលែងតែត្រូវបំពេញភារកិច្ច ឬជាការតម្រូវរបស់តុលាការដើម្បីបញ្ជាក់ពីភាពយុត្តិធម៌។

–ពិនិត្យមើលទិដ្ឋភាពទូទៅ និងក្ដីបារម្ភរបស់ជនរងគ្រោះ នៅពេលមានការប៉ះពាល់ផលប្រយោជន៍របស់ពួកគេ និងប្រាប់ពីសិទ្ធិរបស់ជនរងគ្រោះ ដើម្បីឱ្យស្របទៅនឹងយុត្តិធម៌របស់ជនរងគ្រោះ ក្នុងរឿងក្ដីព្រហ្មទណ្ឌ និងការរំលោភអំណាច។

**៤. អំណាចរបស់តំណាងអយ្យការ**

ចំពោះសំណុំរឿងព្រហ្មទណ្ឌក្នុងដំណាក់កាលចោទប្រកាន់ ព្រះរាជអាជ្ញាគឺជាអ្នកមានសមត្ថកិច្ច និងទទួលបន្ទុកធ្វើចំណាត់ការលើសំណុំរឿង។ នៅក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញាមានអំណាចក្នុងការដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន វៀរលែងក្នុងករណីដែលអនុវត្តដីកាសម្រេចចាត់ឱ្យស៊ើបសួរជំនួស ដែលមន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។ ចំណែកឯក្នុងដំណាក់កាលស៊ើបអង្កេត ដើម្បីធ្វើការចោទប្រកាន់ចំពោះអំពើណាមួយ ព្រះរាជអាជ្ញាត្រូវធ្វើការស៊ើបអង្កេតក្នុងគោលបំណងស្វែងរកធាតុផ្សំបទល្មើស និងភស្តុតាងឱ្យបានគ្រប់គ្រាន់។ ក្នុងករណីនេះ ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ឱ្យទៅមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត។[10] ដូច្នេះ ព្រះរាជអាជ្ញាប្រើប្រាស់អំណាចក្នុង

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៧ កថាខណ្ឌទី ២

ការស៊ើបអង្កេតបឋម ឬការស៊ើបអង្កេតករណីជាក់ស្តែង ដែលអំណាចទាំងនោះអាចជា៖ ការឆែកឆេរ ការចាប់យកវត្ថុតាង ការបញ្ជាឱ្យចូលខ្លួន ការធ្វើកោសលវិច័យ។ល។ ឱ្យទៅមន្ត្រីនគរបាលយុត្តិធម៌បាន។ រីឯក្នុងដំណាក់កាលចោទប្រកាន់វិញ ព្រះរាជអាជ្ញាមានអំណាចក្នុងការសម្រេចជ្រើសរើសវិធីក្នុងការចោទប្រកាន់ ឬការសម្រេចមិនចោទប្រកាន់ ហៅថា "**ជម្រើសនៃការចោទប្រកាន់**" ឬ "**គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់**"។

## ផ្នែកទី៣៖ គោលការណ៍របស់អង្គការអយ្យការ

គោលការណ៍គ្រឹះនៃអង្គការអយ្យការ គឺជាទ្រឹស្តីដែលសម្រាប់ប្រើជាគោល ក្នុងការអនុវត្ត ឬសម្រាប់ដំណើរការនៅក្នុងអង្គការអយ្យការ។ នៅក្នុងទំនាក់ទំនងការងារនៃការរៀបចំអង្គការអយ្យការ ព្រះរាជអាជ្ញាត្រូវគោរពនូវគោលការណ៍ដូចជា៖ (១) គោលការណ៍ឯកភាព (២) គោលការណ៍អវិភាគ (៣) គោលការណ៍ឯករាជ្យ (៤) គោលការណ៍មិនអាចប្តឹងជំទាស់ដិតចិត្ត និង(៥) គោលការណ៍មិនទទួលខុសត្រូវ។

### កថាខណ្ឌទី១៖ គោលការណ៍ឯកភាព

គោលការណ៍ឯកភាព ឬគោលការណ៍ឋានានុក្រម ជាការដែលឋានានុក្រមថ្នាក់ក្រោម ត្រូវតែស្តាប់ការណែនាំ និងការបង្គាប់របស់នាយឋានានុក្រមថ្នាក់លើ។ មានន័យថា ព្រះរាជអាជ្ញារងនៅអយ្យការអមសាលាដំបូងនីមួយៗ ត្រូវធ្វើការក្រោមការទទួលខុសត្រូវ និងការណែនាំរបស់ព្រះរាជអាជ្ញា។ ចំណែកឯព្រះរាជអាជ្ញាមានសិទ្ធិណែនាំ និងបញ្ជាទៅដល់ព្រះរាជអាជ្ញារងទាំងអស់។ រីឯនៅមហាអយ្យការអមសាលាឧទ្ធរណ៍វិញ អគ្គព្រះរាជអាជ្ញាមានអំណាចឋានានុក្រមទៅលើអគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញាដែលធ្វើការនៅក្នុងមហាអយ្យការ។

ម្យ៉ាងទៀត សេចក្តីបង្គាប់ ឬការណែនាំរបស់នាយឋានានុក្រម មិនអាចប្រឆាំង ឬមិនធ្វើតាមបានទេ។ ក្នុងករណីដែលឋានានុក្រមថ្នាក់ក្រោម ប្រឆាំង ឬមិនធ្វើតាមបង្គាប់ ឬការណែនាំនោះទេ នាយឋានានុក្រម មានសិទ្ធិក្នុងការដកព្រះរាជអាជ្ញារូបនោះចេញពីសំណុំរឿង ដោយដាក់ខ្លួនផ្ទាល់ឬផ្ទេរទៅឱ្យព្រះរាជអាជ្ញាផ្សេងទៀតបាន។ គួរឱ្យកត់សម្គាល់ផងដែរ នាយឋានានុក្រមអាចធ្វើអធិបញ្ញាបានគ្រប់យ៉ាង ដូចជាការធ្វើសេចក្តីសន្និដ្ឋានតាមការយល់ឃើញរបស់ខ្លួន ប៉ុន្តែមិនអាចធ្វើអធិបញ្ញាឱ្យតម្កល់រឿងទុកឥតចាត់ការបានទេ។ តែនៅក្នុងសវនាការ ព្រះរាជអាជ្ញា អាចធ្វើសេចក្តីសន្និដ្ឋានតាមការយល់ឃើញរបស់ខ្លួន បើទោះបីជាការសន្និដ្ឋាននោះខុសពីសេចក្តីសន្និដ្ឋានក្នុងសំណុំរឿងក៏ដោយ។

### កថាខណ្ឌទី២៖ គោលការណ៍អវិភាគ

គោលការណ៍អវិភាគ មានន័យថា សមាជិកនៃអង្គការអយ្យការម្នាក់ជាតំណាងឱ្យអង្គការទាំងមូល។ ពោលគឺ នៅក្នុងសំណុំរឿងក្តីមួយ ព្រះរាជអាជ្ញាអាចត្រូវបានផ្លាស់ប្តូរ ឬជំនួសគ្នាទៅវិញទៅមកបាន។ តាមគោលការណ៍នេះ តំណាងអយ្យការមានច្រើនរូប អាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំង

របស់នាយឋានានុក្រម។[11] ដោយនៅមហាអយ្យការអមតុលាការកំពូល និងអមសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា ធ្វើការក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់អគ្គព្រះរាជអាជ្ញា ហើយនៅអយ្យការអមសាលាដំបូងវិញ ព្រះរាជអាជ្ញារង ធ្វើការក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា។

**កថាខណ្ឌទី៣៖ គោលការណ៍ឯករាជ្យ**

អង្គការអយ្យការ គឺជាអង្គឯករាជ្យពីសាលាជម្រះក្តី បើទោះបីជាអយ្យការស្ថិតនៅអមនឹងសាលាដំបូងក៏ដោយ ពោលគឺអង្គការអយ្យការមិនស្ថិតនៅចំណុះឱ្យសាលាជម្រះក្តីឡើយ។ លើសពីនេះទៅទៀត សាលាជម្រះក្តី គ្មានអំណាចត្រួតពិនិត្យទៅលើតំណាងអយ្យការទេ ពោលគឺកិច្ចការរបស់តំណាងអយ្យការ មិនអាចត្រូវបានលូកលាន់ ឬជ្រៀតជ្រែកដោយសាលាជម្រះក្តី ឬពីចៅក្រមអាសនៈឡើយ។ ចំពោះការចោទប្រកាន់ ឬសកម្មភាពការងាររបស់តំណាងអយ្យការ គឺផ្នែកខាងចៅក្រមអាសនៈ ឬប្រធានតុលាការ មិនអាចធ្វើការស្តីបន្ទោស ឬធ្វើការណែនាំបានទេ។ ក្នុងករណីដែលតំណាងអយ្យការបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ ចៅក្រមអាសនៈ ឬប្រធានតុលាការអាចរាយការណ៍ទៅនាយឋានានុក្រមនៃតំណាងអយ្យការបាន។ ការរាយការណ៍នេះ មិនអាចលើកជាសំណើដើម្បីឱ្យធ្វើចំណាត់ការទៅលើកំហុសរបស់តំណាងអយ្យការបានទេ។[12]

**កថាខណ្ឌទី៤៖ គោលការណ៍មិនអាចប្តឹងជំទាស់**

ជាទូទៅ ចៅក្រមអាសនៈអាចនឹងត្រូវបានផ្លាស់ប្តូរ ប្រសិនបើមានពាក្យប្តឹងជំទាស់ពីភាគី ឬពាក្យសុំដកខ្លួនពីចៅក្រមផ្ទាល់ ហើយមានមូលហេតុស្របតាមមាត្រា ៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីពីមូលហេតុនៃការប្តឹងជំទាស់ចៅក្រមអាសនៈ។ បណ្តឹងជំទាស់ សំដៅដល់ការស្នើសុំដកហូតសមាសភាពចៅក្រមណាមួយចេញពីសំណុំរឿង ក្នុងដំណាក់កាលណាមួយដោយមូលហេតុសមាសភាពនៃចៅក្រមរូបនោះ អាចធ្វើឱ្យមានការលំអៀង ឬភាគីយល់ឃើញថាមិនអាចផ្តល់យុត្តិធម៌ឱ្យខ្លួនបាន។

ដោយឡែក តំណាងអយ្យការមិនអាចត្រូវបានប្តឹងជំទាស់ឡើយ បើទោះបីជាមានមូលហេតុស្របតាមមាត្រា ៥៥៦ ក៏ដោយ។ ពោលគឺប្រសិនបើព្រះរាជអាជ្ញាមានពាក់ព័ន្ធជាសាច់ញាតិ ឬមានផលប្រយោជន៍ក្នុងបណ្តឹងក៏ដោយ ក៏ភាគីមិនអាចប្តឹងជំទាស់បានឡើយ ដោយហេតុថាព្រះរាជអាជ្ញាធ្វើសកម្មភាពក្នុងនាមជាអ្នកតំណាងឱ្យរដ្ឋ ដោយមិនមែនក្នុងនាមគាត់ផ្ទាល់ឡើយ។

[11] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ឆ្នាំ២០១៤, មាត្រា ៧៥ កថាខណ្ឌទី ២

[12] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ឆ្នាំ២០១៤, មាត្រា ៧៥ កថាខណ្ឌទី ៣

**កថាខណ្ឌទី៥៖ គោលការណ៍មិនទទួលខុសត្រូវ**

ជាទូទៅ អយ្យការ ជាតំណាងឱ្យអំណាចនីតិប្រតិបត្តិដើម្បីការពារផលប្រយោជន៍សាធារណៈ និងតាំងខ្លួនជាគូរក្តីដើមប្រឆាំងនឹងជនល្មើសជានិច្ច។ ពោលគឺព្រះរាជអាជ្ញា ធ្វើសកម្មភាពក្នុងនាមតំណាងឱ្យរដ្ឋ ដោយធ្វើការចោទប្រកាន់ចំពោះអង្គហេតុណាមួយ ដែលខ្លួនយល់ថាជាបទល្មើសព្រហ្មទណ្ឌ។ម្យ៉ាងទៀត ការចោទប្រកាន់ធ្វើឡើងតាមរយៈបណ្តឹងអាជ្ញា ដែលបើកប្រឆាំងចំពោះគ្រប់បុគ្គល ដោយមិនប្រកាន់វណ្ណៈ ពូជសាសន៍ ជាអាទិ៍។ នៅពេលដែលព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ចំពោះបុគ្គលណាម្នាក់ ហើយស្ថាប័នយុត្តាធិការធ្វើការជំនុំជម្រះ ដោយប្រកាសថាគ្មានពិរុទ្ធ ហើយដោះលែងឱ្យមានសេរីភាពវិញ នោះព្រះរាជអាជ្ញាដែលជាគូរក្តីដើមដែលបានចោទប្រកាន់ជនគ្មានកំហុសនោះ មិនត្រូវទទួលខុសត្រូវពីបទព្រហ្មទណ្ឌឬទណ្ឌកម្មខាងវិន័យឡើយ។ ប៉ុន្តែជាគោលការណ៍នៃការមិនទទួលខុសត្រូវនៃអង្គការអយ្យការ មិនអាចធ្វើឱ្យព្រះរាជអាជ្ញារួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ចំពោះករណីដែលព្រះរាជអាជ្ញា បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលកើតឡើងពីឆន្ទៈទុច្ចរិតក្នុងការបំពេញមុខងារតួនាទីរបស់ខ្លួនបានទេ។

## ជំពូកទី២៖ កាលានុវត្តភាពនៃការចោទប្រកាន់

នៅពេលដែលព្រះរាជអាជ្ញាទទួលបានពាក្យបណ្តឹងបរិហា ឬពាក្យប្តឹងពីជនរងគ្រោះប្រគល់ជូនព្រះរាជអាជ្ញាផ្ទាល់ ឬតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ក៏ដោយ ព្រះរាជអាជ្ញាត្រូវថ្លឹងថ្លែងទៅលើពាក្យបណ្តឹងទាំងនោះព្រមទាំងអាចធ្វើការសម្រេចចិត្តដោយឆន្ទានុសិទ្ធិ ក្នុងការតម្កល់រឿងទុកឥតចាត់ការ ឬសម្រេចចិត្តចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។[13] ការសម្រេចចិត្តដោយឆន្ទានុសិទ្ធិនេះគេហៅថា **"គោលការណ៍កាលានុវត្តភាព"** នៃការចោទប្រកាន់។ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ គឺជាសេរីភាពរបស់ព្រះរាជអាជ្ញា ដើម្បីធ្វើជាមូលវិចារណ៍ក្នុងការសម្រេចថាចាត់ការ ឬមិនចាត់ការក្នុងបណ្តឹងរបស់ជនរងគ្រោះ ឬបណ្តឹងបរិហាពីជនណាមួយ ឬអង្គការណាមួយពីបទល្មើសព្រហ្មទណ្ឌណាមួយដែលបានសន្មតថាកើតមានឡើង។ ម្យ៉ាងវិញទៀត នៅមុនពេលសម្រេចចិត្តព្រះរាជអាជ្ញាអាចធ្វើការបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម ដើម្បីជាមូលដ្ឋានក្នុងការសម្រេចចិត្តឱ្យបានត្រឹមត្រូវក្នុងការជ្រើសរើសជម្រើសណាមួយមកចោទប្រកាន់ ឬធ្វើការតម្កល់រឿងទុកឥតចាត់ការបាន។ ហេតុនេះទើបធ្វើឱ្យលេចឡើងនូវសំណួរមួយលើកឡើងថា តើអ្វីទៅជាការចោទប្រកាន់របស់ព្រះរាជអាជ្ញា? ការចោទប្រកាន់របស់ព្រះរាជអាជ្ញា គឺជាចំណាត់ការមួយដែលមានអានុភាពក្នុងការផ្ទេរសមត្ថកិច្ចពីតំណាងអយ្យការ ទៅយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ ឬអាចនិយាយបានថា ជាការបញ្ជូនជនល្មើសមួយ ឬច្រើននាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ ឬចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌ ដើម្បីធ្វើការផ្តន្ទាទោសទៅតាមបញ្ញត្តិច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ យ៉ាងណាមិញ ប្រសិនបើព្រះរាជអាជ្ញាសម្រេចថានឹងធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ នីតិវិធីដែលអាចបើកកិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញាមាន ៣ (បី) យ៉ាងគឺ៖

**ផ្នែកទី១ ការបើកការស៊ើបសួរ ឬហៅកាត់ថា RI**

**ផ្នែកទី២ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬហៅកាត់ថា CD**

**ផ្នែកទី៣ តាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម ឬហៅកាត់ថា CI**

### ផ្នែកទី១៖ ការបើកការស៊ើបសួរ

ការបើកការស៊ើបសួរ គឺជាសិទ្ធិ និងតួនាទីរបស់ចៅក្រមស៊ើបសួរ ក្នុងការស្រាវជ្រាវចំពោះអង្គហេតុនៃបទល្មើសព្រហ្មទណ្ឌក្រោយពីទទួលបាន ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ ឬព្រះរាជអាជ្ញា។ ចំពោះកិច្ចស៊ើបសួរទាំងអស់ គឺត្រូវបានអនុវត្តន៍ និងដឹកនាំដោយផ្ទាល់ដោយចៅក្រមស៊ើបសួរ ដើម្បីប្រមូលភស្តុតាងទាំងអស់ដែលពាក់ព័ន្ធ និងបញ្ជាក់ពីការពិតនៃអង្គហេតុព្រហ្មទណ្ឌ ចាប់តាំងពីការចាប់ផ្តើមស្រាវជ្រាវ

[13] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤០

រហូតដល់ការបញ្ចប់ការស៊ើបសួរ។ ការស្រាវជ្រាវនេះ គឺខុសពីការស្រាវជ្រាវរបស់ព្រះរាជអាជ្ញា ព្រោះព្រះរាជអាជ្ញាធ្វើការស្រាវជ្រាវរកតែព័ត៌មាន និងភស្តុតាងទាំងឡាយណា ដែលជាមូលដ្ឋានក្នុងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌប៉ុណ្ណោះ។ ប៉ុន្តែនៅពេលដែលចៅក្រមស៊ើបសួរបានទទួលនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញានោះ ចៅក្រមស៊ើបសួរត្រូវបំពេញកិច្ចនីតិវិធី ក៏ដូចជាធ្វើការស្រាវជ្រាវដោយលម្អិតជាងមុន ដើម្បីស្វែងរកព័ត៌មានពិតប្រាកដ និងភស្តុតាងទាំងឡាយណាដែលពាក់ព័ន្ធ ក៏ដូចជាស្វែងរកសាក្សីដើម្បីមកផ្ដល់នូវសាក្ខីកម្ម ដើម្បីកំណត់ឱ្យឃើញអំពីនត្ថិភាព ឬអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌ ដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ ហើយក្នុងខណៈនោះចៅក្រមស៊ើបសួរនឹងស្វែងរកគ្រប់ទន្និន័យ ឬព័ត៌មានទាំងអស់ដែលរួមមានទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក។[14] ដូចដែលបានលើកឡើងខាងលើ ការស៊ើបសួរត្រូវបានបើកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬហៅកាត់ថា RI ដែលត្រូវបានប្ដឹងដោយចៅក្រមស៊ើបសួរ។ គួរបញ្ជាក់ផងដែរថា ចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរតែអង្គហេតុណា ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬប្រឆាំងទៅលើអញ្ញាតជន។[15] ចៅក្រមស៊ើបសួរក៏អាចបើកកិច្ចស៊ើបសួរបានផងដែរ ចំពោះបុគ្គលទាំងឡាយណាដែលមានតម្រុយស៊ីចង្វាក់ និងច្បាស់លាស់ដែលបញ្ជាក់ថាបុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ដូចដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទោះបីជាបុគ្គលនោះមិនមានឈ្មោះក្នុងដីកាក៏ដោយក្ដី។

## កថាខណ្ឌទី១៖ លក្ខខណ្ឌនៃការបើកការស៊ើបសួរ

ដើម្បីឈានដល់ការបើកការស៊ើបសួរ គឺមានលក្ខខណ្ឌមួយចំនួនដែលចង្អុលបង្ហាញថាស្របតាមនីតិវិធីនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ហើយលក្ខខណ្ឌនោះសំដៅដល់ការកំណត់ប្រភេទនៃបទល្មើសជាមុនសិនទើបព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់តាមនីតិវិធីនៃការបើកការស៊ើបសួរ។ ប្រភេទនៃបទល្មើសដែលអាចធ្វើការចោទប្រកាន់បាននោះគឺ បទឧក្រិដ្ឋ និងបទមជ្ឈិម។[16]

### ១. ការបើកការស៊ើបសួរករណីបទឧក្រិដ្ឋ

ការបើកការស៊ើបសួរ គឺជានីតិវិធីមួយដែលវែងអន្លាយ និងមានភាពស្មុគស្មាញ ក្នុងការស្រាវជ្រាវស្វែងរកភស្តុតាងដែលពិសេសនោះ គឺមានទៅលើបទឧក្រិដ្ឋ។ ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាចាំបាច់ត្រូវតែធ្វើបណ្ដឹង

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២៧ កថាខណ្ឌទី២

[15] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៤ កថាខណ្ឌទី ២

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២២

ទៅចៅក្រមស៊ើបសួរដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដើម្បីបើកការស៊ើបសួរជាដាច់ខាត។[17] មានន័យថានៅក្នុងករណីបទឧក្រិដ្ឋ ចៅក្រមស៊ើបសួរចាំបាច់ត្រូវតែបើកការស៊ើបសួរជាដាច់ខាត មិនអាចរំលង ឬមិនបើកការស៊ើបសួរបាននោះទេ។ បើនិយាយពីបទឧក្រិដ្ឋ គ្មានបទឧក្រិដ្ឋណាមួយដែលមិនបានឆ្លងកាត់ការជំនុំជម្រះនោះទេ ព្រោះបទឧក្រិដ្ឋ ជាបទល្មើសដែលមានអតិបរិមានៃទោសដាក់ពន្ធនាគារលើសពី ៥ (ប្រាំ) ឆ្នាំ និងក្រោម ឬស្មើ៣០ (សាមសិប) ឆ្នាំ ឬត្រូវជាប់ពន្ធនាគារអស់មួយជីវិត។[18] ប្រសិនបើយើងផ្អែកតាមនិយមន័យបទឧក្រិដ្ឋ យើងឃើញថាបទឧក្រិដ្ឋជាបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរ ឬមានលក្ខណៈស្មុគស្មាញ ដែលជាហេតុទាមទារឱ្យមានការស្រាវជ្រាវឱ្យបានម៉ត់ចត់ ទើបឈានដល់ការសម្រេចបញ្ជូនជនល្មើសទៅជំនុំជម្រះនៅចំពោះមុខតុលាការ។ ការធ្វើបែបនេះ ព្រោះដើម្បីចៀសវាងការភាន់ច្រឡំនៅពេលជំនុំជម្រះដែលអាចនាំឱ្យមោឃភាពដល់នីតិវិធី ឬធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនដែលត្រូវបានគេចោទប្រកាន់ និងដើម្បីធានាដល់ដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌។

**២. ការបើកការស៊ើបសួរករណីបទមជ្ឈិម**

ចំពោះបទមជ្ឈិម គឺជាប្រភេទបទល្មើសដែលមានលក្ខណៈនៃទោសធូរស្រាលជាងបទឧក្រិដ្ឋ ដែលបទល្មើសនេះបានកំណត់អតិបរិមានៃទោសដាក់ពន្ធនាគារលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ។[19] ករណីបទមជ្ឈិម ព្រះរាជអាជ្ញាអាចសម្រេចដោយឆន្ទានុសិទ្ធិ ដោយយកការបើកការស៊ើបសួរ ឬជ្រើសរើសជម្រើសផ្សេងពីនេះទៀត ដោយថ្លឹងថ្លែងទៅតាមប្រភេទនៃបទល្មើស។ ការបើកការស៊ើបសួរចំពោះករណីបទមជ្ឈិម ចៅក្រមស៊ើបសួរអាចធ្វើការបើកក៏បាន ឬមិនបើកក៏បាន។[20] ដោយឡែក ការបើកការស៊ើបសួរចំពោះបទមជ្ឈិម នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមិនបានកំណត់យ៉ាងច្បាស់ ថាប្រភេទបទមជ្ឈិមនោះមានលក្ខណៈស្មុគស្មាញ ឬយ៉ាងណានោះទេ ដែលនាំឱ្យព្រះរាជអាជ្ញាសម្រេចជ្រើសរើសជម្រើសណាមួយយកមកចោទប្រកាន់ ប៉ុន្តែប្រសិនបើបទមជ្ឈិមនោះមានលក្ខណៈស្មុគស្មាញខ្លាំងនោះ ព្រះរាជអាជ្ញាអាចមានឆន្ទានុសិទ្ធិ ដោយជ្រើសរើសការបើកការស៊ើបសួរបានដូចនឹងការបើកការស៊ើបសួរក្នុងករណីបទឧក្រិដ្ឋដែរ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលព្រះរាជអាជ្ញាបានប្រើនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមក្នុងការចោទប្រកាន់ជនល្មើស ប៉ុន្តែនៅពេលដែលតុលាការដែលបានទទួលបណ្តឹងយល់ឃើញថាមិនបានបំពេញតាមលក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាម ដូចដែលបានចែងក្នុងមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឬមានភាពស្មុគស្មាញនៅក្នុងសំណុំរឿង ដែលតម្រូវឱ្យមានការ

[17] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៤ កថាខណ្ឌទី ១

[18] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៤៦

[19] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៤៧

[20] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២២

ស្រាវជ្រាវបន្ថែមនោះ តុលាការអាចបញ្ជូនសំណុំរឿងទៅកាន់ព្រះរាជអាជ្ញាវិញ ដើម្បីប្រើកិច្ចនីតិវិធីបើកការស៊ើបសួរ។[21] ប៉ុន្តែនៅពេលដែលជនល្មើសនោះជាអញ្ញាតជន ដែលពុំមានអត្តសញ្ញាណច្បាស់លាស់ ហើយសំណុំរឿងពុំទាន់ពេញលេញនៅឡើយ ពោលគឺមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការជំនុំជម្រះបាន ដូចនេះព្រះរាជអាជ្ញាត្រូវតែប្រើនីតិវិធីបើកការស៊ើបសួរ។

សរុបជារួមមក នៅក្នុងប្រភេទនៃបទល្មើសដូចដែលបានរៀបរាប់ខាងលើ ព្រះរាជអាជ្ញាអាចប្រើនីតិវិធីបើកការស៊ើបសួរបាន។ យ៉ាងណាមិញ ការបើកការស៊ើបសួរមិនអាចបើកចំពោះបទលហុបានទេ ដោយសារតែបទលហុ ជាប្រភេទបទល្មើសដែលមានអតិបរិមានៃទោសដាក់ពន្ធនាគារដែលមានរយៈពេលក្រោម ឬស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ ដែលប្រភេទនៃបទល្មើសនេះមានភាពធូរស្រាល ហើយនៅពេលដែលចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរវាមានរយៈពេលវែង និងច្រើនដំណាក់កាល ដែលវាអាចលើសពីបរិមាណពី ៦ (ប្រាំមួយ) ថ្ងៃនៃបទលហុ ដែលនាំឱ្យបទលហុមិនត្រូវបានបើកការស៊ើបសួរបានទេ។

**កថាខណ្ឌទី២៖ នីតិវិធីនៃការបើកការស៊ើបសួរ**

ព្រះរាជអាជ្ញាអាចសម្រេចធ្វើការចោទប្រកាន់ដោយការបើកការស៊ើបសួរ តាមរយៈការទទួលបណ្តឹងនៅក្នុងករណី ២ (ពីរ) យ៉ាងគឺ ការបើកការស៊ើបសួរតាមរយៈពាក្យបណ្តឹងបញ្ជូនមកដោយផ្ទាល់ ឬបណ្តឹងសាមញ្ញ (១) និងការបើកការស៊ើបសួរចំពោះពាក្យបណ្តឹងដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (២)។

**១. ការបើកការស៊ើបសួរតាមរយៈពាក្យបណ្តឹងបញ្ជូនមកដោយផ្ទាល់ ឬបណ្តឹងសាមញ្ញ**

ការស៊ើបសួរត្រូវបានបើកតាមរយៈពាក្យបណ្តឹងសាមញ្ញ ឬពាក្យបណ្តឹងដែលមន្ត្រីនគរបាលយុត្តិធម៌បានប្តឹងដោយផ្ទាល់ទៅកាន់ព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ ដើម្បីបើកកិច្ចនីតិវិធីស៊ើបសួរ។ ចំពោះពាក្យបណ្តឹងសាមញ្ញ គឺជាបណ្តឹងទាំងឡាយណាដែលធ្វើឡើងក្នុងគោលបំណងដើម្បីជួសជុលព្យសនកម្មដែលខ្លួនទទួលរងការខូចខាត ឬចង់បង្ហាញប្រាប់ពីអង្គហេតុនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលកើតឡើងហើយខ្លួនបានឃើញទៅកាន់អាជ្ញាធរមានសមត្ថកិច្ច។ ប៉ុន្តែចំពោះពាក្យបណ្តឹងសាមញ្ញនេះ មិនទាន់មានអានុភាពសម្រាប់ធ្វើការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌបានទេ។[22] នៅពេលដែលព្រះរាជអាជ្ញាទទួលបាននូវបណ្តឹងសាមញ្ញ ទោះបីជាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរក្តី ក៏ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងនោះត្រឡប់មកព្រះរាជអាជ្ញាវិញដដែល ព្រោះពាក្យបណ្តឹងមិនមានលក្ខណៈស្របទៅតាមច្បាប់។[23]

---

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៨ កថាខណ្ឌទី ១១

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៦

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២៤ កថាខណ្ឌទី៥

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានទទួលស្គាល់ថា ពាក្យបណ្ដឹងសាមញ្ញបានបែងចែកចេញជា ២ (ពីរ) ប្រភេទ គឺ បណ្ដឹងទាមទារ និងបណ្ដឹងបរិហា។

**–បណ្ដឹងទាមទារ ឬពាក្យប្ដឹង** គឺជាបណ្ដឹងមួយប្រភេទដែលត្រូវបានធ្វើឡើងដោយបុគ្គលគ្រប់រូបដែលបានប្រកាសថាខ្លួន គឺជាជនរងគ្រោះនៃបទល្មើស ហើយបានដាក់ពាក្យប្ដឹងទៅអង្គការអយ្យការដោយផ្ទាល់។ **ឧទាហរណ៍៖** លោក **ក** បានប្ដឹងទៅស្ថាប័នអយ្យការថា លោក **ខ** បានប្រព្រឹត្តអំពើហិង្សាដោយចេតនាមកលើខ្លួន ដែលការប្ដឹងនេះក្នុងគោលបំណងទាមទារនូវសំណងការខូចខាតដែល លោក **ខ** បានធ្វើមកលើខ្លួន។ ក្នុងករណីនេះ បណ្ដឹងដែលបានធ្វើឡើងដោយលោក **ក** គឺជាបណ្ដឹងទាមទារ។

**–បណ្ដឹងបរិហារ** គឺជាបណ្ដឹងមួយប្រភេទដែលធ្វើឡើងដោយបុគ្គលផ្សេង ក្រៅពីជនរងគ្រោះ ដែលក្នុងគោលបំណងរាយការណ៍ប្រាប់អាជ្ញាធរមានសមត្ថកិច្ច (មន្ត្រីនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថជាដើម) អំពីសកម្មភាពណាមួយដែលខ្លួនបានឃើញ ហើយច្បាប់បានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌ ដោយមិនមានគោលបំណងក្នុងការទទួលបាននូវសំណងរដ្ឋប្បវេណីត្រឡប់មកវិញឡើយ ដូចនឹងបណ្ដឹងទាមទារផងដែរ។ **ឧទាហរណ៍៖** លោក **ក** បានប្ដឹងទៅអាជ្ញាធរមានសមត្ថកិច្ចថាលោក **ខ** បានធ្វើសកម្មភាពលួចកាបូប និងទូរស័ព្ទរបស់លោក **គ** ដែលការប្ដឹងនេះលោក **ក** មិនមានគោលបំណងទាមទារសំណងការខូចខាតនោះទេ។ ក្នុងករណីផងដែរ ការប្ដឹងរបស់លោក **ក** ជាពាក្យបណ្ដឹងបរិហា។

**២. ការបើកការស៊ើបសួរចំពោះពាក្យបណ្ដឹងដែលមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី**

នៅក្នុងចំណុចនេះ ជាទូទៅអ្នកដែលធ្វើបណ្ដឹងនេះ គឺជាជនរងគ្រោះដែលបានទទួលរងនូវព្យសនកម្មនៃបទល្មើសព្រហ្មទណ្ឌ ដែលតែងតែដាក់ពាក្យបណ្ដឹងទៅកាន់អាជ្ញាធរដែលមានសមត្ថកិច្ច ដើម្បីទទួលបាននូវសំណងរដ្ឋប្បវេណី និងយុត្តិធម៌ត្រឡប់មកវិញ។ ដូច្នេះក្រៅពីការបើកការស៊ើបសួរតាមរយៈពាក្យបណ្ដឹងសាមញ្ញនៅមាននីតិវិធីមួយទៀតដែលច្បាប់បានទទួលស្គាល់នោះគឺ "**ការដាក់បណ្ដឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ ឬពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ**"។[24] នៅពេលដែលជនរងគ្រោះយល់ឃើញថាខ្លួនបានបាត់បង់ផលប្រយោជន៍ ឬទទួលរងនូវភាពអយុត្តិធម៌ ក្នុងករណីដែលព្រះរាជអាជ្ញាបានតម្កល់រឿងទុកឥតចាត់ការនោះ ជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលា។ ការធ្វើបែបនេះ គឺច្បាប់បានផ្ដល់នូវអាទិភាពមួយដល់ជនរងគ្រោះ ដែលអាចធ្វើឱ្យបណ្ដឹងអាជ្ញាមានចលនាឡើងវិញ។ ការប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋ

[24] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥

ប្បវេណី ច្បាប់មិនបានកំណត់អំពីទម្រង់ណាមួយឡើយ។[25] ប៉ុន្តែប្រសិនបើជនរងគ្រោះតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដោយបានធ្វើឡើងជាលិខិតលាយលក្ខណ៍អក្សរ លិខិតនោះត្រូវបានភ្ជាប់ជាមួយនឹងសំណុំរឿង ប៉ុន្តែប្រសិនបើធ្វើឡើងដោយផ្ទាល់មាត់វិញ ចៅក្រមស៊ើបសួរត្រូវធ្វើជាកំណត់ហេតុ ហើយចៅក្រមស៊ើបសួរត្រូវជូនដំណឹងជូនព្រះរាជអាជ្ញា និងជនជាប់ចោទ។[26]

បន្ទាប់ពី ចៅក្រមស៊ើបសួរបានយល់ព្រមទទួលនូវពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរួចមក ចំណាត់ការបន្ទាប់របស់ចៅក្រមស៊ើបសួរគឺ ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា **(ក)** ការបង្គាប់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការបង់ប្រាក់តម្កល់ទុក **(ខ)** ប៉ុន្តែប្រសិនបើតុលាការរកឃើញថាបណ្ដឹងត្រូវបានធ្វើឡើងដោយមានការបំពាន ឬបណ្ដឹងនោះបានអូសបន្លាយពេលវេលានីតិវិធី នោះនឹងមានការដាក់ទណ្ឌកម្មចំពោះដើមបណ្ដឹងរដ្ឋប្បវេណីដែលបានកំណត់ទៅតាមច្បាប់ **(គ)**។

### ២.១. ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា

បន្ទាប់ពី ចៅក្រមស៊ើបសួរទទួលបាននូវពាក្យបណ្ដឹងអំពីការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះ ចៅក្រមស៊ើបសួរនឹងត្រូវការកត់សំគាល់សំណុំរឿងនោះជាលាយលក្ខណ៍អក្សរដោយដីកា រួចបញ្ជូនពាក្យបណ្ដឹងនេះទៅកាន់ព្រះរាជអាជ្ញា។[27]

ក្រោយពីបានឃើញពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវធ្វើបណ្ដឹងទៅចៅក្រមស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះដូចដែលបានរៀបរាប់ខាងលើ គឺអាចបើកប្រឆាំងនឹងអញ្ញាត្រជន ហើយទោះបីជាមានការចង្អុលបង្ហាញទៅលើបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ។ យ៉ាងណាមិញ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរមិនឱ្យស៊ើបសួរបាន ក្នុងករណីដែលបណ្ដឹងអាជ្ញានោះត្រូវបានផុតរលត់ដោយមូលហេតុណាមួយដូចដែលមានចែងក្នុងមាត្រា ៧ និង៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ឬប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។ ក្នុងករណីដែល ចៅក្រមស៊ើបសួរសម្រេចមិនបើកការស៊ើបសួរតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវចេញនូវដីកាសម្រេចដោយបញ្ជាក់អំពីសំអាងហេតុ ដែលត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី។[28] ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរសម្រេចបើកការស៊ើបសួរវិញ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេច

[25] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣៧ កថាខណ្ឌទី២

[26] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣៧ កថាខណ្ឌទី៣ និងទី៥

[27] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣៩ កថាខណ្ឌទី១

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣៩ កថាខណ្ឌទី៤

ដោយបញ្ជាក់ពីសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ព្រះរាជអាជ្ញា។[29] ចំពោះការសម្រេចឱ្យបើកការស៊ើបសួរចំពោះពាក្យបណ្ដឹងដែលមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីបង់ប្រាក់តម្កល់ទុកសម្រាប់ដំណើរការនីតិវិធីនៃការបើកការស៊ើបសួរ។

### ២.២. ការបង់ប្រាក់តម្កល់ទុក

នៅពេលដែលចៅក្រមស៊ើបសួរសម្រេចធ្វើការស៊ើបសួរនោះ ដែលតម្រូវឱ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការតម្កល់ប្រាក់ទុក ដើម្បីដំណើរការនីតិវិធីទៅមុខបន្តទៀតបាន។ ចំពោះប្រាក់តម្កល់ដែលទទួលបានពីការបង់ប្រាក់របស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺគេបានបង្កើតនូវគណនីពិសេសនៅក្នុងធនាគារ ឬត្រូវបានរក្សាទុកនៅក្នុងកន្លែងដែលមានការធានាសុវត្ថិភាពយ៉ាងម៉ត់ចត់។ ចំពោះការជ្រើសរើសទីកន្លែងតម្កល់ប្រាក់ គឺត្រូវមានការយល់ព្រមពីប្រធានតុលាការ និងព្រះរាជអាជ្ញា។ ចំពោះការបង់ប្រាក់នេះ គឺចៅក្រមស៊ើបសួរបានកំណត់រយៈពេលទៅកាន់អ្នកប្ដឹងដើម្បីបង់ប្រាក់ធានាដល់កិច្ចនីតិវិធី។ ប៉ុន្តែការបង់ប្រាក់តម្កល់ទុកមិនមែនជាលក្ខខណ្ឌដាច់ខាតដែលតម្រូវឱ្យអ្នកប្ដឹងដែលជាដើមបណ្ដឹងរដ្ឋប្បវេណីបង់នោះទេ ព្រោះគេនឹងធ្វើការពិចារណាទៅលើធនធានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ បើសិនគេមើលទៅលើធនធាននៃដើមបណ្ដឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចមើលឃើញជាមុននោះ ចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ដែលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង់ ព្រមទាំងកំណត់រយៈពេលដែលត្រូវឱ្យបង់ប្រាក់។[30] ប្រសិនបើគេសង្កេតឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណីពុំមានលទ្ធភាពក្នុងការបង់ប្រាក់តម្កល់ទុកទេនោះ ចៅក្រមស៊ើបសួរអាចសម្រេចលើកលែងមិនឱ្យបង់ប្រាក់បាន ហើយដីកាសម្រេចនេះត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីឱ្យបានដឹង។[31] ក្នុងករណីដែលដើមបណ្ដឹងមានលទ្ធភាពបង់ប្រាក់តម្កល់ ប៉ុន្តែមិនបានបង់ទាន់ពេលដែលបានកំណត់ដោយចៅក្រមស៊ើបសួរនោះ ចៅក្រមស៊ើបសួរនឹងប្រកាសពីការមិនអាចបើកកិច្ចនីតិវិធីបើកការស៊ើបសួរបានទេ។ យ៉ាងណាមិញ ប្រសិនបើបានបង់នូវប្រាក់តម្កល់រួចរាល់ហើយ ដើមបណ្ដឹងរដ្ឋប្បវេណីនឹងទទួលបាននូវបង្កាន់ដៃដែលមានចុះហត្ថលេខាដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី។ នៅពេលនីតិវិធីនៃការបើកការស៊ើបសួរនេះត្រូវបានបញ្ចប់ ប្រាក់តម្កល់ទុកនឹងត្រូវបង្វិលទៅឱ្យសាមីខ្លួន ឬដើមបណ្ដឹងរដ្ឋប្បវេណីវិញ ប៉ុន្តែលើកលែងតែក្នុងករណីដែលកិច្ចនីតិវិធីនៃការស៊ើបសួរនេះ ដែលមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានបិទដោយដីកាលើកលែងការចោទប្រកាន់ ហើយប្រសិនបើក្នុងករណីដែលចៅក្រមស៊ើបសួរយល់ឃើញថា នីតិវិធីនេះត្រូវបានធ្វើឡើងដោយការរំលោភបំពាន ឬដោយការអូសបន្លាយពេលវេលានោះ ចៅក្រមស៊ើបសួរអាចសម្រេចតាម

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣៩ កថាខណ្ឌទី៥

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៤០ កថាខណ្ឌទី ១

[31] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៤០ កថាខណ្ឌទី២

ដីកាសម្រេចឱ្យដើមបណ្តឹងរដ្ឋប្បវេណីបង់ប្រាក់ពិន័យរដ្ឋប្បវេណី ដែលប្រាក់ពិន័យនេះមិនអាចលើសពីប្រាក់តម្កល់ទុកទេ ហើយក៏ត្រូវជូនដំណឹងជាបន្ទាន់អំពីដីកានេះទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។[32] ការជូនដំណឹងនេះ គឺជាការទុកពេលវេលាដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលបាននូវសិទ្ធិ ដើម្បីធ្វើបណ្តឹងទៅកាន់សភាស៊ើបសួររបស់សាលាឧទ្ធរណ៍ចំពោះដីកាសម្រេចនោះ។[33]

### ២.៣. ទណ្ឌកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ការដាក់ពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរនេះ គឺជាផលប្រយោជន៍មួយរបស់ជនរងគ្រោះ ដើម្បីទាមទារនូវសំណងជម្ងឺចិត្ត និងសំណងនៃការខូចខាតចំពោះព្យសនកម្មដែលខ្លួនបានទទួលរងពីបទល្មើស។ លើសពីនេះទៅទៀត វិស័យយុត្តិធម៌នឹងមានភាពសុក្រឹត្យនៅពេលដែលការទាមទារទទួលបាននូវភាពយុត្តិធម៌ផង។ ផ្ទុយទៅវិញ កាលណាដែលចៅក្រមស៊ើបសួរបានបើកការស៊ើបសួរបន្ទាប់ពីបានពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយការបើកការស៊ើបសួរនេះត្រូវបានបិទទៅវិញដោយដីកាសម្រេចលើកលែងការចោទប្រកាន់ចូលជាស្ថាពរទៀតនោះ បុគ្គលដែលមានឈ្មោះនៅក្នុងបណ្តឹង អាចប្តឹងសុំការជួសជុលសំណងពីអ្នកដែលប្តឹងខ្លួន ប្រសិនបើកិច្ចនីតិវិធីធ្វើឡើងដោយរំលោភបំពាន ឬដោយអូសបន្លាយពេលវេលា។ ចំពោះពាក្យសុំការជួសជុលនេះ ត្រូវបានដាក់ជូនតុលាការជាន់ដំបូងដែលរឿងត្រូវបានស៊ើបសួរ ហើយតុលាការអាចស្នើសុំឱ្យបញ្ជូនសំណុំរឿងមកពិនិត្យ។ នៅត្រង់ចំណុចនេះបានសេចក្តីថា នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងទាមទារនូវអ្វីមួយ ប៉ុន្តែតុលាការបានស្វែងរកតាមការទាមទាររួចរាល់ហើយនៅតែមិនឃើញទៀតនោះ ដើមបណ្តឹងរដ្ឋប្បវេណីអាចនឹងត្រូវផ្តន្ទាទោសតាមផ្លូវតុលាការ។

### ៣. ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

នៅក្នុងនីតិវិធីនៃការបើកការស៊ើបសួរ ត្រូវតែមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលដីកានេះមានទម្រង់ដែលបានកំណត់តាមច្បាប់ដែលចាំបាច់ត្រូវគោរពតាម បើពុំនោះទេនឹងត្រូវចាត់ទុកថាមោឃៈ ប្រសិនបើមិនគោរពតាមទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចំពោះទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវបានកំណត់នៅក្នុងមាត្រា៤៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីរួមមាន៖

– សេចក្តីសង្ខេបនៃអង្គហេតុ

– ការកំណត់ឈ្មោះបទល្មើស

– ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង

[32] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៤១

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៦៨

– ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

គួរបញ្ជាក់ដែរថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាជាចាំបាច់។[34] ការចុះកាលបរិច្ឆេទនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ គឺដើម្បីជាប្រយោជន៍ក្នុងការផ្ទៀងផ្ទាត់ថា បណ្ដឹងអាជ្ញានៅមិនទាន់ផុតរលត់នៅឡើយនោះទេ ហើយចៅក្រមស៊ើបសួរក៏មិនទាន់បានធ្វើការស៊ើបសួរនៅមុនពេលទទួលពាក្យបណ្ដឹង។ ចំពោះការចុះហត្ថលេខាវិញ គឺដើម្បីបង្ហាញពីឆន្ទៈរបស់ចៅក្រមស៊ើបពីការបើកការស៊ើបសួរក្នុងការចោទប្រកាន់។ ប្រសិនបើទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមិនបានបំពេញគ្រប់លក្ខខណ្ឌ នោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះនឹងត្រូវចាត់ទុកជាមោឃៈ។[35]

### ៤. អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

បន្ទាប់ពីព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ ដោយចេញនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួររួចហើយ នោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះនឹងលេចឡើងនូវអានុភាពពីរយ៉ាងគឺ ការផុតរលត់អាជ្ញាយុកាលនៃបទល្មើស (៤.១) និង ការកំណត់ពីវិសាលភាពនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ (៤.២)។

#### ៤.១. ការផុតរលត់អាជ្ញាយុកាលនៃបទល្មើស

ជាទូទៅ ចិរវេលានៃបទល្មើសព្រហ្មទណ្ឌត្រូវបានគិតច្បាប់ពីពេលដែលមានបទល្មើសកើតមានឡើង ប៉ុន្តែចិរវេលានៃបទល្មើសនេះក៏ត្រូវរលត់ទៅវិញដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរទៅតាមចំណាត់ថ្នាក់នៃបទល្មើស។[36] យោងតាមច្បាប់ចំណាត់ថ្នាក់នៃបទល្មើសបែងចែកជាបី គឺបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។ ចំពោះបទឧក្រិដ្ឋ ចិរវេលានៃអាជ្ញាយុកាល ១៥ (ដប់ប្រាំ) ឆ្នាំដោយរាប់ចាប់ពីបទល្មើសបានចាប់ផ្តើមប្រព្រឹត្តិ បទមជ្ឈិមមានចិរវេលានៃអាជ្ញាយុកាល ៥ (ប្រាំ) ឆ្នាំដោយរាប់ចាប់ពីបទល្មើសបានចាប់ផ្តើមប្រព្រឹត្តិ និងចំពោះបទលហុវិញ មានចិរវេលានៃអាជ្ញាយុកាល ១ (មួយ) ឆ្នាំដោយរាប់ចាប់ពីបទល្មើសបានចាប់ផ្តើមប្រព្រឹត្តិ។[37] ប៉ុន្តែចំពោះបទឧក្រិដ្ឋដូចដែលមានចែងក្នុងមាត្រា៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌជាអញ្ញត្រកម្មដែលមិនអាចផុតរលត់ពីអាជ្ញាយុកាលនៃបទល្មើស ដែលបទល្មើសទាំងនោះរួមមាន បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម។[38] មានន័យថាអាជ្ញាយុកាលនៃបទល្មើសព្រហ្មទណ្ឌត្រូវបានរលត់ នៅពេលដែលព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ ដោយជ្រើសរើសយកនីតិវិធីណាមួយ ដូចដែលមានចែងក្នុងមាត្រា

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៤

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៤

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១១

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១០

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៩

៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឬចំពោះបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។

### ៤.២. ការកំណត់ពីវិសាលភាពនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ

ការស៊ើបសួរ ត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលចេញដោយព្រះរាជអាជ្ញាទៅចៅក្រមស៊ើបសួរ ដើម្បីប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ដែលមានចង្អុលបង្ហាញឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬប្រឆាំងនឹងអញ្ញាតជន ដែលជាជនមិនស្គាល់អត្តសញ្ញាណជាដើម។[39] ចៅក្រមស៊ើបសួរ មិនអាចបើកការស៊ើបសួរ ឬបំពេញកិច្ចណាមួយដោយមិនបានទទួលនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញាបាននោះទេ មានន័យថាប្រសិនបើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នោះក៏គ្មានចៅក្រមស៊ើបសួរផងដែរ។ ចំពោះការស៊ើបសួរ គឺចៅក្រមស៊ើបសួរមានសមត្ថកិច្ចស្រាវជ្រាវបានតែចំពោះអង្គហេតុដែលចង្អុលបង្ហាញ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ។[40] ម្យ៉ាងវិញទៀត នៅក្នុងករណីដែលចៅក្រមស៊ើបសួររកឃើញតម្រុយ ឬលេចឡើងនូវអង្គហេតុថ្មី ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីអង្គហេតុនោះទៅព្រះរាជអាជ្ញា។ ចំពោះអង្គហេតុថ្មីនេះ ព្រះរាជអាជ្ញាអាចចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទៅចៅក្រមស៊ើបសួរ ដើម្បីធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះ ប៉ុន្តែប្រសិនបើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញានោះទេ ចៅក្រមស៊ើបសួរមិនអាចធ្វើការស៊ើបសួរទៅលើអង្គហេតុថ្មីបាននោះទេ។[41] ប៉ុន្តែមានអញ្ញាត្រកម្ម នៅពេលដែលអង្គហេតុថ្មីនោះគ្រាន់តែជាស្ថានទម្ងន់ទោសទៅលើអង្គហេតុចាស់ដែលមានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូងពីព្រះរាជអាជ្ញា នោះការស៊ើបសួរលើអង្គហេតុថ្មីនេះមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញាទេ។[42] ដោយឡែកចៅក្រមស៊ើបសួរក៏មានអំណាចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការពិនិត្យ ចំពោះគ្រប់បុគ្គលណាដែលបានចង្អុលបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬមានតម្រុយច្បាស់លាស់ ហើយមានលក្ខណៈស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថាបានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលឈ្មោះបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ ហើយចំពោះបុគ្គលដែលត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យមានឋានៈជាចារី ជាអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត។[43] **ឧទាហរណ៍បញ្ជាក់៖** នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាបាន

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២៤

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២៥

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២៥

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២៥

[43] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២៦

បញ្ជូនមកនោះ គឺជាអង្គហេតុចោទប្រកាន់ពីបទវំលោភសេពសន្ថវៈ ហើយនៅពេលដែលចៅក្រមស៊ើបសួរចាប់ផ្តើមកិច្ចស៊ើបសួរ ស្រាប់តែលេចឡើងនូវអង្គហេតុផ្សេងទៀត ដែលមានទាំងអំពើលួចនៅក្នុងសំណុំរឿងនេះផង ដែលនោះជាអង្គហេតុថ្មី ខុសពីខ្លឹមសារនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរតែចំពោះអង្គហេតុដែលទាក់ទងនឹងបទរំលោភសេពសន្ថវៈ ដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ ប្រសិនបើអង្គហេតុថ្មីនោះលេចឡើងជាស្ថានទម្ងន់ទោសនៅក្នុងបទចោទខាងលើវិញ ចៅក្រមស៊ើបសួរអាចស៊ើបសួរបានដោយមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញា។ ដោយឡែក ប្រសិនបើអង្គហេតុថ្មីនោះមានខុសប្លែកពីអង្គហេតុក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចៅក្រមស៊ើបសួរអាចជូនព័ត៌មានភ្លាមទៅកាន់ព្រះរាជអាជ្ញា រួចព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទៅលើអង្គហេតុថ្មីនេះ ទើបចៅក្រមស៊ើបសួរអាចស៊ើបសួរលើអង្គហេតុថ្មីនោះបាន។

**កថាខណ្ឌទី៣៖ ការបិទការស៊ើបសួរ**

នៅពេលដែលចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរត្រូវបានបញ្ចប់ ចៅក្រមស៊ើបសូវត្រូវជូនដំណឹងនេះទៅកាន់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី។ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យក្នុងរយៈពេល ២ (ពីរ) ថ្ងៃក្រោយពីកិច្ចនីតិវិធីស៊ើបសួរបានបញ្ចប់។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើការស៊ើបសួរជាថ្មីទៀតនោះ ព្រះរាជអាជ្ញាត្រូវសុំទៅចៅក្រមស៊ើបសួរឱ្យធ្វើកិច្ចស៊ើបសួរណាមួយដែលព្រះរាជអាជ្ញាយល់ឃើញថាមានប្រយោជន៍។[44] ក្នុងករណីដែលចៅក្រមស៊ើបសួរបានបដិសេធនឹងសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវធ្វើដីកាបដិសេធនេះក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃដោយមានភ្ជាប់ជាមួយនឹងសំអាងហេតុ ហើយត្រូវជូនដំណឹងទៅកាន់ព្រះរាជអាជ្ញាក្នុងចិរវេលាឆាប់បំផុត។ ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនេះទេ ព្រះរាជអាជ្ញាអាចប្តឹងទៅកាន់សភាស៊ើបសួរផ្ទាល់ឱ្យសម្រេចជំនួសនឹងចៅក្រមស៊ើបសួរ។[45] ក្រោយពីពិនិត្យសំណុំរឿងរួចព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានជាស្ថាពរភ្ជាប់ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃប្រសិនបើជនត្រូវចោទត្រូវបានឃុំខ្លួន និង ១ (មួយ) ខែក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំដែលចិរវេលានេះត្រូវគិតជាមួយនឹងថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង។ ម្យ៉ាងវិញទៀត ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចនឹងចៅក្រមស៊ើបសួរវិញ ការស៊ើបសួរត្រូវបានបញ្ចប់ដោយព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋាន

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣២ កថាខណ្ឌទី១

[45] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣២

ស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ព្រះរាជអាជ្ញាក៏មានសិទ្ធិប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬលើកលែងការចោទប្រកាន់បាន។[46]

ក្រោយពីព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានស្ថាពររួចមក ដោយចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួរមានលក្ខណៈពេញលេញហើយ ចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយបិទការស៊ើបសួរ ហើយក្នុងដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់។[47] ប្រសិនបើចៅក្រមស៊ើបសួរចេញដីកាបញ្ជូនទៅតុលាការជំនុំជម្រះ កាលណាចៅក្រមស៊ើបសួរយល់ឃើញថាអំពើនោះ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ហើយក្នុងដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ ក៏ដូចជាឈ្មោះរបស់បទល្មើសតាមច្បាប់។ ផ្ទុយទៅវិញ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចចេញដីកាលើកលែងការចោទប្រកាន់ មានមូលហេតុ ៣ យ៉ាងគឺ ទី១ អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ទី២ ជនដែលប្រព្រឹត្តអំពើនោះនៅតែមិនស្គាល់អត្តសញ្ញាណ និងទី៣ គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ដែលនាំឱ្យចៅក្រមស៊ើបសួរចេញនូវដីកាដំណោះស្រាយបិទការស៊ើបសួរ។[48] ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុអមជាមួយជានិច្ច ហើយចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ច គោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញានោះទេ អាចនិយាយបានថាការចេញដីកាដំណោះស្រាយជាសិទ្ធិឯករាជ្យ របស់ចៅក្រមស៊ើបសួរជាអ្នកសម្រេចក្នុងការបិទការស៊ើបសួរ។[49] ចំពោះដីកាដំណោះស្រាយនេះត្រូវមានការជូនដំណឹងទៅកាន់ព្រះរាជអាជ្ញា ក៏ដូចជាជនត្រូវចោទនិងដើមបណ្តឹងរដ្ឋប្បវេណីក្នុងរយៈពេលដ៏ខ្លីបំផុតផងដែរ។[50]

គួរបញ្ជាក់ផងដែរថា កាលណាកិច្ចស៊ើបសួរមិនបានគោរពតាមវិធាន និងទម្រង់ការសំខាន់ណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដែលត្រូវបានរំលោភបំពាន ហើយច្បាប់បានកំណត់ជាដាច់ខាតនោះទេ កិច្ចស៊ើបសួរនោះនឹងត្រូវមោឃភាព។[51]

### ផ្នែកទី២៖ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាជម្រើសនៃការចោទប្រកាន់មួយទៀតដែលព្រះរាជអាជ្ញាបញ្ជាដល់ជនជាប់ចោទទៅជំនុំជម្រះដោយផ្ទាល់នៅចំពោះមុខតុលាការជាន់ដំបូង តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះ

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៤៦ កថាខណ្ឌទី៥

[47] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៤៧ កថាខណ្ឌទី១

[48] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៤៧ កថាខណ្ឌទី៣

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៤៧ កថាខណ្ឌទី៤

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៤៧

[51] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៥២

ផ្ទាល់ដែលសម្រេចពីរឿងព្រហ្មទណ្ឌ[52] ដោយពុំមានឆ្លងកាត់នីតិវិធីនៃការបើកការស៊ើបសួរ មានន័យថាប្រសិនបើព្រះរាជអាជ្ញាជ្រើសរើសនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ហើយ គឺព្រះរាជអាជ្ញាមិនប្រើនីតិវិធីនៃការបើកការស៊ើបសួរ ឬនីតិវិធីនៃការបង្ហាញខ្លួនភ្លាមនោះទេ។ ការដែលព្រះរាជអាជ្ញាជ្រើសរើសនីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺមានគោលបំណងធានាសិទ្ធិរបស់ជនល្មើស ក្នុងការទទួលបាននូវការជំនុំជម្រះរបស់តុលាការ ដោយទាមទារឱ្យមានការធ្វើការចោទប្រកាន់បទល្មើស និងបញ្ជូនអង្គហេតុទៅយុត្តាធិការជំនុំជម្រះតែម្តង។ ចំពោះនីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺមានភាពឆាប់រហ័សដោយសារតែការចោទប្រកាន់នេះត្រូវបានផ្ទេរសមត្ថកិច្ចរបស់អង្គការអយ្យការទៅចៅក្រមជំនុំជម្រះដើម្បីធ្វើការជំនុំជម្រះតែម្តង។ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់អាចប្រព្រឹត្តទៅបាន គឺទាមទារឱ្យគោរពតាមលក្ខខណ្ឌមួយចំនួន ហើយក៏ត្រូវអនុវត្តឱ្យស្របទៅតាមនីតិវិធីមួយជាក់លាក់ ដែលនីតិវិធីនេះត្រូវធ្វើឡើងតាមទម្រង់ការនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដើម្បីឱ្យនីតិវិធីនេះមានអានុភាពទៅដល់ចំណាត់ការយុត្តាធិការជំនុំជម្រះផងដែរ។

**កថាខណ្ឌទី១៖ លក្ខខណ្ឌនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់**

មុននឹងឈានដល់ការសម្រេចចោទប្រកាន់ តាមនីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ចាំបាច់ត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួន ដែលលក្ខខណ្ឌនោះគឺសំដៅដល់លក្ខខណ្ឌនៃប្រភេទនៃល្មើស **(ចំណុចទី១)** និងសារតាររបស់ជនរងគ្រោះ **(ចំណុចទី២)**។

**១. ប្រភេទនៃបទល្មើស**

នៅក្នុងនីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺគេអាចធ្វើឡើងបានតែចំពោះបទមជ្ឈិម និងបទលហុនោះទេ ដោយសារតែនីតិវិធីនេះមានភាពឆាប់រហ័ស ទើបគេអនុវត្តតែចំពោះប្រភេទបទល្មើសទាំងពីរនេះ ចំពោះបទឧក្រិដ្ឋ គឺគេមិនអាចប្រើនីតិវិធីនេះបានទេដោយសារតែបទឧក្រិដ្ឋមានភាពស្មុគស្មាញ និងត្រូវអូសបន្លាយនីតិវិធីវែង។

**១.១. ចំពោះបទល្មើសជាបទលហុ**

បទលហុ សំដៅដល់បទល្មើសទាំងឡាយណាដែលអតិបរិមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះមានរយៈពេលក្រោម ឬស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ ហើយត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ដែលច្បាប់បានកំណត់ផងដែរ។[53] នៅពេលដែលអង្គហេតុបង្កើតបានជាបទលហុ ព្រះរាជអាជ្ញាមិនអាចជ្រើសរើសនីតិវិធីផ្សេងក្រៅពីនីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់នោះទេ។[54] ចំពោះបទលហុនេះ មិនអាចប្រើនីតិវិធីដូចជាការបើកការស៊ើបសួរ

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៥៦ កថាខណ្ឌទី ១

[53] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៤៨

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៥

ឬការបង្ហាញខ្លួនភ្លាមបាននោះទេ ដោយសារតែប្រសិនបើប្រើនីតិវិធីទាំងពីរនេះ វានឹងនាំឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិសេរីភាពរបស់ជនត្រូវចោទ ដែលចំពោះនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ឬនីតិវិធីការបើកការស៊ើបសួរត្រូវតែមានការឃុំហួតដល់ការបង្ហាញខ្លួននៅចំពោះមុខតុលាការជំនុំជម្រះ។

**១.២. ចំពោះបទល្មើសជាបទមជ្ឈិម**

បទមជ្ឈិម គឺជាបទល្មើសទាំងឡាយណាដែលមានអតិបរិមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះមានរយៈពេលលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ ហើយត្រូវបន្ថែមនឹងទោសពិន័យជាប្រាក់ដែលកំណត់ទៅតាមច្បាប់។[55] ក្នុងករណីបទមជ្ឈិមនេះ ព្រះរាជអាជ្ញាក៏អាចជ្រើសរើសនីតិវិធីនៃការបើកការស៊ើបសួរ ឬនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ឬក៏បង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅចំពោះមុខតុលាការជាន់ដំបូងបានផងដែរ ពីព្រោះអំពើល្មើសក្នុងបទមជ្ឈិមមួយចំនួនបានបំពេញនូវលក្ខខណ្ឌនៃនីតិវិធីទាំងនេះ ក៏ដូចជាបទមជ្ឈិមមួយចំនួនមានភាពស្រាល ងាយស្រួលក្នុងការប្រមូលភស្តុតាងជាដើម ដែលតម្រូវឱ្យព្រះរាជអាជ្ញាជ្រើសរើសយកនីតិវិធីនៃការបង្ហាញខ្លួនភ្លាមនេះ។

**២. សាចតារបស់ជនល្មើស**

នៅក្នុងនីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ មិនត្រឹមតែកំណត់អំពីប្រភេទនៃបទល្មើសនោះទេ ប៉ុន្តែប្រសិនបើមិនស្គាល់អត្តសញ្ញាណរបស់ជនល្មើសនោះទេ កិច្ចនីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់មិនអាចប្រព្រឹត្តទៅបាននោះទេ។ ដូច្នេះ នីតិវិធីនៃការបញ្ជូនខ្លួនទៅជំនុំជម្រះផ្ទាល់ទាមទារឱ្យមានការកំណត់យ៉ាងច្បាស់នូវអត្តសញ្ញាណរបស់ជនល្មើសដោយខានមិនបាន ដោយសារតែគោលបំណង គឺមិនត្រឹមតែស្វែងរកអត្ថិភាពនៃបទល្មើសទេ ហើយក៏ត្រូវផ្តន្ទាទោសចំពោះជនល្មើសផងដែរ។

## កថាខណ្ឌទី២៖ នីតិវិធីនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

នីតិវិធីនៃការបញ្ជូនខ្លួនទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីនៃការចោទប្រកាន់មួយដែលមិនឆ្លងកាត់ដំណាក់កាលនៃការស៊ើបសួរទេ ពោលគឺនៅពេលដែលព្រះរាជអាជ្ញាបានទទួលពាក្យបណ្តឹង ហើយបានបំពេញតាមលក្ខខណ្ឌនៃការបញ្ជូនខ្លួនទៅជំនុំជម្រះផ្ទាល់ ព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ភ្លាម ហើយបញ្ជូនសំណុំរឿងទៅកាន់យុត្តាធិការជំនុំជម្រះតាមរយៈដីកាបញ្ជូនរឿងឱ្យទៅជំនុំជម្រះ និងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់សម្រាប់កោះហៅជនជាប់ចោទ ចូលទៅកាន់សវនាការដើម្បីធ្វើការជំនុំជម្រះ។

[55] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៤៧

**១. ថិរវេលានៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

នៅពេលដែលតុលាការបានទទួលបណ្តឹង ដោយការបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ប្រធានតុលាការត្រូវគិតគូរតាមរយៈពេលដែលកំណត់តាមប្បញ្ញត្តិច្បាប់ ដើម្បីកំណត់កាលបរិច្ឆេទបើកសវនាការ ហើយការជូនដំណឹងត្រូវប្រាប់ដោយផ្ទាល់មាត់ដល់ព្រះរាជអាជ្ញា។[56] ចំពោះរយៈពេលដែលត្រូវគោរពរវាង ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ឱ្យដល់ជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវបានកំណត់ដូចតទៅ[57]៖

– ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការជាន់ដំបូង

– ២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ

– ២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា

– ៣ (បី) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត។

យ៉ាងណាមិញ បើយោងតាមមាត្រា ៤៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា ប្រសិនបើការប្រគល់ដីកាពុំបានគោរពតាមរយៈពេលដែលច្បាប់បានកំណត់នោះទេ វានឹងនាំឱ្យមានផលវិបាក ដូច្នេះក្នុងករណីនេះតុលាការមានចំណាត់ការក្នុងករណីដូចតទៅ៖

–ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួនទេ តុលាការពិនិត្យមោឃភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬដីកាកោះហៅឱ្យចូលបង្ហាញខ្លួន។ តុលាការបង្គាប់ឱ្យចេញដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬដីកាកោះហៅបង្គាប់ឱ្យចូលខ្លួនជាថ្មីម្តងទៀត លើកលែងតែបណ្តឹងអាជ្ញាត្រូវបានផុតរលត់។

–ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការ តុលាការអាចពិនិត្យមើលសំណុំរឿង ប្រសិនបើជនជាប់ចោទយល់ព្រមយ៉ាងជាក់លាក់ឱ្យជំនុំជម្រះភ្លាម។ ប្រសិនបើជនជាប់ចោទមិនព្រមឱ្យជំនុំជម្រះភ្លាមទេ តុលាការបង្គាប់ឱ្យលើកសំណុំរឿងនេះទៅជំនុំជម្រះនៅសវនាការពេលក្រោយទៀត។

ម្យ៉ាងវិញទៀត នីតិវិធីនេះនឹងត្រូវបានប្រកាសមោឃភាព កាលណាដែលដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់មានអានុភាពធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជនជាប់ចោទ លើកលែងតែជនជាប់ចោទចូលខ្លួនមកបង្ហាញដោយស្ម័គ្រចិត្ត។[58]

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៩២

[57] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៥៧

[58] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៩២ កថាខណ្ឌទី១

## ២. របៀបនៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ការប្រគល់ដីកា និងចុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ទៅជនជាប់ចោទដោយផ្ទាល់ដៃដោយព្រះរាជអាជ្ញា។[59] ចំពោះដើមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវមានចុះកាលបរិច្ឆេទ ទីកន្លែងកំណើត និងលំនៅឋានរបស់ជនជាប់ចោទ ហើយត្រូវតែមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា។[60] ចំពោះចុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់វិញត្រូវមានចុះនិទ្ទេសពីកាលបរិច្ឆេទ និងទីកន្លែងប្រគល់ដីកានៅលើដើមដីកា ហើយជនជាប់ចោទត្រូវចុះហត្ថលេខានៅលើដើមដីកាផងដែរ។[61]

ក្រៅពីព្រះរាជអាជ្ញាដែលមានសិទ្ធិប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏មានអ្នកផ្សេងទៀតដែលអាចប្រគល់ដីកាដូចគ្នានឹងព្រះរាជអាជ្ញាដែល ហើយបុគ្គលទាំងនោះរួមមាន អាជ្ញាសាលា[62] ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល ដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀត តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។[63] យ៉ាងណាមិញ ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាលដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀត តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលត្រូវបានព្រះរាជអាជ្ញាសុំឱ្យប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏ត្រូវតែគោរពតាមការបញ្ជារបស់ព្រះរាជអាជ្ញាផងដែរ។[64]

ទន្ទឹមនឹងនេះ អាជ្ញាសាលាមិនត្រឹមតែអាចប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បាននោះទេ ក៏ប៉ុន្តែអាជ្ញាសាលាក៏អាចប្រគល់ចុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បានផងដែរ ដោយប្រើគ្រប់មធ្យោបាយ ដើម្បីប្រគល់ដីកានេះឱ្យដោយជនជាប់ចោទផ្ទាល់ដៃ ឬដល់មេឃុំ ឬចៅសង្កាត់។ ក្នុងករណីដែលអាជ្ញាសាលាបានជួបប្រទះជនជាប់ចោទនៅក្នុងផ្ទះ ឬនៅកន្លែងដទៃផ្សេងទៀត អាជ្ញាសាលាត្រូវប្រគល់ចុងដីកាកោះដល់សាមីខ្លួន ដោយចារលើសេចក្តីដើមដីកាថា បានប្រគល់ចុងដីកាដល់ជនជាប់ចោទផ្ទាល់ដៃ និងត្រូវចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់ ព្រមទាំងហត្ថលេខារបស់ជនជាប់ចោទនៅដើមដីកា ហើយដើមដីកាត្រូវបញ្ជូនវិលត្រឡប់ទៅកាន់ព្រះរាជអាជ្ញាវិញភ្លាម។[65]

[59] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៥៨ កថាខណ្ឌទី១
[60] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៥៦ កថាខណ្ឌទី២
[61] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៥៨ កថាខណ្ឌទី២
[62] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៥៩
[63] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៦៣ កថាខណ្ឌទី១
[64] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៦៣ កថាខណ្ឌទី២
[65] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៦០

លើសពីនេះទៅទៀត ប្រសិនបើជនជាប់ចោទអវត្តមានពីលំនៅឋានរបស់ខ្លួន អាជ្ញាសាលាត្រូវប្រគល់ចុងដីកាឱ្យដល់បុគ្គលទាំងឡាយណា ជានីតិជនដែលមានវត្តមាននៅលំនៅឋាននោះ ដោយឱ្យចុះសេចក្តីលើដើមដីកាថា ចុងដីកាត្រូវបានប្រគល់ឱ្យបុគ្គលដែលមានវត្តមាននៅលំនៅឋាន ហើយក៏ត្រូវចុះនិទ្ទេសស្តីពីអត្តសញ្ញាណនៃបុគ្គលនោះ និងកាលបរិច្ឆេទនៃការប្រគល់ដីកា ព្រមជាមួយនឹងការចុះហត្ថលេខារបស់បុគ្គលដែលទទួលដីកា ដោយត្រូវសន្យាថានឹងប្រគល់ដីកានេះដល់ជនជាប់ចោទក្នុងរយៈពេលខ្លីបំផុត ហើយដើមដីកាក៏ត្រូវបង្វិលជូនព្រះរាជអាជ្ញាវិញភ្លាមផងដែរ។[66]

ម្យ៉ាងវិញទៀត អាជ្ញាសាលាអាចប្រគល់ចុងដីកា ឱ្យដល់មេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង នៅក្នុងករណីដូចតទៅ[67]៖

–ជនជាប់ចោទមិនព្រមទទួលដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

–គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទ

–គ្មានបុគ្គលណាម្នាក់ ដែលមានវត្តមាននៅក្នុងលំនៅឋាន របស់ជនជាប់ចោទ យល់ព្រមទទួលដីកាកោះទេ។

នៅពេលដែលអាជ្ញាសាលាបានប្រគល់ចុងដីកាដល់មេឃុំ ឬចៅសង្កាត់ ត្រូវមានចុះនិទ្ទេសនៅលើដើមដីកា អំពីអត្តសញ្ញាណ និងឋានៈរបស់បុគ្គលដែលបានទទួលចុងដីកា ព្រមទាំងកាលបរិច្ឆេទនៃការប្រគល់ដីកា ហើយបុគ្គលដែលទទួលចុងដីកាត្រូវចុះហត្ថលេខារបស់ខ្លួនលើដើមដីកា ព្រមជាមួយនឹងការសន្យាថានឹងប្រគល់ដីកានោះដល់ដៃជនជាប់ចោទក្នុងរយៈពេលដ៏ខ្លីបំផុត ហើយដើមដីកាក៏ត្រូវបង្វិលជូនព្រះរាជអាជ្ញាវិញភ្លាមផងដែរ។[68]

គួរបញ្ជាក់ផងដែរថា ប្រសិនបើជនជាប់ចោទគ្មានលំនៅឋាន ឬទីសំណាក់ ឬក៏រស់នៅក្រៅដែនដីជាតិ ព្រះរាជអាជ្ញាក៏អាចធ្វើការចោទប្រកាន់លើជននោះបាន ហើយកាលបរិច្ឆេទនៃការធ្វើដីកា ត្រូវចាត់ទុកថាជាកាលបរិច្ឆេទនៃការប្រគល់ដីកា។[69]

**កថាខណ្ឌទី៣៖ ទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

ព្រះរាជអាជ្ញាត្រូវធ្វើដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយត្រូវមានទម្រង់ការច្បាស់លាស់ ដើម្បីឱ្យចៅក្រមជំនុំជម្រះយល់ឃើញថា រឿងក្តីដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ពិតជាមានភាពធន់ល្មមនឹង

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៦១

[67] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៦២

[68] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៦២

[69] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៦៤

អាចចោទប្រកាន់បាន។ ទម្រង់នៃដីកាកោះហៅបញ្ជូនខ្លួនទៅជំនុំជម្រះផ្ទាល់នេះ ជាព័ត៌មានសំខាន់សម្រាប់ជនជាប់ចោទយល់អំពីមូលហេតុនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចរបស់ជនជាប់ចោទក្នុងការបង្ហាញខ្លួនតាមកាលកំណត់ក្នុងដីកា។ យោងតាមមាត្រា ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ថា នៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់រួមមានៈ

–អត្តសញ្ញាណនៃជនជាប់ចោទ

–សេចក្តីសង្ខេបនៃអង្គហេតុ

–ឈ្មោះបទល្មើស

–អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស។

នៅក្នុងដីកានេះផង ក៏ត្រូវចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ ហើយត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងមេធាវីឱ្យអមខ្លួនបាន។

**កថាខណ្ឌទី៤៖ អានុភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

បន្ទាប់ពីព្រះរាជអាជ្ញាបានសម្រេចធ្វើការចោទប្រកាន់ ដោយចេញនូវដីកាសន្និដ្ឋានបញ្ជូនរឿងជំនុំជម្រះផ្ទាល់រួចមក នោះដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់នឹងលេចឡើងនូវអានុភាពពីរយ៉ាងគឺ ការផុតរលត់រយៈពេលអាជ្ញាយុកាលនៃបទល្មើស (១) និង វិសាលភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ (២)។

**១. ការផុតរលត់អាជ្ញាយុកាលនៃបទល្មើស**

ជាទូទៅ អាជ្ញាយុកាលត្រូវបានផុតរលត់នៅគ្រប់កិច្ចនៃការចោទប្រកាន់ ឬស៊ើបសួរ។[70] ដូចនេះមានន័យថា ដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជាកិច្ចនៃការចោទប្រកាន់របស់អង្គការអយ្យការ ដែលអាចមានអានុភាពជំរុញឱ្យរលត់អាជ្ញាយុកាលនៃបទល្មើស ឬអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាដែលចាប់រាប់គិតនៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តឡើងមក។ ដូចដែលបានលើកឡើងម្តងរួចមកហើយ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាដីកាដែលព្រះរាជអាជ្ញាបញ្ជាដល់ជនជាប់ចោទឱ្យចូលបង្ហាញខ្លួននៅតុលាការជាន់ដំបូងដែលមានសិទ្ធិសម្រេចរឿងក្តីព្រហ្មទណ្ឌ។[71] ក្នុងករណីនេះ យើងអាចឃើញថា វាជាដំណាក់កាលមួយនៃកិច្ចចោទប្រកាន់របស់តំណាងអយ្យការ ដែលបានផ្ទេរសមត្ថកិច្ចរបស់ខ្លួនពីស្ថាប័នអយ្យការទៅកាន់យុត្តាធិការជំនុំជម្រះក្នុងការចេញសេចក្តីសម្រេច ដោយហេតុថាជនជាប់ចោទត្រូវទៅបង្ហាញខ្លួននៅចំពោះមុខតុលាការជំនុំជម្រះ ក៏ជាហេតុដែលនាំឱ្យមានការរំលងនូវកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ។

[70] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១១

[71] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៥៦

### ២. វិសាលភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវមានការចុះនិទ្ទេស ដែលមានការបង្ហាញពីសេចក្តីសង្ខេបនៃអង្គហេតុ ដែលជាលក្ខខណ្ឌមួយក្នុងចំណោមទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។ ហើយតុលាការអាចសម្រេចសេចក្តីបានតែទៅលើអំពើទាំងឡាយណា ដែលមានបង្ហាញនៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់[72] មានន័យថាតុលាការអាចជំនុំជម្រះបានតែអង្គហេតុទាំងឡាយណា ដែលបានចង្អុលបង្ហាញនៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះតែប៉ុណ្ណោះ តុលាការមិនអាចធ្វើការជំនុំជម្រះលើអង្គហេតុផ្សេងពីដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បានទេ។

គួរបញ្ជាក់ផងដែរថា ព្រះរាជអាជ្ញាធ្វើកិច្ចចោទប្រកាន់ដោយប្រើដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គ្មានអានុភាពបង្ខំឱ្យជនជាប់ចោទចូលសវនាការនោះទេ គឺជនជាប់ចោទមានសេរីភាពចូលទៅបង្ហាញខ្លួនដោយខ្លួនឯងនៅពេលសវនាការ។[73]

## ផ្នែកទី៣៖ ការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

ការចោទប្រកាន់របស់ព្រះរាជអាជ្ញា ក្រៅពីនីតិវិធីនៃការបើកការស៊ើបសួរ និងការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ព្រះរាជអាជ្ញាក៏អាចចោទប្រកាន់តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។ នីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម គឺជាជម្រើសមួយនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ដែលបានបង្គាប់ឱ្យជនជាប់ចោទបង្ហាញខ្លួនភ្លាមនៅតុលាការជំនុំជម្រះដោយផ្ទាល់។ ការបង្ហាញខ្លួនភ្លាមអាចប្រព្រឹត្តទៅបានតាមលក្ខខណ្ឌនៃនីតិវិធីបង្ហាញខ្លួនភ្លាម **(កថាខណ្ឌទី១)** ដែលត្រូវបំពេញ និងគោរពទៅតាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម **(កថាខណ្ឌទី២)** ដែលជាហេតុនាំឱ្យមានអានុភាពនៃការបង្ហាញខ្លួនភ្លាម **(កថាខណ្ឌទី៣)** កើតមានឡើង។

### កថាខណ្ឌទី១៖ លក្ខខណ្ឌនៃនីតិវិធីបង្ហាញខ្លួនភ្លាម

នៅក្នុងនីតិវិធីនៃការបង្ហាញខ្លួនភ្លាមនេះ ជាកិច្ចនីតិវិធីមួយដែលមានភាពឆាប់រហ័ស និងលឿនជាងនីតិវិធីផ្សេងទៀត ដែលវាបានជម្រុញឱ្យដំណើរការនីតិវិធីមិនមានភាពយឺតយ៉ាវ ក៏ចៀសវាងនឹងការកកស្ទះសំណុំរឿងនៅក្នុងស្ថាប័នតុលាការ ក៏ដូចជាជួយសម្រួលដល់វិស័យយុត្តិធម៌ផង។ ការជ្រើសរើសជម្រើសនៃការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមនេះ គឺអនុវត្តន៍តែចំពោះរឿងក្តីដែលមានលក្ខណៈគ្រប់គ្រាន់អាចជំនុំជម្រះបានដែលពុំត្រូវការការស្រាវជ្រាវបន្ថែម ហើយក្នុងគោលបំណងដើម្បីឱ្យចំណេញពេលវេលា ក៏ដូចជាជួយកាត់បន្ថយសំណុំរឿងក្នុងដំណាក់កាលស៊ើបសួរ និងដំណាក់កាលបញ្ជូនទៅជំនុំជម្រះផ្ទាល់ គ្រាន់តែខុសគ្នាត្រង់លក្ខខណ្ឌ។

[72] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៤៨ កថាខណ្ឌទី១

[73] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣០២

### ១. លក្ខខណ្ឌនៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

ព្រះរាជអាជ្ញាអាចជ្រើសរើសយកការចោទប្រកាន់ តាមរយៈនីតិវិធីបង្ហាញខ្លួនភ្លាមនៅចំពោះមុខតុលាការជាន់ដំបូង បានលុះត្រាតែបានបំពេញគ្រប់លក្ខខណ្ឌទាំង ៤ (បួន) ដូចតទៅ[74]៖

–បទល្មើសជាបទល្មើសមជ្ឈិមជាក់ស្តែង ដែលបទល្មើសនេះបានបញ្ជាក់យ៉ាងជាក់ច្បាស់ ដោយយកអត្ថន័យតាមមាត្រា៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) និងមាត្រា៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។ ដោយហេតុក្នុងនីតិវិធីនៃការបង្ហាញខ្លួនភ្លាម កំណត់យកតែ អត្ថន័យតាមនិយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង គឺសំដៅដល់បទល្មើសដែលកំពុងប្រព្រឹត្ត ឬបទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម ឬត្រូវចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងកាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក ជនដែលគេសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រផាប់ចាប់ប្រ-ភីង ឬបុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។[75] មិនតែប៉ុណ្ណោះ ទោះបីមិនស្ថិតក្នុងអត្ថន័យនៃមាត្រា ៨៦ ប៉ុន្តែមាត្រា ៨៨ បានកំណត់អំពីការចាត់ទុកដូចបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ចំពោះគ្រប់បទឧក្រិដ្ឋ ឬមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ។[76]

–បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ (មួយ) ឆ្នាំ និងយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំ ដែលនេះជាចំនួនអតិបរិមានៃទោសដែលត្រូវរងចំពោះបទមជ្ឈិម។

–ជនជាប់ចោទជានីតិជន សំដៅដល់ជនដែលមានអាយុ ១៨ ឆ្នាំឡើងទៅ ដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌបាន។[77] ដូចនេះ យើងមិនអាចអនុវត្តនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមទៅលើអនីតិជនបានទេ ដែលវាហាក់បីដូចជាការរំលោភសិទ្ធិសេរីភាព និងផលប្រយោជន៍របស់អនីតិជនដូចដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ។

–រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន មានន័យថាជារឿងក្តីដែលត្រូវមានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់ក្នុងការដាក់បន្ទុកបានដោយមិនមានមន្ទិលសង្ស័យក្នុងការបញ្ជូនទៅជំនុំជម្រះផ្ទាល់។

[74] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៧
[75] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៨៦
[76] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៨៨
[77] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៣៨

ជារួមមក លក្ខខណ្ឌទាំងបួននេះត្រូវតែអនុវត្តន៍ជាដាច់ខាត នៅពេលដែលព្រះរាជអាជ្ញាជ្រើសរើសកិច្ចនីតិវិធីនេះចោទប្រកាន់លើជនជាប់ចោទ ដែលមិនអាចខ្វះលក្ខខណ្ឌណាមួយបានឡើយ។ ប្រសិនបើខ្វះលក្ខខណ្ឌណាមួយ ជម្រើសនៃការចោទប្រកាន់តាមរយៈនីតិវិធីនៃការបង្ហាញខ្លួនភ្លាមមិនអាចប្រព្រឹត្តទៅបានឡើយ។ បន្ទាប់ពី ព្រះរាជអាជ្ញាមានចំណាត់ការលើគ្រប់លក្ខខណ្ឌហើយ ជំហ៊ានបន្ទាប់គឺជានីតិវិធីនៃការបង្ហាញខ្លួនភ្លាមនៅចំពោះមុខយុត្តាធិកាជំនុំជម្រះ។

### កថាខណ្ឌទី២៖ នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

នៅក្នុងនីតិវិធីនៃការបង្ហាញខ្លួនភ្លាមមានភាពប្លែកពីនីតិវិធីផ្សេង ដែលនីតិវិធីនេះមានភាពល្អិតល្អន់ និងជាក់លាក់ជាងនីតិវីធីមុនៗ។ ចំពោះនីតិវិធីនៃការបង្ហាញខ្លួនភ្លាមនេះបានបែងចែកចេញជា ២ (ពីរ) ដំណាក់កាល គឺ ការបង្ហាញខ្លួនភ្លាមធ្វើនៅចំពោះមុខព្រះរាជអាជ្ញា **(ចំណុចទី១)** និងការបង្ហាញខ្លួនភ្លាមធ្វើនៅចំពោះមុខតុលាការជំនុំជម្រះ **(ចំណុចទី២)**

#### ១. ការបង្ហាញខ្លួនភ្លាមធ្វើនៅចំពោះមុខព្រះរាជអាជ្ញា

ជាបឋម ជនជាប់ចោទត្រូវបានធ្វើការឃាត់ខ្លួនពីមន្ត្រីនគរបាលយុត្តិធម៌ រួចទើបបញ្ជូនខ្លួនទៅកាន់ព្រះរាជអាជ្ញា។[78] នៅពេលដែលរលត់រយៈពេលនៃការឃាត់ខ្លួន ព្រះរាជអាជ្ញានឹងថ្លឹងថ្លែងថាគួរតែដោះលែងឱ្យរួចខ្លួន ឬធ្វើចំណាត់ការនីតិវិធីបន្ត។ ប្រសិនបើព្រះរាជអាជ្ញាសម្រេចជ្រើសរើសនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវ[79]៖

– ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនខ្លួនមក មានន័យថា ដើម្បីកំណត់ឱ្យបាននូវអត្តសញ្ញាណរបស់បុគ្គលនោះដែលបានកត់ត្រានៅក្នុងកំណត់ហេតុដែលបញ្ជូនមកនោះ។

– ឱ្យដំណឹងដល់ជននោះអំពីរឿងរ៉ាវដែលបានចោទប្រកាន់ និងឈ្មោះបទល្មើស

– ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ មានន័យថា ជាការផ្តល់សិទ្ធិសេរីភាពដល់ជនជាប់ចោទក្នុងការអះអាងគ្រប់បែបយ៉ាង ដើម្បីការពារខ្លួន និងលើកយកព័ត៌មានដែលខ្លួនបានដឹងទុកជាប្រយោជន៍ដល់សំណុំរឿង។

– ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម មានន័យថានីតិវិធីនៃការបង្ហាញខ្លួនភ្លាមអាចអនុវត្តបាន លុះត្រាតែចេញកំណត់ហេតុស្តីពីនីតិវិធីនៃការបង្ហាញខ្លួនភ្លាម រួចបញ្ជូនទៅតុលាការជាន់ដំបូង ដើម្បីចាត់តាំងចៅក្រមជំនុំជម្រះនៅពេលបើកសវនាការ។

[78] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១០៣

[79] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៨

ព្រះរាជអាជ្ញាត្រូវប្រាប់ជនជាប់ចោទថា ខ្លួនមានសិទ្ធិសុំពឹងមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈរបស់មេធាវី។ ចំពោះមេធាវីដែលត្រូវបានជ្រើសរើស ឬចាត់តាំងត្រូវទទួលបានដំណឹងភ្លាម និងអាចសុំពិនិត្យសំណុំរឿង និងទាក់ទងនឹងជនជាប់ចោទបាន ដែលត្រូវចុះក្នុងកំណត់ហេតុនូវនិទ្ទេសនៃគ្រប់ទម្រង់ការ ប្រសិនបើមិនបានចុះនិទ្ទេសទេ នោះនីតិវិធីនឹងត្រូវទុកជាមោឃៈ។

**២. ការបង្ហាញខ្លួនភ្លាមធ្វើនៅចំពោះមុខតុលាការជំនុំជម្រះ**

បន្ទាប់មកទៀត តុលាការជាន់ដំបូង ត្រូវទទួលពាក្យបណ្តឹងតាមកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។[80] ចំពោះជនជាប់ចោទវិញ គឺត្រូវបង្ខាំងទុកដោយមានកងកម្លាំងការពារ រហូតដល់សាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ដែលត្រូវបើកសវនាការនៅក្នុងថ្ងៃតែមួយតែម្តង។[81] នៅក្នុងពេលបង្ហាញខ្លួន តុលាការក្រោយពីបានផ្ទៀងផ្ទាត់មើលអត្តសញ្ញាណរបស់ជនជាប់ចោទ និងធ្វើរបាយការណ៍សង្ខេបរឿងរ៉ាវដែលបានចោទប្រកាន់ហើយ តុលាការត្រូវប្រាប់ដល់ជនជាប់ចោទថា សាមីខ្លួនអាចមានរយៈពេលដើម្បីរៀបចំការពារខ្លួន។[82] ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថាមិនទាន់អាចជំនុំជម្រះបានទេនោះ សវនាការនឹងត្រូវលើកទៅពេលក្រោយ ដែលអាចទាមទារឱ្យធ្វើការស៊ើបអង្កេត ឬបើកការស៊ើបសួរឡើងវិញ។[83] ក្នុងករណីនេះតុលាការអាចសម្រេចឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នដោយសាលក្រមដែលមានបញ្ជាក់នូវសំអាងហេតុ និងត្រូវយោងតាមមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបានកំណត់ពីមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ដោយចេញនូវដីកាសម្រេចបង្គាប់ឱ្យឃុំខ្លួន។[84] ចំពោះដីកាសម្រេចបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទត្រូវបញ្ឈប់ដោយពេញច្បាប់ក្នុងរយៈពេល ២ (ពីរ) សប្តាហ៍គិតពីថ្ងៃចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការ ពុំដូច្នេះទេ ប្រសិនបើលើសពីរយៈពេល ២ (ពីរ) សប្តាហ៍ នឹងត្រូវដោះលែងឱ្យជនជាប់ចោទមានសេរីភាពតាមសេចក្តីសម្រេចរបស់តុលាការ។[85] ម្យ៉ាងវិញទៀត ប្រសិនបើតុលាការយល់ឃើញថាមិនបានបំពេញតាមលក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាមទេ ឬដោយសារតែភាពសាំញ៉ាំនៃសំណុំរឿង តម្រូវជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវឱ្យបានកាន់តែស៊ីជម្រៅ ឬកាន់តែច្បាស់បន្ថែម ហើយតុលាការត្រូវបញ្ជូនសំណុំរឿងទៅកាន់ព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ។ ជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួនភ្លាមនៅថ្ងៃនោះតែម្តង នៅចំពោះមុខចៅក្រម

[80] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣០៤ កថាខណ្ឌទី៥

[81] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣០៤ កថាខណ្ឌទី៦

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៨ កថាខណ្ឌទី ៧

[83] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៨ កថាខណ្ឌទី ៨

[84] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៨ កថាខណ្ឌទី ៩

[85] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៨ កថាខណ្ឌទី ១០

ស៊ើបសួរ តាមការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា បើពុំដូច្នោះទេ ជនជាប់ចោទត្រូវតែដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង។[86]

**កថាខណ្ឌទី៣៖ អានុភាពនៃការបង្ហាញខ្លួនភ្លាម**

ការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម គឺជានីតិវិធីដែលស្តែងឡើងដោយការធ្វើកំណត់ហេតុស្តីពីការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា ដែលស្នើឱ្យតុលាការបើកការជំនុំជម្រះ។ ចំពោះអានុភាពនៃនីតិវិធីនៃការបង្ហាញខ្លួនភ្លាមនេះ មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងនីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដែលវាបង្កើតឱ្យមានអានុភាពក្នុងការផុតរលត់អាជ្ញាយុកាលនៃបទល្មើស ក៏ដូចជាការផ្ទេរសមត្ថកិច្ចពីស្ថាប័នអយ្យការទៅយុត្តាធិកាស៊ើបសួរ និងបានកំណត់ពីព្រំដែននៃអំណាចតុលាការផងដែរ។

[86] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៤៨ កថាខណ្ឌទី ១១

## ជំពូកទី៣៖ ការតម្កល់រឿងទុកឥតចាត់ការ

ក្រៅពីការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌ ដែលរួមមាន ការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម[87] ព្រះរាជអាជ្ញាក៏មានឆន្ទានុសិទ្ធិក្នុងការតម្កល់រឿងទុកឥតចាត់ការ[88] ចំពោះបទល្មើសព្រហ្មទណ្ឌណាមួយ។ ការតម្កល់រឿងទុកឥតចាត់ការ មានមូលហេតុជាច្រើនជាអាទិ៍ ដូចជាការរលត់បណ្តឹងអាជ្ញា (មរណភាពនៃជនល្មើស, ការផុតអាជ្ញាយុកាល, ការលើកលែងទោសជាទូទៅ, និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ, អាជ្ញាអស់ជំនុំ, និងមូលហេតុផ្សេងទៀត) លក្ខខណ្ឌនៃអំពើ (ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ, ខ្វះធាតុផ្សំនៃបទល្មើស, អត្ថិភាពនៃបទល្មើស, ព្យសនកម្ម ឬមិនផ្តល់ប្រយោជន៍)។ ម្យ៉ាងទៀតការតម្កល់រឿងទុកឥតចាត់ការនេះ ក៏ត្រូវផ្អែកលើទម្រង់មួយចំនួនដូចជា៖ លក្ខខណ្ឌ អានុភាព នីតិវិធី និងវិធានការដែលជម្រុញឱ្យមានការចោទប្រកាន់ឡើងវិញផងដែរ។

### ផ្នែកទី១៖ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

ក្នុងការតម្កល់រឿងទុកឥតចាត់ការទាមទារឱ្យមាននូវ មូលហេតុ លក្ខខណ្ឌ និងអានុភាពច្បាស់លាស់ ក្នុងការលើកលែងការចោទប្រកាន់នៃបទល្មើសព្រហ្មទណ្ឌណាមួយ។

#### កថាខណ្ឌទី១៖ ការរលត់បណ្តឹងអាជ្ញា

កាលណាបណ្តឹងអាជ្ញាត្រូវបានផុតរលត់ហើយ ការចោទប្រកាន់ខាងព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់។[89] សរបញ្ជាក់យ៉ាងច្បាស់ថា កាលណាមានមូលហេតុណាមួយដែលធ្វើឱ្យបណ្តឹងអាជ្ញាត្រូវបានផុតរលត់ នោះព្រះរាជអាជ្ញាមិនអាចចាប់ផ្តើមធ្វើការចោទប្រកាន់ទៅលើបទល្មើសខាងព្រហ្មទណ្ឌណាមួយទៀតទេ រីឯចំពោះករណីដែលព្រះរាជអាជ្ញាបានសម្រេចចោទប្រកាន់រួចរាល់ហើយ បើទោះបីជាស្ថិតនៅក្នុងដំណាក់កាលណាមួយនៃនីតិវិធីក៏ដោយ ក៏ត្រូវតែបញ្ចប់តាមរយៈដីកាតម្កល់រឿងទុកឥតចាត់ការ ដែលធ្វើឡើងដោយព្រះរាជអាជ្ញា។

មូលហេតុនៃការផុតរលត់បណ្តឹងអាជ្ញារួមមានជាអាទិ៍៖ មរណភាពនៃជនល្មើស ការផុតរលត់អាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និងអាជ្ញាអស់ជំនុំ។[90] លើសពីនេះទៅទៀត ក៏

---

[87] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៣

[88] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤០

[89] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៧ កថាខណ្ឌទី ២

[90] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៧ កថាខណ្ឌទី ១

មានមូលហេតុមួយចំនួនទៀតដែលជាហេតុដែលនាំអោយបណ្តឹងអាជ្ញាត្រូវបានផុតរលត់រួមមាន៖ ការសម្របសម្រួលជាមួយរដ្ឋ ការដកពាក្យបណ្តឹង និងការបង់ប្រាក់ពិន័យ។[91]

• មរណភាពនៃជនល្មើស

មរណភាពនៃជនល្មើស សំដៅដល់មរណភាពនៃបុគ្គលដែលចាត់ទុកជាជនដែលបានប្រព្រឹត្ត ឬជនដែលសង្ស័យថាបានប្រព្រឹត្ត ស្ថិតនៅក្នុងដំណាក់កាលនីតិវិធីណាមួយ ហើយជននោះអាចជាជនត្រូវចោទ ឬជនជាប់ចោទ។ ក្នុងករណីនេះ ជនល្មើសដែលបានទទួលមរណភាពមិនអាចទទួលឋានៈជាប្រធាននៃសិទ្ធិ និងករណីកិច្ចបានទេ។ ដោយផ្អែកតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើផ្ទាល់ខ្លួន។[92] មានន័យថា គ្មាននរណាម្នាក់ទទួលខុសត្រូវព្រហ្មទណ្ឌជំនួសជនល្មើស ឬអ្នកប្រព្រឹត្តបានទេ។ កាលបើជនល្មើសបានទទួលមរណភាពទៅហើយ ដូចនេះពុំមានអ្នកណាម្នាក់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។

លើសពីនេះទៅទៀត ដូចយើងបានដឹងហើយថាទោសព្រហ្មទណ្ឌ គឺមានគោលបំណងដាក់ទណ្ឌកម្មចំពោះជនល្មើស និងសម្រួលអប់រំ កែប្រែ និងធានាថាទណ្ឌិតអាចធ្វើសមាហរណកម្មក្នុងសង្គមវិញបាន។ ក្នុងករណីដែលជនល្មើសបានទទួលមរណភាពទៅហើយ ដូចនេះមិនអាចធ្វើការដាក់ទណ្ឌកម្ម ឬធ្វើការសម្រួលអប់រំកែប្រែ ណាមួយចំពោះជនល្មើសនោះបានឡើយ។

យោងតាមការបកស្រាយខាងលើ មរណភាពនៃជនល្មើស គឺពិតជាមូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ ឬការសម្រេចមិនចោទប្រកាន់ តាមរយៈដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ដែលចេញដោយព្រះរាជអាជ្ញា។

• ការផុតអាជ្ញាយុកាល

អាជ្ញាយុកាលនៃរឿងក្តីព្រហ្មទណ្ឌមាន២គឺ៖ អាជ្ញាយុកាលនៃបទល្មើស[93] និងអាជ្ញាយុកាលនៃទោស[94]។ អាជ្ញាយុកាលនៃបទល្មើស និងអាជ្ញាយុកាលនៃទោស សំដៅដល់អំឡុងពេលដែលច្បាប់បានកំណត់ក្នុងការចោទប្រកាន់ និងការដាក់ទោសនៃបទល្មើសព្រហ្មទណ្ឌណាមួយ។ អាជ្ញាយុកាលនៃបទល្មើស មានអំឡុងពេលខុសៗគ្នាទៅតាមប្រភេទនៃបទល្មើស។ អាជ្ញាយុកាលនៃបទល្មើសមានជាអាទិ៍៖

➢ ចំពោះបទឧក្រិដ្ឋ មានអាជ្ញាយុកាលនៃបទល្មើស ១៥ឆ្នាំ

[91] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៨
[92] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ២៤
[93] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១០
[94] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ១៤៤

- ចំពោះបទមជ្ឈិម មានអាជ្ញាយុកាលនៃបទល្មើស ៥ឆ្នាំ
- ចំពោះបទលហុ មានអាជ្ញាយុកាលនៃបទល្មើស ១ឆ្នាំ។[95]

ប៉ុន្តែអាជ្ញាយុកាលនៃបទល្មើសនេះ មិនយកមកអនុវត្តន៍ចំពោះបទល្មើសមួយចំនួនដូចជា៖ បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម។[96]

កាលណាអំឡុងពេលដែលច្បាប់បានកំណត់នេះបានកន្លងផុតទៅ ជាមូលហេតុមួយដែលនាំឱ្យបណ្ដឹងអាជ្ញាមិនអាចប្រព្រឹត្តទៅបាន ដែលហេតុនាំឱ្យព្រះរាជអាជ្ញាសម្រេចមិនចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ តាមរយៈដីកាតម្កល់រឿងទុកឥតចាត់ការ។

- ការលើកលែងទោសជាទូទៅ

យោងតាមស្មារតីនៃរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស។[97] ចំណែកឯ ច្បាប់ស្ដីពីការលើកលែងទោសទូទៅ គឺត្រូវបានរដ្ឋសភាជាអ្នកអនុម័ត។[98] ការលើកលែងទោសនេះ សំដៅតាមស្មារតីនៃច្បាប់ស្ដីពីការលើកលែងទោសទូទៅ កាលណាបទល្មើសណាមួយទាក់ទងទៅនឹងច្បាប់ស្ដីពីការលើកលែងទោសទូទៅ នោះទោសនៃបទល្មើសព្រហ្មទណ្ឌនោះមិនអាចយកមកអនុវត្តបាននោះទេ។ ម្យ៉ាងទៀត ចំពោះទោសដែលកំពុងអនុវត្តនឹងត្រូវបានបញ្ចប់។ ប៉ុន្តែប្រាក់ដែលបានពិន័យ ឬប្រាក់ប្រដាប់ក្ដីមិនអាចទាមទារពីរដ្ឋវិញបានឡើយ។[99]

ចំពោះអានុភាពវិញ ការលើកលែងទោសទូទៅមានអានុភាពលុបបំបាត់ចោល ឬបញ្ចប់នូវទណ្ឌកម្មព្រហ្មទណ្ឌណាមួយ ពោលគឺការផ្ដន្ទាទោសចំពោះជនល្មើសមិនអាចប្រព្រឹត្តទៅបាន ហើយមានគោលបំណងដកចេញនូវទណ្ឌកម្មទាំងឡាយដែលអនុវត្តលើជនល្មើសនោះ។ ដូចនេះទើប ការលើកលែងទោសទូទៅជាមូលហេតុនៃការរំលត់បណ្ដឹងអាជ្ញា ដែលតម្រូវឱ្យតំណាងអយ្យការសម្រេចតម្កល់រឿងទុកឥតចាត់ការ។

- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ សំដៅដល់ការដែលបទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌចាស់ ដែលមានភាពផ្ទុយគ្នាទៅនឹងបទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌថ្មី ដែលចូលជាធរមាន ហើយនឹងកំពុងអនុវត្តន៍។ ក្នុងករណីនេះ មានភាពទាក់ទងទៅនឹងគោលការណ៍នីត្យានុកូលភាពនៃបទល្មើស ព្រោះដើម្បីចោទប្រកាន់ជនណាមួយពីបទល្មើស

[95] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១០

[96] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៩

[97] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ១៩៩៣, មាត្រា ២៧

[98] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ១៩៩៣, មាត្រា ៩០ថ្មី

[99] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ១៤៩ កថាខណ្ឌទី ៤

ព្រហ្មទណ្ឌ ត្រូវបំពេញធាតុផ្សំនៃបទល្មើសឱ្យបានគ្រប់គ្រាន់ ដែលក្នុងនោះមានធាតុផ្សំនីត្យានុកូលភាពផងដែរ។ ធាតុនីត្យានុកូលភាព សំដៅលើការកំណត់ថាអំពើល្មើសណាមួយជាបទល្មើសព្រហ្មទណ្ឌបាន លុះត្រាតែមានបញ្ញត្តិច្បាប់កំណត់។ ដូចនេះបើក្នុងច្បាប់ព្រហ្មទណ្ឌចាស់កំណត់ថាអំពើនោះជាបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែច្បាប់នោះបាននិរាករណ៍ ហើយច្បាប់ព្រហ្មទណ្ឌថ្មីមិនបានកំណត់អំពើនោះថាជាបទល្មើសព្រហ្មទណ្ឌទេ នោះតំណាងអយ្យការមិនអាចសម្រេចចោទប្រកាន់ពីបទល្មើសណាមួយបានទេ ពោលគឺត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ។

ចំពោះអានុភាពនៃច្បាប់ព្រហ្មទណ្ឌថ្មី បានរុញច្រានច្បាប់ព្រហ្មទណ្ឌចាស់ គឺមានអានុភាពលើបទល្មើសនោះមិនអាចចោទប្រកាន់បានទេ។ លើសពីនេះទៅទៀត និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ក៏មានអានុភាពលើការចោទប្រកាន់ដែលកំពុងប្រព្រឹត្ត គឺត្រូវបញ្ចប់។[100] ប្រសិនបើការផ្តន្ទាទោសជាស្ថាពរត្រូវបានប្រកាសរួចហើយ ទោសនោះមិនត្រូវអនុវត្តន៍ទេ ឬត្រូវតែឈប់អនុវត្ត។[101]

. អាជ្ញាអស់ជំនុំ

គោលការណ៍អាជ្ញាអស់ជំនុំ សំដៅលើជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវបានចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសផ្សេងក៏ដោយ។[102] មានន័យថា កាលណាតុលាការចេញសាលក្រមសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ តុលាការមិនអាចចោទប្រកាន់ជននោះ ចំពោះអង្គហេតុចាស់ដដែលបានទេ បើទោះបីជាស្ថិតក្រោមឈ្មោះបទល្មើសថ្មីក៏ដោយ។ លើសពីនេះទៅទៀត ដីកាតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា ពុំមានអានុភាពនាំឱ្យមានអាជ្ញាអស់ជំនុំទេ។[103]

ដូចនេះ អាជ្ញាអស់ជំនុំ ក៏ជាមូលហេតុដែលនាំឱ្យបណ្តឹងអាជ្ញារលត់ផងដែរ។

. ការសម្របសម្រួលជាមួយរដ្ឋ

ការសម្របសម្រួលជាមួយរដ្ឋ លុះត្រាតែមានការអនុញ្ញាតឱ្យមានការសម្របសម្រួល ដោយមានចែងជាក់លាក់ក្នុងច្បាប់ដោយឡែក ដែលជាទូទៅ ការសម្របសម្រួលអាចធ្វើទៅបានលុះត្រាតែអំពីនោះផ្តល់នូវផលប៉ះពាល់តិចតួចដល់សង្គម ឬសណ្តាប់ធ្នាប់សាធារណៈ។ លើសពីនេះទៅទៀត លុះត្រាតែជនដែលបានប្រព្រឹត្តអំពើនោះ ព្រមទទួលស្គាល់នូវកំហុសរបស់ខ្លួន។ ប៉ុន្តែការសម្របសម្រួលជាមួយជនរងគ្រោះ ដោយការសងជា

[100] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៩ កថាខណ្ឌទី ១
[101] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៩ កថាខណ្ឌទី ២
[102] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២
[103] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១ កថាខណ្ឌទី ២

សំណងការខូចខាត សំណងជម្ងឺចិត្ត មិនមែនជាមូលហេតុដែលនាំឱ្យបណ្ដឹងអាជ្ញាផុតរលត់ឡើយ ពោលគឺការសម្របសម្រួលជាមួយជនរងគ្រោះនេះ រលត់ត្រឹមតែបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះ។

• ការដកពាក្យបណ្ដឹង នៅក្នុងករណីដែលពាក្យប្ដឹងនេះមានលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ

ការដកពាក្យបណ្ដឹងដោយជនរងគ្រោះនេះផងដែរ អាចអនុវត្តន៍ទៅបានលុះត្រាតែមានចែងជាក់លាក់ក្នុងច្បាប់ដោយឡែក។ ការដកពាក្យបណ្ដឹងនេះ អនុវត្តន៍តែចំពោះបទល្មើសមួយចំនួនដែលជាបទមជ្ឈិមស្រាល ឬបទលហុ ហើយដែលបណ្ដឹងនោះជាលក្ខខណ្ឌចាំបាច់សម្រាប់ព្រះរាជអាជ្ញាក្នុងការចោទប្រកាន់អំពីបទល្មើសណាមួយបាន។

ករណីដែលអាចអនុវត្តន៍ការដកពាក្យបណ្ដឹងដោយជនរងគ្រោះនោះបានគឺ មាត្រា ៣៦ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជងរងគ្រោះ ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ ក្នុងករណីបើមានសំណើពីជនរងគ្រោះជានីតិជនដោយបទល្មើសនោះអាចជា បទមជ្ឈិមស្រាល ឬបទលហុ។ មានន័យថា កាលណាបើជនរងគ្រោះដែលជានីតិជននោះ បានស្នើសុំកុំឱ្យមានការចោទប្រកាន់ នោះដំណើរការនៃការចោទប្រកាន់ចំពោះមជ្ឈិមស្រាល ឬបទលហុនោះ មិនអាចប្រព្រឹត្តទៅបានទេ។ ពោលការស្នើសុំកុំឱ្យចោទប្រកាន់របស់ជនរងគ្រោះនោះ ត្រូវសន្មតថាជាការដកពាក្យបណ្ដឹង ដែលបណ្ដាលឱ្យបណ្ដឹងអាជ្ញាត្រូវបានផុតរលត់។

• ការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល

ការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួលនេះ អាចអនុវត្តន៍ទៅបានតែចំពោះបទល្មើសមួយចំនួនតែប៉ុណ្ណោះ ដែលករណីទាំងនោះមានចែងក្នុងច្បាប់ដោយឡែក។ បទល្មើសទាំងនោះអាចបញ្ចប់ទៅវិញបានដោយមិនចាំបាច់ធ្វើបណ្ដឹងអាជ្ញា ឬធ្វើការចោទប្រកាន់នោះទេ ពោលគឺគ្រាន់តែបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួលតែប៉ុណ្ណោះ។ បទល្មើសទាំងនោះ អាចជាបទល្មើសចរាចរណ៍។

ដូចជាមាត្រា ៦៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៥ ចំពោះបទល្មើសចរាចរណ៍ដែលត្រូវផ្ដន្ទា-ទោសពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ហើយមន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក អាចធ្វើការសម្របសម្រួលក្នុងគ្រោះថ្នាក់ចរាចរណ៍ ដែលតម្រូវឱ្យសងតែសំណងការខូចខាតប៉ុណ្ណោះ។ ដូចនេះការបង់ប្រាក់ពិន័យអន្តរការណ៍នេះ អាចឱ្យជនប្រព្រឹត្តអំពើនោះ រួចផុតពីការចោទប្រកាន់របស់ព្រះរាជអាជ្ញា ពោលគឺបណ្ដឹងអាជ្ញាត្រូវបានផុតរលត់ តាមការបង់ប្រាក់ពិន័យ។

## កថាខណ្ឌទី២៖ នត្ថិភាពនៃបទល្មើស

ជាទូទៅ រាល់អំពើល្មើសទាំងអស់ មិនប្រាកដថាសុទ្ធសឹងតែជាបទល្មើសនោះទេ បើទោះបីជាអំពើល្មើសនោះបានបង្កឱ្យមានព្យសនកម្មក៏ដោយ។ ផ្អែកតាមគោលការណ៍នីត្យានុកូលភាព រាល់អំពើល្មើសដែលបង្កើតឱ្យមានបទល្មើស លុះត្រាតែអំពើល្មើសនោះត្រូវបានបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌតែប៉ុណ្ណោះ ទើបត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌបាន។[104] មានន័យថា លុះត្រាតែក្រមព្រហ្មទណ្ឌបានបញ្ញត្តិថាអំពើល្មើសនេះជាបទល្មើស ទើបអាចត្រូវបានផ្តន្ទាទោសបាន។ ដូចនេះ នត្ថិភាពនៃបទល្មើស អាចជាភាពដែលអវត្តមានបទល្មើស ឬកង្វះធាតុផ្សំនៃបទល្មើស។

. ភាពអវត្តមានបទល្មើស

ក្រោយពីព្រះរាជអាជ្ញាបានដឹង ឬទទួលបាននូវបណ្តឹងសាមញ្ញ ឬបណ្តឹងបរិហារ នោះព្រះរាជអាជ្ញានឹងថ្លឹងថ្លែងអំពីបណ្តឹងនោះ ថាត្រូវសម្រេចចោទប្រកាន់ ឬមិនចោទប្រកាន់។ ចំណុចមួយក្នុងចំណុចជាច្រើនដែលព្រះរាជអាជ្ញាថ្លឹងថ្លែងក្នុងការសម្រេចនោះគឺ អវត្តមាននៃបទល្មើស។ អវត្តមាននៃបទល្មើស សំដៅដល់បណ្តឹងដែលធ្វើឡើងប្រឆាំងនឹងអំពើដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ ដែលអាចជាបណ្តឹងដែលបានដាក់ខុសមុខងារនៃសមត្ថកិច្ចសាលាជម្រះក្តី។ ហើយក៏អាចជាការភាន់ច្រឡំ ឬខុសរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលបានធ្វើសេចក្តីសន្និដ្ឋាន។

. កង្វះធាតុផ្សំនៃបទល្មើស

ជាគោលការណ៍ ដើម្បីសន្មតថាអំពើណាមួយជាបទល្មើសព្រហ្មទណ្ឌ លុះត្រាតែអំពើនោះបានបំពេញនូវធាតុផ្សំបទល្មើសបានគ្រប់គ្រាន់។ ការដែលបំពេញនូវធាតុផ្សំនៃបទល្មើសនេះ គឺជាកត្តាមួយដែលជម្រុញធ្វើការចោទប្រកាន់លើបុគ្គលណាម្នាក់ថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីដែលធាតុផ្សំនៃបទល្មើសមិនត្រូវបានបំពេញ នោះក៏ជាកត្តាដែលធ្វើឱ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការដែរ។ ជាគោលការណ៍ ធាតុផ្សំបទល្មើសមានបីគឺ៖ ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត។

- ធាតុនីត្យានុកូល៖ សំដៅដល់ធាតុផ្សំដែលទាក់ទងនឹងច្បាប់។ ពោលគឺដើម្បីកំណត់ថាអំពើល្មើសណាមួយជាបទល្មើសព្រហ្មទណ្ឌទៅបាន លុះត្រាតែមានបទប្បញ្ញត្តិជាក់លាក់ជាអ្នកកំណត់ថាអំពើល្មើសនោះ គឺជាបទល្មើសព្រហ្មទណ្ឌ។

- ធាតុសត្យានុម័ត៖ អាចហៅម្យ៉ាងទៀតបានថាជា ធាតុផ្សំសម្ភារៈ ដែលសំដៅដល់អំពើប្រព្រឹត្ត ឬហេតុការណ៍ទាំងឡាយ ទោះបីជាអំពើសកម្មក្តី ឬអំពើអកម្មក្តី ដែលអំពើទាំងនោះបានបង្កើតឱ្យមាននូវអាកប្បកិរិយា

[104] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៣ កថាខណ្ឌទី ១

ណាមួយ ដែលត្រូវបានបទបញ្ញត្តិនៃច្បាប់កំណត់ថា អំពើនោះជាបទល្មើស។ អំពើប្រព្រឹត្ត ឬហេតុការណ៍នោះ អាចមានច្រើន ដូចជាអំពើកើតឡើងភ្លាមៗ ឬអូសបន្លាយ អំពើកើតឡើងម្តងម្កាល ឬជាទម្លាប់ជាអាទិ៍។

- ធាតុអត្តនោម័តៈ សំដៅលើឆន្ទៈ ឬចេតនាដែលជាកិរិយាផ្លូវចិត្តរបស់អ្នកប្រព្រឹត្ត ចំពោះអំពើដែលបានប្រព្រឹត្ត ហើយបង្កឱ្យមានគ្រោះថ្នាក់ដល់សង្គម និងព្យសនកម្មដែលកើតឡើងដោយសារអំពើនោះ។ ជាគោលការណ៍ ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្តអំពើ លើកលែងតែមានករណីដែលច្បាប់បានបញ្ញត្តិទុកជាមុន។ អំពើដែលមិនមានចេតនា ឬឆន្ទៈក្នុងប្រព្រឹត្តដែលបញ្ញត្តិច្បាប់បានកំណត់ថាជាបទល្មើសនោះ អាចជាការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយទ្បែកណាមួយ។[105]

សរុបមក អំពើណាមួយដែលបានប្រព្រឹត្តឡើង ដោយមានធាតុផ្សំណាមួយនៃធាតុផ្សំទាំងបីខាងលើ មិនត្រូវបានបំពេញទេនោះ ត្រូវសន្មតថាធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់ ដែលជាហេតុនាំឱ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ។

### កថាខណ្ឌទី៣៖ មូលហេតុគតិយុត្តិផ្សេងទៀត

ក្រៅពីមូលហេតុជាច្រើន ដែលបានបកស្រាយខាងលើ ក៏នៅមានមូលហេតុមួយចំនួនទៀត ដែលជាកត្តាជម្រុញឱ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការផងដែរ ហើយមូលហេតុទាំងនោះក៏ត្រូវបានបញ្ញត្តិក្នុងច្បាប់ជាធរមានដែរ។ មូលហេតុទាំងនោះមានជាអាទិ៍៖ ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ អភ័យឯកសិទ្ធិ និងអនិយ័តភាពនៃនីតិវិធី។ល។

- ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

ការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនល្មើស សំដៅដល់ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើសទៅលើអំពើល្មើសដែលខ្លួនបានប្រព្រឹត្ត។ កាលណាអំពើល្មើសស្ថិតក្នុងលក្ខខណ្ឌនៃការមិនទទួលខុសត្រូវ បើទោះបីជាអំពើនោះបង្កឱ្យមានព្យសនកម្មច្រើនក៏ដោយ ក៏ជននោះមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌដែរ ឬរួចផុតពីការទទួលខុសត្រូវ។ ដោយផ្អែកតាមក្រមព្រហ្មទណ្ឌ ការមិនទទួលខុសត្រូវ ឬការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ គឺត្រូវគិតពិចារណាទៅលើ កាលៈទេសៈនៃបទល្មើស និងចរិកលក្ខណៈនៃជនល្មើស។ យោងតាមក្រមព្រហ្មទណ្ឌ មូលហេតុដែលនាំឱ្យរួចផុតពីការទទួលខុសត្រូវ ឬមិនទទួលខុសត្រូវព្រហ្មទណ្ឌ រួមមានជាអាទិ៍៖

- វិបល្លាសស្មារតី[106]៖ សំដៅដល់ស្ថានភាពមួយដែលជននោះមិនអាចវិនិច្ឆ័យផ្លូវច្បាប់ ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។ វិបល្លាសស្មារតី អាចជាការបាត់បង់ការដឹងខុសត្រូវ ឬបន្ថយការដឹងខុសត្រូវរបស់ខ្លួន។ ចំពោះ

---

[105] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៤

[106] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៣១

ករណីដែលជនល្មើសនោះស្ថិតក្នុងភាពវិបល្លាសស្មារតីដែលបាត់បង់ការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ដោយឡែកករណីដែលជននោះ ស្ថិតក្នុងស្ថានភាពវិបល្លាសស្មារតី ក្នុងកម្រិតបន្ថយនូវការយល់ដឹងខុសត្រូវរបស់ខ្លួន ក៏ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ដោយតុលាការយកភាពវិបល្លាសស្មារតីមកពិចារណាក្នុងការកំណត់ទោស។ រីឯភាពវិបល្លាសស្មារតី ដោយសារគ្រឿងស្រវឹង ឬគ្រឿងញៀន មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានទេ។

- ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ[107]៖ សំដៅដល់ការអនុញ្ញាតជាមុន ដោយច្បាប់ ឬបទបញ្ញត្តិនានា ឬតាមការបញ្ជារបស់អាជ្ញាធរមានសមត្ថកិច្ចដែលច្បាប់បានប្រគល់សិទ្ធិ។ បើទោះបីជាអំពើល្មើសនោះសន្មតថាជាបទល្មើសក៏ដោយ ក៏ជននោះអាចត្រូវបានរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។ ដោយឡែកចំណុចនេះ មិនអនុវត្តន៍ចំពោះ បទល្មើសដែលមានចរិកលក្ខណៈឃោរឃៅ ទៅលើសង្គមជាតិ ដូចជា បទល្មើសប្រល័យពូជសាសន៍ បទល្មើសឧក្រិដ្ឋសង្គ្រាម និងបទល្មើសឧក្រិដ្ឋប្រឆាំងមនុស្សជាតិទេ។

- ការការពារស្របច្បាប់[108]៖ សំដៅលក្ខខណ្ឌក្នុងការប្រព្រឹត្តអំពើល្មើសក្នុងការការពារស្របច្បាប់។ កាលណាលក្ខខណ្ឌនៃការការពារស្របច្បាប់នេះត្រូវបានបំពេញ អ្នកប្រព្រឹត្តអំពើនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ លក្ខខណ្ឌក្នុងការសន្មតថាជាការការពារស្របច្បាប់រួមមាន៖ (១) ជាភាពចាំបាច់ក្នុងការការពារខ្លួន អ្នកដទៃ ឬទ្រព្យសម្បត្តិរបស់ខ្លួន ឬរបស់អ្នកដទៃ ដែលនឹងត្រូវប្រឈមមុខនិងការឈ្លានពាន (២) បទល្មើស និងអំពើឈ្លានពានត្រូវកើតឡើងក្នុងពេលដំណាលគ្នា និង(៣) គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារ និងទម្ងន់នៃការឈ្លានពាន។

- សច្ចធារណ៍នៃការការពារស្របច្បាប់[109]៖ ជាការសន្មតថាជាការការពារស្របច្បាប់ ក្នុងករណីដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ និងប្រព្រឹត្តដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តន៍ដោយហិង្សា។

- ស្ថានភាពចាំបាច់[110]៖ សំដៅដល់ស្ថានភាពមួយដែលតម្រូវឱ្យជននោះប្រព្រឹត្តបទល្មើស។ លក្ខខណ្ឌក្នុងការសន្មតថាជាស្ថានភាពចាំបាច់រួមមាន៖ (១) ស្ថានភាពចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារ

[107] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៣២

[108] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៣៣

[109] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៣៤

[110] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៣៥

ទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន។ (២) គ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់។

- អានុភាពនៃកម្លាំង ឬការបង្ខំ[111]៖ កាលណាជនណាម្នាក់បានប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំដែលមិនអាចទប់ទល់បាន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ហើយមិនអាចមើលឃើញជាមុន និងមិនអាចជៀសវាងបាន។

- ជនល្មើសដែលជាអនីតិជនមានអាយុក្រោម ១៤ឆ្នាំ៖ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់ចាប់ពីអាយុ ១៨ឆ្នាំឡើងទៅ។[112] ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ឆ្នាំឡើងទៅ។[113] មូលហេតុទាំងនេះ សរបង្ហាញឱ្យឃើញថា អនីតិជនមានអាយុក្រោម ១៤ឆ្នាំមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ លើសពីនេះទៅទៀត ក្នុងករណីអនីតិជនមានអាយុក្រោម ១៤ឆ្នាំ គិតដល់ថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស នោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ។[114]

សរុបមកវិញ មូលហេតុគតិយុត្តិទាំងនេះសុទ្ធសឹងតែជាកត្តាដែលជម្រុញឱ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ។ បើទោះបីជាអំពើដែលបានប្រព្រឹត្តខាងលើនេះ គឺជាបទល្មើសក្តី ក៏ប៉ុន្តែច្បាប់បានបញ្ញត្តិថាអំពើទាំងនោះជាអំពើយុត្តិកម្ម ដែលតម្រូវឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។

. អភ័យឯកសិទ្ធិ

អភ័យឯកសិទ្ធិ គឺជាសិទ្ធិពិសេសមួយ ដែលប្រគល់ទៅឱ្យបុគ្គលពិសេសមួយចំនួនតូច។ ដូចមានបញ្ញត្តិក្នុងរដ្ឋធម្មនុញ្ញ សមាជិករដ្ឋសភាមានអភ័យឯកសិទ្ធិ[115] និងសមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិ។[116] ដូចនេះចំពោះជនដែលមានអភ័យឯកសិទ្ធិ មិនអាចត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយ ក្នុងពេលដែលខ្លួនស្ថិតក្នុងតួនាទីរបស់ខ្លួនឡើយ។ ជាគោលការណ៍ បើទោះបីជាអំពើនោះសន្មតថាជាបទល្មើសក៏ដោយ ក៏ជនដែលមានសិទ្ធិពិសេសនេះ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។

. អនិយ័តភាពនៃកិច្ចនីតិវិធី

អនិយ័តភាពនៃកិច្ចនីតិវិធី សំដៅដល់ភាពមួយដែលមិនត្រឹមត្រូវតាមច្បាប់នៃការអនុវត្តកិច្ចនីតិវិធីនៅក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ឬតំណាងអយ្យការ ក្នុងការស៊ើបអង្កេត ស្រាវជ្រាវបន្ថែម។ ហើយការអនុវត្ត

[111] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៣៦

[112] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៣៨

[113] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៣៩ កថាខណ្ឌទី ២

[114] ច្បាប់ស្តីពីយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧១៦/០០៩, ១៤ កក្កដា ឆ្នាំ២០១៦, មាត្រា ២៧ កថាខណ្ឌទី ១

[115] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ១៩៩៣, មាត្រា ៨០

[116] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ១៩៩៣, មាត្រា ១០៤ថ្មី

នោះមានភាពមិនស្របនីតិវិធី និងមិនបានលទ្ធផល គ្មានប្រយោជន៍ ដែលជាហេតុនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការ។

**កថាខណ្ឌទី៤៖ ការចោទប្រកាន់មិនផ្ដល់ប្រយោជន៍**

ការចោទប្រកាន់មិនផ្ដល់ប្រយោជន៍ សំដៅដល់ការថ្លឹងថ្លែងរបស់ព្រះរាជអាជ្ញា ឬតំណាងអយ្យការ ទៅលើស្ថានភាពណាមួយដែលពាក់ព័ន្ធបទល្មើស ចារី សហចារី ជនរងគ្រោះ ជាអាទិ៍ ហើយរកឃើញថា ប្រសិនបើចោទប្រកាន់ ហាក់បីដូចជាមិនបានផ្ដល់ផលប្រយោជន៍អ្វីសោះដល់សង្គម។ ម្យ៉ាងទៀត ការចោទប្រកាន់នោះអាចមិនផ្ទុយពីគោលបំណងនៃបណ្ដឹងអាជ្ញាផងដែរ។

មូលហេតុដែលនាំឱ្យការចោទប្រកាន់របស់តំណាងអយ្យការ ឬព្រះរាជអាជ្ញាមិនផ្ដល់ប្រយោជន៍នោះ អាចបណ្ដាលមកពីកត្តាជាច្រើនដូចជា៖ កត្តាចំណាត់ការ កត្តាចារី កត្តាជនរងគ្រោះ កត្តាព្យសនកម្ម ជាអាទិ៍។

- កត្តាចំណាត់ការ៖ សំដៅដល់ស្ថានភាពមួយដែល ការចាទប្រកាន់មិនបានផ្ដល់ផលប្រយោជន៍ ដោយសារចំណាត់ការនៃនីតិវិធី។ ចំណាត់ការនៃនីតិវិធី អាចជាកាលៈទេសៈមួយដែលកិច្ចស៊ើបអង្កេតមិនបានផល ដែលអាចមកពីមូលហេតុនៃការអូសបន្លាយពេលយូរក្នុងការស៊ើបអង្កេតជាអាទិ៍។

- កត្តាចារី៖ សំដៅដល់ស្ថានភាពមួយដែលអ្នកប្រព្រឹត្ត ឬចារីស្ថិតក្នុងស្ថានភាពចាំបាច់ណាមួយ។ ស្ថានភាពទាំងនោះអាចជា ស្ថានភាពដែលចារីមានអាកប្បកិរិយា និងទទួលស្គាល់កំហុសដែលខ្លួនបានប្រព្រឹត្ត ឬអាចជាស្ថានភាពបញ្ហាបន្ទុកគ្រួសារ។ល។

- កត្តាជនរងគ្រោះ៖ សំដៅដល់ស្ថានភាពដែលជនរងគ្រោះខ្លួនឯង បានបោះបង់ចោលពាក្យបណ្ដឹង ឬការដែលមិនអើពើចំពោះអំពើល្មើសមកលើខ្លួន ឬការខកខាននៅក្នុងនីតិវិធី។ល។

- កត្តាព្យសនកម្ម៖ សំដៅដល់ស្ថានភាពដែលអំពើល្មើសនោះ បានហុចផល ដែលជាព្យសនកម្មមានលក្ខណៈតិចតួច ឬអាចជាភាពដែលព្យសនកម្មបានកើតចេញពីអំពើល្មើស ប៉ុន្តែព្យសនកម្មត្រូវបានប៉ះប៉ូវ។ល។

ក្រៅពីមូលហេតុដែលបានបកស្រាយខាងលើ ក៏នៅមានមូលហេតុជាក់ស្ដែងជាច្រើនទៀតដែលធ្វើឱ្យការចោទប្រកាន់មិនផ្ដល់ប្រយោជន៍ ដែលជាហេតុនាំឱ្យតំណាងអយ្យការថ្លឹងថ្លែងលើការសម្រេចតម្កល់រឿងទុកឥតចាត់ការ។

- អំពើល្មើសដែលបង្កព្យសនកម្មតិចតួច

ក្រោយពីព្រះរាជអាជ្ញាទទួលបាននូវបណ្ដឹង ព្រះរាជអាជ្ញាត្រូវថ្លឹងថ្លែងអំពីអំពើនោះ ដើម្បីសម្រេចថាចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ។ ការថ្លឹងថ្លែងរបស់ព្រះរាជអាជ្ញានោះ ត្រូវថ្លឹងថ្លែងទៅលើចរិកគ្រោះថ្នាក់ និងព្យសនកម្មរបស់អំពើនោះ ដែលប៉ះពាល់ទៅដល់ជនរងគ្រោះ ក៏ដូចជាសង្គមជាតិទាំងមូល។ កម្មវត្ថុនៃការចោទ

ប្រកាន់គឺមានគោលបំណងស្វែងរកការពិតនៃបទល្មើស និងចង្អុលបង្ហាញជនល្មើសដើម្បីយកមកផ្តន្ទាទោស។ ដូចនេះប្រសិនបើការចោទប្រកាន់ចំពោះអំពើដែលមានចរិកគ្រោះថ្នាក់ និងបច្ច័យតិចតួចបំផុត ការថ្លឹងថ្លែងក៏មានគោលបំណងតែមួយគត់ គឺផ្តល់ផលប្រយោជន៍ដល់សង្គមជាតិ តាមការតម្កល់រឿងទុកឥតចាត់ការ។

## ផ្នែកទី២៖ នីតិវិធី ទម្រង់ការ និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

ក្នុងករណីដែលតំណាងអយ្យការ ឬព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ចំពោះអង្គហេតុណាមួយដោយផ្អែកតាមមូលហេតុដែលបានបកស្រាយខាងលើ ដោយធ្វើឡើងទៅតាមនីតិវិធីមួយច្បាស់លាស់ នឹងត្រឹមត្រូវតាមលក្ខខណ្ឌដែលច្បាប់តម្រូវ ទើបដីកានេះមានអានុភាពអនុវត្តន៍។

### កថាខណ្ឌទី១៖ នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

ក្រោយពីទទួលបានពាក្យបណ្តឹងសាមញ្ញ ឬបណ្តឹងបរិហារ ដោយផ្ទាល់ឬតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញាត្រូវថ្លឹងថ្លែងអំពីចំណាត់ការនៃបណ្តឹងនោះ។[117] ក្នុងករណីដែលព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវចេញដីកាមួយហៅថា ដីកាតម្កល់រឿងទុកឥតចាត់ការ។ ដើម្បីឱ្យដីកានេះមានអានុភាពអនុវត្តន៍ លុះត្រាតែការចេញដីកាត្រូវបានធ្វើឡើងតាមនីតិវិធីដែលច្បាប់បានកំណត់។

កាលណាបណ្តឹងណាមួយត្រូវបានតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់អ្នកប្តឹង អំពីសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ខែ។[118] មានន័យថា កាលណាព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវផ្តល់ដំណឹងអំពីការសម្រេចទៅអ្នកប្តឹង ឱ្យបានឆាប់បំផុត ដោយមិនឱ្យលើសពីរយៈពេល ២ខែទេ។ ការជូនដំណឹងអំពីការសម្រេចគឺ មានគោលបំណងគោរពនូវសិទ្ធិរបស់អ្នកប្តឹង ដើម្បីឱ្យបានដឹងអំពីសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា នឹងធានាឱ្យបាននូវសិទ្ធិប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចនោះ។ ក្នុងករណីដែលមិនសុខចិត្ត អាចប្តឹងតវ៉ាអំពីសេចក្តីសម្រេចនេះទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលជានាយឋានានុក្រមរបស់ព្រះរាជអាជ្ញា។ រយៈពេលនៃការផ្តល់ដំណឹងនេះមានរយៈពេល ២ ខែគិតចាប់ពីថ្ងៃចុះពាក្យប្តឹងក្នុងបញ្ជី ដែលបញ្ជីនោះសំដៅដល់បញ្ជីរបស់អយ្យការសម្រាប់ចុះបណ្តឹង ដែលមាននៅតាមតុលាការជាន់ទាបនីមួយៗ។[119]

### កថាខណ្ឌទី២៖ ទម្រង់នៃការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ ត្រូវធ្វើឡើងដោយដីកាតម្កល់រឿងទុកឥតចាត់ការ។ ទម្រង់នៃការតម្កល់រឿងទុកឥតចាត់ការ សំដៅទៅដល់ធាតុដែលចាំបាច់ត្រូវមានក្នុងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ដើម្បីឱ្យ

[117] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤០ កថាខណ្ឌទី ១
[118] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១ កថាខណ្ឌទី ១
[119] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥០

ដីកានេះមានអានុភាពអនុវត្តន៍ទៅបាន។ ដោយឡែក ក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានបញ្ញត្តិអំពីទម្រង់របស់ដីកានេះឱ្យបានច្បាស់លាស់ឡើយ ប៉ុន្តែក៏មានលក្ខខណ្ឌចាំបាច់មួយផងដែរ ពោលគឺការតម្កល់រឿងទុកឥតចាត់ការត្រូវតែមានសំអាងច្បាប់ និងសំអាងហេតុ។[120] សំអាងច្បាប់ សំដៅដល់ការលើកយកនូវអត្ថបទច្បាប់ ដើម្បីជាការគាំទ្រ និងជាមូលហេតុក្នុងការចេញដីកាតម្កល់រឿងទុកឥតចាត់ការ។ សំអាងហេតុ មានន័យថា ជាទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ដែលនាំឱ្យចេញសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ដូចនេះ សំអាងហេតុ និងសំអាងច្បាប់ ជាលក្ខខណ្ឌចាំបាច់ដែលតម្រូវឱ្យដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការត្រូវតែមានជាដាច់ខាត និងមិនអាចខ្វះបាន។

### កថាខណ្ឌទី៣៖ អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ គ្មានអាជ្ញាអស់ជំនុំទេ។[121] ពោលគឺ នៅពេលមានការតម្កល់រឿងទុកឥតចាត់ការ គឺពុំបង្កើតឱ្យមានអានុភាពអាជ្ញាអស់ជំនុំទេ។ មានន័យថា កាលណាព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការហើយ ជនល្មើសគឺអាចនឹងត្រូវបានព្រះរាជអាជ្ញាសើរើរឿងក្តីសម្រាប់ចោទប្រកាន់ជាថ្មីបាន។ ពោលគឺ ការតម្កល់រឿងទុកឥតចាត់ការមិនមានអានុភាព ធ្វើឱ្យជនល្មើសរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានទេ នាពេលដែលព្រះរាជអាជ្ញាសម្រេចចោទប្រកាន់សារជាថ្មី។ ការសម្រេចចោទប្រកាន់ជាថ្មីនេះ អាចកើតឡើងនាពេលដែលមានការលេចឡើង ឬព្រះរាជអាជ្ញាទទួលបាននូវភស្តុតាងសម្រាប់ដាក់បន្ទុកក្នុងការចោទប្រកាន់។ ការអនុវត្តការតម្កល់រឿងទុកឥតចាត់ការ ដោយគ្មានភាពអាជ្ញាអស់ជំនុំនេះ គឺសំដៅធានាឱ្យបាននូវសិទ្ធិរបស់ជនរងគ្រោះនៃបទល្មើស ដើម្បីឱ្យមានការសើរើឡើងវិញចំពោះការសម្រេចសេចក្តីរបស់ព្រះរាជអាជ្ញា នៅពេលដែលការសម្រេចសេចក្តីរបស់ព្រះរាជអាជ្ញាមានការខុសឆ្គង ឬចន្លោះប្រហោងត្រង់ចំណុចណាមួយ ព្រោះការសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ គឺជាឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញាក្នុងការសម្រេចមិនចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ។

សរុបមកវិញ អាជ្ញាអស់ជំនុំមិនអាចស្តែងឡើងតាមរយៈការតម្កល់រឿងទុកឥតចាត់ការបាននោះទេ ដោយហេតុថាការតម្កល់រឿងទុកឥតចាត់ការ គឺជាឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញា។ម្យ៉ាងទៀត ភាពគ្មានអាជ្ញាអស់ជំនុំនេះ អាចធ្វើឱ្យព្រះរាជអាជ្ញាសម្រេចចោទប្រកាន់សារជាថ្មី ទៅលើអង្គហេតុដដែល នៅពេលដែលព្រះរាជអាជ្ញាយល់ឃើញថា មានភស្តុតាងសម្រាប់ដាក់បន្ទុកដែលបង្កើតឱ្យបានជាបទល្មើសព្រហ្មទណ្ឌចំពោះអង្គហេតុដដែល វៀរលែងតែមានការរលត់បណ្តឹងអាជ្ញា។

[120] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៤១ កថាខណ្ឌទី ២

[121] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៤១ កថាខណ្ឌទី ២

## ផ្នែកទី៣៖ យន្តការជម្រុញឱ្យមានការចោទប្រកាន់ឡើងវិញ

យន្តការជម្រុញឱ្យមានការចោទប្រកាន់ឡើងវិញ សំដៅដល់នីតិវិធីទាំងឡាយណា ដែលធ្វើឡើងក្នុងគោលបំណងនាំឱ្យមានការចោទប្រកាន់ឡើងវិញ នៅពេលដែលមានការតម្កល់រឿងទុកឥតចាត់ការ។ ដោយហេតុថា ការតម្កល់រឿងទុកឥតចាត់ការគឺមិនមានលក្ខណៈដាច់ខាតនោះទេ ពោលគឺក្រោយមានការតម្កល់រឿងទុកឥតចាត់ការ ជនល្មើសអាចនឹងត្រូវបានចោទប្រកាន់ឡើងវិញ លើកលែងតែមានការរលត់បណ្តឹងអាជ្ញា។ ដោយផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌ ការដែលជម្រុញឱ្យមានការចោទប្រកាន់ឡើងវិញមានជាអាទិ៍៖ (១)ការកែប្រែសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា (២)ការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញា (៣)អធិបញ្ជារបស់នាយឋានានុក្រមនៃអង្គការអយ្យការ និង(៤)ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

### កថាខណ្ឌទី១៖ ការកែប្រែសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា

ដោយសារតែការតម្កល់រឿងទុកឥតចាត់ការ ពុំបង្កើតឱ្យការអានុភាពអាជ្ញាអស់ជំនុំទេ[122] ដូចនេះតំណាងអយ្យការអាចធ្វើការសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញបាន ក្នុងខណៈដែលបណ្តឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ។[123] មូលហេតុដែលច្បាប់បានអនុញ្ញាតឱ្យព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ឡើងវិញ ព្រោះការសម្រេចតម្កល់រឿងទុកឥតចាត់ការអាចនឹងមានភាពខុសឆ្គង ឬភាពខ្វះចន្លោះក្នុងប្រការណាមួយ ដែលនាំឱ្យការសម្រេចសេចក្តីនេះមានភាពមិនត្រឹមត្រូវ។ ម្យ៉ាងទៀត ការដែលព្រះរាជអាជ្ញាសម្រេចចោទប្រកាន់សារជាថ្មី អាចធ្វើឡើងដោយហេតុថាមានការលេចឡើងនូវភស្តុតាង ឬបានរកឃើញនូវអង្គហេតុថ្មី ដែលបង្កើតឱ្យអំពើល្មើសនោះក្លាយទៅជាបទល្មើសព្រហ្មទណ្ឌ។

ដូចនេះ ការដែលអនុញ្ញាតឱ្យព្រះរាជអាជ្ញាធ្វើការកែប្រែនូវសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ខ្លួននេះ ជាវិធានមួយដែលរឹតបន្តឹងលើការអនុវត្តច្បាប់ ដោយមិនអនុញ្ញាតឱ្យជនដែលបានប្រព្រឹត្តបទល្មើស រួចផុតពីការចោទប្រកាន់ទេ នឹងធានាការពារដល់ប្រយោជន៍ និងផ្តល់ជូននូវយុត្តិធម៌ ដល់ជនរងគ្រោះនៃអំពើល្មើសណាមួយ។ ម្យ៉ាងទៀត ការដែលអនុញ្ញាតឱ្យព្រះរាជអាជ្ញា ធ្វើការកែប្រែនូវសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ខ្លួន ក៏ជាវិធានមួយ ដែលធ្វើឱ្យតំណាងអយ្យការបំពេញនូវតួនាទីរបស់ខ្លួនឱ្យបានត្រឹមត្រូវ តាមរយៈការកែប្រែនូវសេចក្តីសម្រេច ដែលមានការខុសឆ្គង ឬខ្វះចន្លោះនោះឡើងវិញ។

[122] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១ កថាខណ្ឌទី ២
[123] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១ កថាខណ្ឌទី ៣

**កថាខណ្ឌទី២៖ ការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍**

ការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ គឺជានីតិវិធីសង្គ្រោះមួយសម្រាប់ជនរងគ្រោះ ក្នុងការដាក់ពាក្យបណ្តឹងទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ នៅពេលដែលពាក្យប្តឹងត្រូវបានព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការដោយដីកាសម្រេច ឬពាក្យបណ្តឹងស្ថិតនៅដោយគ្មានចំលើយ។[124] មានន័យថា ក្រោយពីពេលដែលព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ហើយជនរងគ្រោះមានការមិនសុខចិត្តនឹងការសម្រេចនេះ ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍[125] ដែលច្បាប់បានកំណត់ថាជានាយឋានានុក្រមរបស់ព្រះរាជអាជ្ញា។[126] ម្យ៉ាងទៀត តួនាទីរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺឃ្លាំមើលការអនុវត្តច្បាប់ ស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[127] ដូចនេះទើបអគ្គព្រះរាជអាជ្ញាមានសិទ្ធិក្នុងការទទួលបណ្តឹងពីជនរងគ្រោះ និងសម្រេចសេចក្តីលើបណ្តឹងនោះ។

រីឯអំឡុងពេលនៃការធ្វើបណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញា ត្រូវធ្វើឡើងក្នុងរយៈពេល ២ ខែ ដែលគិតចាប់ពីថ្ងៃដែលទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ។[128] មានន័យថា ចាប់ពីថ្ងៃដែលទទួលបានដំណឹងអំពីការសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា ជនរងគ្រោះមានរយៈពេល ២ ខែក្នុងការធ្វើបណ្តឹងតវ៉ាចំពោះសេចក្តីសម្រេចនោះ។ ចំពោះការដាក់ពាក្យបណ្តឹងតវ៉ានេះវិញ ត្រូវធ្វើតាមរយៈបណ្តឹងសាមញ្ញដោយជនរងគ្រោះ ដាក់នៅអង្គការអយ្យការពាក់ព័ន្ធ (អង្គការអយ្យការដែលបានចេញសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ)។ ក្រោយពីអង្គការអយ្យការពាក់ព័ន្ធបានទទួលបណ្តឹងសាមញ្ញនោះ នឹងបញ្ជូនសំណុំរឿងនោះភ្លាមទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្នុងគោលបំណងដើម្បីសម្រេចនឹងចេញអធិបញ្ញា។ ការសម្រេចរបស់អគ្គព្រះរាជអាជ្ញាលើបណ្តឹងតវ៉ានោះមាន ២ រូបភាព៖ ការបដិសេធនឹងសេចក្តីសម្រេច និងការយល់ស្របតាមសេចក្តីសម្រេច។

- ការបដិសេធនឹងសេចក្តីសម្រេច

ការបដិសេធនេះ គឺជាស្ថានភាពមួយដែលអគ្គព្រះរាជអាជ្ញាបដិសេធចំពោះសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា។ ប្រសិនបើបណ្តឹងតវ៉ានោះ មានមូលហេតុត្រឹមត្រូវ នោះអគ្គព្រះរាជអាជ្ញានឹងបដិសេធ ចំពោះសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ របស់ព្រះរាជអាជ្ញា ហើយចេញអធិបញ្ញា ដល់ព្រះរាជអាជ្ញាអមសាលាដំបូង

[124] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៦ កថាខណ្ឌទី ២

[125] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១ កថាខណ្ឌទី ៤

[126] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៨

[127] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៤ កថាខណ្ឌទី ១

[128] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១ កថាខណ្ឌទី ៥

ឱ្យធ្វើការចោទប្រកាន់ឡើងវិញ។ អធិបញ្ញានេះ ត្រូវធ្វើឡើងដោយលាយលក្ខណ៍អក្សរ ហើយព្រះរាជអាជ្ញាមិនអាចបដិសេធចំពោះអធិបញ្ញានេះបានទេ ពោលគឺត្រូវតែចោទប្រកាន់តាមអធិបញ្ញារបស់អគ្គព្រះរាជអាជ្ញា។

- ការយល់ស្របនឹងសេចក្តីសម្រេច

សំដៅដល់ករណីមួយ ដែលអគ្គព្រះរាជអាជ្ញាយល់ស្របនឹងសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា។ ក្នុងករណីដែល បណ្តឹងតវ៉ាធ្វើឡើងដោយមិនមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញានឹងសម្រេចតម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាទុកជាបានការ។ ការយល់ស្របនេះ ត្រូវជូនដំណឹងដល់អ្នកប្តឹង ដើម្បីឱ្យអ្នកប្តឹងអាចប្រើប្រាស់នីតិវិធីផ្សេងទៀតបាន។

**កថាខណ្ឌទី៣៖ អំណាចអធិបញ្ញាដោយនាយឋានានុក្រមនៃអង្គការអយ្យការ**

ពាក្យថាអំណាចអធិបញ្ញា សំដៅដល់ការបញ្ជាតាមឋានានុក្រមថ្នាក់លើ មកឱ្យឋានានុក្រមថ្នាក់ក្រោម ដើម្បីបញ្ជាឱ្យធ្វើអ្វីមួយ។ ក្នុងកថាខណ្ឌទី៣នេះ គឺសំដៅលើអំណាចនៃការបញ្ជារបស់ឋានានុក្រមថ្នាក់លើនៃអង្គការអយ្យការ មកឋានានុក្រមថ្នាក់ក្រោមនៃអង្គការអយ្យការ ក្នុងគោលបំណងឱ្យចោទប្រកាន់ឡើងវិញ។ ឋានានុក្រមនៃអង្គការអយ្យការ រួមមាន៖ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា។

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌៖ សំដៅដល់ឋានៈមួយដែលធំជាគេ ក្នុងក្រសួងយុត្តិធម៌ ហើយជាសេនាធិការចំណុះឱ្យរាជរដ្ឋាភិបាល ក្នុងវិស័យច្បាប់។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង អំពីអំពើល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលរដ្ឋមន្ត្រីយល់ឃើញជាការគួរ។[129] រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនអាចធ្វើអធិបញ្ញា ឱ្យតម្កល់រឿងទុកឥតចាត់ការបានទេ។ លើសពីនេះទៅទៀត រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យការ ហើយអាចធ្វើអធិបញ្ញាជាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់។[130]

[129] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣០

[130] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ឆ្នាំ២០១៤, មាត្រា ៧៥ កថាខណ្ឌទី ១

- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍៖ គឺជានាយឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍[131] ដែលមានមុខនាទីឃ្លាំមើលការអនុវត្តច្បាប់ និងមានអំណាចលើព្រះរាជអាជ្ញាទាំងអស់ដែលស្ថិតក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍របស់ខ្លួន។[132] អគ្គព្រះរាជអាជ្ញា អាចធ្វើអធិបញ្ញាឱ្យចោទប្រកាន់ ឬក៏ចាត់ឱ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ឃើញថាជាការគួរ។[133]

- ព្រះរាជអាជ្ញាអមសាលាដំបូង៖ គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញា មានអំណាចទៅលើព្រះរាជអាជ្ញារងដែលនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ហើយអាចធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញារងធ្វើការចោទប្រកាន់ ឬចាត់ឱ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ឃើញថាជាការគួរ។

ដូច្នេះ ប្រសិនបើមានការសម្រេចតម្កល់រឿងទុកឥតចាត់ការ ករណីដែលជនរងគ្រោះមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ អាចធ្វើការប្តឹងទៅនាយឋានានុក្រមនៃអង្គការអយ្យការដែលបានបញ្ជាក់ខាងលើនេះ ក្នុងគោលបំណងដើម្បីឱ្យធ្វើអធិបញ្ញាឱ្យចោទប្រកាន់ឡើងវិញ។

### កថាខណ្ឌទី៤៖ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ

ក្រៅពីជម្រើសដែលបានបកស្រាយខាងលើនេះ ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ក៏អាចដាក់ពាក្យប្តឹង ដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។[134] ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរអំពីបណ្តឹងអាជ្ញា។ ក្រោយពីចៅក្រមស៊ើបសួរ ធ្វើការកត់សម្គាល់ដោយដីកា លើពាក្យបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួររូបនោះត្រូវបញ្ជូនបណ្តឹងនោះទៅព្រះរាជអាជ្ញា។ ក្រោយពីបានឃើញពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរ ដោយប្រើប្រាស់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អាចបើកការប្រឆាំងនឹងអញ្ញាតជន បើទោះជាបណ្តឹងនោះមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចោទប្រកាន់ទៅលើបុគ្គលម្នាក់ ឬច្រើន។[135] ករណីនេះ ព្រះរាជអាជ្ញាក៏អាចសុំឱ្យចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរ ប្រសិនបើបណ្តឹងអាជ្ញា ត្រូវបានផុតរលត់ ឬមិនមែនជាបទ

---

[131] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ឆ្នាំ២០១៤, មាត្រា ៧៥ កថាខណ្ឌទី ១

[132] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៤

[133] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៩ កថាខណ្ឌទី ២

[134] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥

[135] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៣៩ កថាខណ្ឌទី ២

ល្មើសព្រហ្មទណ្ឌទេ។ ចៅក្រមស៊ើបសួរនៅតែស្ថិតក្នុងភាពឯករាជ្យ បើទោះបីជាមានការសុំមិនឱ្យស៊ើបសួរពីព្រះរាជអាជ្ញាក៏ដោយ ពោលគឺចៅក្រមស៊ើបសួរអាចសម្រេចបើកស៊ើបសួរ និងសម្រេចមិនបើកការស៊ើបសួរ។

- ការសម្រេចបើកស៊ើបសួរៈ ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចបើកការស៊ើបសួរ ត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា។

- ការសម្រេចមិនបើកស៊ើបសួរៈ ករណីចៅក្រមស៊ើបសួរសម្រេចមិនបើកការស៊ើបសួរទេនោះ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើ ស្តែងឱ្យឃើញថា ព្រះរាជអាជ្ញាមានតួនាទីយ៉ាងសំខាន់ ក្នុងការការពារផលប្រយោជន៍សាធារណៈ ក៏ដូចជាសណ្តាប់ធ្នាប់ របៀបរៀបរយក្នុងសង្គមផងដែរ។ ក្នុងនោះផងដែរ តួនាទីដ៏សំខាន់របស់ព្រះរាជអាជ្ញា គឺការធ្វើចំណាត់ការទៅលើបទល្មើស ដែលអាចជាការសម្រេចចោទប្រកាន់ ឬការសម្រេចមិនចោទប្រកាន់។ ការសម្រេចនេះផងដែរ គឺជាឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញាដោយផ្អែកតាមបទបញ្ញត្តិ ឬច្បាប់ជាធរមាន។

ចំពោះការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញាដែលក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិមាន ៣គឺ៖ (១) ការបើកការស៊ើបសួរ (២)ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និង(៣)ការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។ ក្រោយពីឆ្លងកាត់តាមការបកស្រាយយ៉ាងលម្អិតខាងលើ បានបញ្ជាក់ឱ្យឃើញច្បាស់ថា ការសម្រេចចោទប្រកាន់នេះ បើទោះបីជាការចោទប្រកាន់នេះមាន ៣ ប្រភេទក៏ដោយ ក៏នៅតែមានគោលបំណងរួមគឺ ផ្តន្ទាទោសចំពោះជនល្មើស និងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ។ ម្យ៉ាងទៀត ការសម្រេចចោទប្រកាន់ និងការសម្រេចមិនចោទប្រកាន់នេះ ទាមទារឱ្យមាននូវលក្ខណៈច្បាស់លាស់បំផុត។ ផ្ទុយមកវិញ ប្រសិនបើមិនមានភាពច្បាស់លាស់ទេនោះ អាចនឹងខាតបង់ដល់ពេលវេលា និងថវិការបស់ភាគី ក៏ដូចជាតុលាការផងដែរ។ ពិសេសជាងនេះទៅទៀត គឺប៉ះពាល់ទៅដល់សិទ្ធិមនុស្សយ៉ាងខ្លាំង ដោយហេតុប្រសិនបើព្រះរាជអាជ្ញាចេញដីកាសម្រេចឃុំខ្លួនជនណាម្នាក់ ទាំងជននោះមិនបានប្រព្រឹត្តអំពើល្មើស ដែលជាហេតុនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជននោះ ព្រោះថាការឃុំខ្លួន គឺប្រៀបបានទៅនឹងការឃុំឃាំងមនុស្ស។ គួបផ្សំផងដែរ ប្រសិនបើព្រះរាជអាជ្ញាមិនបានស្រាវជ្រាវច្បាស់លាស់ទៅលើកាលៈទេសៈ និងចរិកលក្ខណៈនៃបទល្មើសទេនោះ អាចនឹងផ្តល់ភាពអយុត្តិធម៌ដល់ជនរងគ្រោះ ឬអាចនឹងប៉ះពាល់ដល់សំណងជម្ងឺចិត្តរបស់ជនរងគ្រោះ។ ដូចនេះដើម្បីធានាឱ្យបាន នូវការការពារសិទ្ធិ និងបញ្ចៀសនូវភាពអយុត្តិធម៌ដល់ជនរងគ្រោះ។ ការចោទប្រកាន់ដោយប្រើនីតិវិធីបើកការស៊ើបសួរ គឺជាជម្រើសដ៏ល្អបំផុត ដោយហេតុថា នីតិវិធីនៃការបើកការស៊ើបសួរ គឺមានការចូលរួមពីសំណាក់ចៅក្រមស៊ើបសួរ ដែលជាតួអង្គមួយឯករាជ្យពីគូក្តីដើម និងជនល្មើស។ ក្រៅពីជាតួអង្គឯករាជ្យ ចៅក្រមស៊ើបសួរក៏មានតួនាទីក្នុងការស្វែងរកការពិតនៃបទល្មើស ដោយមិនលំអៀងផងដែរ ពោលគឺស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុក។

ម្យ៉ាងវិញទៀត គ្រប់នីតិវិធីទាំងអស់ក៏ត្រូវតែមានភាពឆាប់រហ័សផងដែរ ពោលគឺឆាប់រហ័សទាំងការផ្តល់យុត្តិធម៌ជូនជនរងគ្រោះ និងភាពឆាប់រហ័សជូនជនត្រូវចោទ។ ដោយហេតុថា ប្រសិនបើមានការយឺតយ៉ាវ នោះការអូសបន្លាយចំពោះការឃុំខ្លួនក៏បន្លាយយូរតាមនោះដែរ ដែលធ្វើឱ្យប៉ះពាល់ដល់ ពេលវេលា ខាតបង់ប្រយោជន៍ ជាពិសេសគឺសេដ្ឋកិច្ច និងកិត្តិយស។ រីឯចំពោះជនរងគ្រោះវិញ ភាពយុត្តិធម៌ដែលមានភាពយឺតយ៉ាវ

ស្មើនឹងភាពអយុត្តិធម៌។ ចំពោះភាពឆាប់រហ័ស ការចោទប្រកាន់ដោយប្រើនីតិវិធីបញ្ជូនទៅជម្រះផ្ទាល់ និងការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម ជាជម្រើសដ៏ល្អ ដោយហេតុថានីតិវិធីទាំងពីរនេះ មានលក្ខណៈខ្លីជាងការបើកការស៊ើបសួរ។ ហើយការប្រើប្រាស់នីតិវិធីទាំងពីរនេះ មិនត្រឹមតែផ្ដល់ប្រយោជន៍ដល់គូក្តីឡើយ ថែមទាំងផ្ដល់ផលប្រយោជន៍ដល់តុលាការផងដែរ។ មានន័យថា តុលាការអាចកាត់បន្ថយការកកស្ទះនូវសំណុំរឿងនៅតាមសាលាជម្រះក្តី ពោលគឺមិនចាំបាច់ចំណាយតួអង្គចៅក្រមស៊ើបសួរក្នុងនីតិវិធីនេះឡើយ។

ក្រៅពីការចោទប្រកាន់ចំពោះអំពើល្មើស ព្រះរាជអាជ្ញាក៏មានសិទ្ធិអំណាចក្នុងការសម្រេចមិនចោទប្រកាន់ផងដែរ។ ការសម្រេចមិនចោទប្រកាន់ ឬការតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាអាចសម្រេចទៅបានលុះត្រាតែលក្ខខណ្ឌត្រូវបានបំពេញ។ ការតម្កល់រឿងទុកឥតចាត់ការអាចសម្រេចបាន បើទោះបីជាអំពើល្មើសនោះជាបទល្មើសក៏ដោយ ព្រោះថាការចោទប្រកាន់លើអំពើទាំងនោះអាចផ្តល់នូវផលប៉ះពាល់ និងខាតបង់ជាដើម។ មូលហេតុនៃការសម្រេចតម្កល់រឿងទុកឥតចាត់ការ អាចបណ្តាលមកពីកត្តាជាច្រើនដូចជា មូលហេតុនៃការរលត់បណ្តឹងអាជ្ញា ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍ នត្ថិភាពនៃបទល្មើស និងមូលហេតុគតិយុត្តផ្សេងទៀត។ ហើយការសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ គឺបានផ្តល់នូវផលប្រយោជន៍ដូចជា ចំណេញពេលវេលា ថវិកា របស់ភាគី និងតុលាការ កាត់បន្ថយការកកស្ទះនូវសំណុំរឿង ផ្តល់ឱកាសដល់ជនល្មើសក្នុងការស្តារនីតិសម្បទាឡើងវិញ ជាពិសេសសម្រាប់អនីតិជន និងជនដែលជាមេគ្រួសារ។

សរុបជារួម សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញាក្នុងការសម្រេចចោទប្រកាន់ ឬការសម្រេចមិនចោទប្រកាន់សុទ្ធសឹងតែមានផ្តល់នូវគុណសម្បត្តិ និងគុណវិបត្តិ។ ទន្ទឹមនឹងនោះដែរ ប្រសិនបើនីតិវិធីនីមួយៗមិនត្រូវបានធ្វើឡើងដោយភាពត្រឹមត្រូវ ច្បាស់លាស់ និងឆាប់រហ័សទេនោះ អាចផ្តល់ផលប៉ះពាល់ទៅដល់សិទ្ធិមនុស្ស និងសិទ្ធិរបស់ជនរងគ្រោះយ៉ាងធ្ងន់ធ្ងរ។

# អនុសាសន៍

ក្រោយពីឆ្លងកាត់តាមការស្រាវជ្រាវ និងបកស្រាយជាច្រើនអំពីគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់របស់តំណាងអយ្យការនេះ សង្កេតឃើញថា ការសម្រេចចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការរបស់តំណាងអយ្យការពិតជាមានសារៈសំខាន់ណាស់។ ដោយហេតុថា ដើម្បីចោទប្រកាន់បុគ្គលណាម្នាក់ទៅបានលុះត្រាតែមានការគោរពតាមនីតិវិធីព្រហ្មទណ្ឌទាំងអស់ បើមិនដូច្នេះទេ នឹងមានការលើកឡើងដោយជនល្មើសនូវការអនុវត្តនីតិវិធីខុស ដែលជាហេតុនាំឱ្យមោឃភាពនីតិវិធីទាំងអស់។ ចំណុចនេះបង្ហាញឱ្យឃើញច្បាស់ថាការអនុវត្តនីតិវិធីព្រហ្មទណ្ឌនេះ ពិតជាទាមទារឱ្យមានការអនុវត្តយ៉ាងហ្មត់ចត់ ដោយមិនអាចអនុវត្តឱ្យខុសនីតិវិធីបានទេ។ ផ្ទុយមកវិញ ប្រសិនបើមានការអនុវត្តខុសនីតិវិធី នឹងធ្វើឱ្យមានការខាតបង់ទាំងពេលវេលា និងថវិកាទាំងរបស់តុលាការ និងរបស់ភាគីផងដែរ។ ដើម្បីពង្រឹង និងធានានូវការអនុវត្តតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាត្រូវបំពេញតួនាទីដោយឈរលើគោលការណ៍៖

**១. ចំពោះការតម្កល់រឿងទុកឥតចាត់ការ៖** ដើម្បីឱ្យសេចក្ដីសម្រេចដែលព្រះរាជអាជ្ញាបានសម្រេចនេះ ជាសេចក្ដីសម្រេចមួយដ៏ត្រឹមត្រូវ ព្រះរាជអាជ្ញាគួរគប្បីធ្វើការពិនិត្យស៊ើបអង្កេតឱ្យបានច្បាស់លាស់ និងថ្លឹងថ្លែងអំពីចំណាត់ការឱ្យបានតឹងរ៉ឹងជាទីបំផុត ដោយស្របតាមច្បាប់ ឬបទប្បញ្ញត្តិជាធរមាន ហើយត្រូវបញ្ជាក់យ៉ាងច្បាស់លាស់អំពីសំអាងហេតុ និងសំអាងច្បាប់ ក្នុងគោលបំណងដើម្បីឱ្យម្ចាស់បណ្ដឹង ឬសាធារណៈជន យល់ពីមូលហេតុនៃការសម្រេចតម្កល់រឿងទុកឥតចាត់ការ និងទទួលយកនូវសេចក្ដីសម្រេចនោះបាន។ ការធ្វើដូចនេះ ក៏អាចសម្រួលដល់កំណើននៃការប្ដឹងឧទ្ធរណ៍ ដោយហេតុថាភាគីអាចទទួលបាន និងយល់អំពីមូលហេតុដែលព្រះរាជអាជ្ញាសម្រេចសេចក្ដីនេះ។

**២. ចំពោះការចោទប្រកាន់៖** ដើម្បីឱ្យការអនុវត្តរបស់ព្រះរាជអាជ្ញា ស្របតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញា គប្បីវិនិច្ឆ័យទៅលើជម្រើសនៃការចោទប្រកាន់ឱ្យបានត្រឹមត្រូវ នឹងអនុវត្តន៍នូវនីតិវិធីទាំងនោះ ឱ្យបានស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ម្យ៉ាងទៀត ព្រះរាជអាជ្ញាក៏ត្រូវពិនិត្យរាល់កិច្ចការ របស់ឋានានុក្រមថ្នាក់ក្រោមរបស់ខ្លួន ដើម្បីធានាឱ្យបាននូវការអនុវត្តត្រឹមត្រូវតាមច្បាប់ជាធរមាន។ ការធ្វើដូចនេះដើម្បីឱ្យមានភាពយុត្តិធម៌ ការវិនិច្ឆ័យដ៏ត្រឹមត្រូវ ហើយនឹងមិនអាចធ្វើឱ្យមានការប៉ះពាល់ដល់សិទ្ធិរបស់ជនល្មើស និងជនរងគ្រោះឡើយ។

# ឯកសារយោង

## I. លិខិតបទដ្ឋានគតិយុត្តជាតិ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

២. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

៤. ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការនៃព្រះរាជាណាចក្រកម្ពុជា ប្រកាលឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

៥. ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញានៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

៦. ច្បាប់ស្ដីពីយុត្តិធម៌អនីតិជននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦

## II. លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

១. គោលការណ៍ណែនាំស្ដីពីតួនាទីរបស់ព្រះរាជអាជ្ញា អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី ស្ដីអំពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស នាទីក្រុង ហាវ៉ាណា នៃប្រទេសគុយបា នៅថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩០

## III. ឯកសារជាសៀវភៅ

១. លោកសាស្ត្រាចារ្យ **ហ៊ី សោភា**, ឯកសារមេរៀន "នីតិព្រហ្មទណ្ឌ"

២. លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធិ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, ឯកសារមេរៀន "នីតិវិធីព្រហ្មទណ្ឌ" ឆ្នាំសិក្សា២០១៣-២០១៤

៣. លោកសាស្ត្រាចារ្យ **មីន សំអុល**, ឯកសារមេរៀន "ចៅក្រមស៊ើបសួរ"

៤. លោក **ចក សម្បត្តិ** អនុប្រធានសមាគមត្រាជូ, "នីតិវិធីព្រហ្មទណ្ឌកម្ពុជា"

៥. លោកស្រី **ឌី លីឡា** និងលោក **ខាន់ សុខា**, ឯកសារមេរៀន "នីតិវិធីព្រហ្មទណ្ឌ"

## IV. ឯកសារពាក់ព័ន្ធផ្សេងទៀត

១. សេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែករបស់ក្រឡាបញ្ជី រៀបរៀង ចងក្រង និងកែសម្រួលដោយនាយកដ្ឋានកិច្ចការនីតិកម្មនៃក្រសួងយុត្តិធម៌ សម្រាប់កិច្ចប្រជុំថ្ងៃទី ១៧-១៨ ខែកញ្ញា ឆ្នាំ២០១២

# បញ្ជីរាយនាមឧបសម្ព័ន្ធ

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ០១ | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែករបស់ក្រឡាបញ្ជី |
| ០២ | គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា |
| ០៣ | ពាក្យបណ្តឹង |
| ០៤ | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ |
| ០៥ | លិខិតជូនដំណឹងស្តីពីការបិទបញ្ចប់ការស៊ើបសួរ |
| ០៦ | ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ |
| ០៧ | លិខិតជូនដំណឹងជនត្រូវចោទ |
| ០៨ | លិខិតជូនដំណឹងដើមបណ្តឹងរដ្ឋប្បវេណី |
| ០៩ | ដីកាសន្និដ្ឋានស្ថាពរ |
| ១០ | ដីកាដំណោះស្រាយ |
| ១១ | លិខិតជូនដំណឹងពីដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ |
| ១២ | ដីកាសម្រេចលើកលែងចោទប្រកាន់ |
| ១៣ | ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ |
| ១៤ | ដីកាសន្និដ្ឋានបញ្ជូនទៅជំនុំជម្រះផ្ទាល់ |
| ១៥ | កំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម |
| ១៦ | ដីកាតម្កល់រឿងទុកឥតចាត់ការ |
| ១៧ | លិខិតជូនដំណឹងអំពីការសម្រេចតម្កល់រឿងទុកឥតចាត់ការ |
| ១៨ | បណ្តឹងតវ៉ាដីកាតម្កល់រឿងទុកឥតចាត់ការ ទៅកាន់អគ្គព្រះរាជអាជ្ញា |
| ១៩ | ដីកាបញ្ជូន |
| ២០ | សេចក្តីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការ |
| ២១ | លិខិតជូនដំណឹងអំពីការសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការ |

# ឧបសម្ព័ន្ធ

# សេចក្តីព្រាងព្រះរាជក្រឹត្យ

# ស្តីពី

# លក្ខន្តិកៈដោយឡែករបស់ក្រឡាបញ្ជី

រៀបរៀង ចងក្រង និងកែសម្រួល
ដោយនាយកដ្ឋានកិច្ចការនីតិកម្មនៃក្រសួងយុត្តិធម៌

សម្រាប់កិច្ចប្រជុំថ្ងៃទី ១៧-១៨ ខែ កញ្ញា ឆ្នាំ ២០១២



Downloaded from http://www.khmerlaws.org

យើង

ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះចៅក្រុងកម្ពុជា

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីការបង្កើតគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៥/០១៩ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥ ស្តីអំពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ..........

សម្រេច



Downloaded from http://www.khmerlaws.org

## ជំពូកទី ១

### និយមន័យ មុខងារ និងស្ថានភាពនៅក្រៅក្របខណ្ឌដើម

មាត្រា ១.-

ត្រូវបានបង្កើតនូវអង្គក្រឡាបញ្ជីនៃសេវាយុត្តាធិការ ដែលស្ថិតក្នុងក្របខណ្ឌប្រភេទ «ខ» ដូចដែលមានកំណត់ឡើងដោយមាត្រា ៨ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍ទូទៅនៃមុខងារសាធារណៈរបស់រដ្ឋ។ ក្រឡាបញ្ជីអនុវត្តមុខងាររបស់ខ្លួនក្នុងសាលាជំរះក្តីគ្រប់ជាន់ថ្នាក់។ ក្រឡាបញ្ជីក៏អាចត្រូវបានប្រគល់ភារកិច្ចឱ្យបម្រើការងារក្នុងរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ក្នុងលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនិងក្នុងផ្នែករដ្ឋបាលផ្សេងៗរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

ក្រឡាបញ្ជីត្រូវបានជ្រើសរើស និងបណ្តុះបណ្តាលដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តធម៌ បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាល។

នៅក្នុងរយៈពេលបណ្តោះអាសន្នមុនលក្ខន្តិកៈនេះចូលជាធរមានក្រឡាបញ្ជីដែលកំពុងបំពេញមុខងារត្រូវទទួលការវាយតម្លៃដោយសាលាភូមិន្ទក្រឡាបញ្ជីនៃរាជបណ្ឌិតសភា វិជ្ជាជីវៈតុលាការ និងអាចទទួលការជ្រើសរើសបន្ទាប់ពីការបណ្តុះបណ្តាលបន្ត និងការប្រលងវិជ្ជាជីវៈមួយ។

មាត្រា ២.-

ក្រឡាបញ្ជីជាអ្នកបច្ចេកទេសផ្នែកនីតិវិធីដែលជួយដល់ចៅក្រមនៅក្នុងសកម្មភាពសាលាជំរះក្តីទៅតាមលក្ខខណ្ឌដែលមានកំណត់ក្នុងអត្ថបទច្បាប់ ឬបទបញ្ញាជាធរមាន។

ក្រឡាបញ្ជីត្រូវស្ថិតនៅក្រោមបង្គាប់នាយកក្រឡាបញ្ជីសម្រាប់កិច្ចការផ្នែករដ្ឋបាល និងនៅក្រោមបង្គាប់ចៅក្រម ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង សម្រាប់កិច្ចការផ្នែកយុត្តាធិការ និងមានតួនាទីភារកិច្ចទូទៅ និងដោយឡែកដូចខាងក្រោម ៖

- ចុះបញ្ជីនូវរាល់សំណុំរឿង ផ្តល់ដំណឹងដល់ភាគីនូវកាលបរិច្ឆេទសវនាការ និងពេលបញ្ចប់សវនាការ ត្រូវកត់ត្រាសរុបលើសំណុំរឿងដែលបានលើកយកមកដោះស្រាយពេលសវនាការ
- ចុះបញ្ជីសំណុំរឿង និងកាន់កាប់បញ្ជីស្ថិតិ
- ចុះបញ្ជីនូវរាល់ពាក្យប្តឹង និងរាល់កំណត់ហេតុសំណុំរឿង
- កត់ត្រានូវព្រឹត្តិការណ៍រឿង និងរៀបចំជាសេចក្តីសម្រេច
- ធ្វើជាជំនួយការចៅក្រមនាពេលសវនាការ



Downloaded from http://www.khmerlaws.org

- ជួយទៅក្រមអយ្យការក្នុងការរៀបចំសរសេរកំណត់ហេតុសំណុំរឿងផ្សេងៗ ឬនៅក្នុងអំឡុងពេលចុះទៅដល់ទីកន្លែងឃុំឃាំង
- ទទួលខុសត្រូវការរៀបចំសំណុំឯកសារ និងការស្រាវជ្រាវរកឯកសារផ្សេងៗ
- សរសេរសេចក្តីព្រាងលិខិតរឹបអូសតាមការចង្អុលបង្ហាញពីចៅក្រម ព្រមទាំងព្រាងដីកាផ្សេងៗ
- បញ្ជាក់ភាពពិត នូវរាល់លិខិតស្នាម និងសេចក្តីសម្រេចរបស់តុលាការ
- រក្សាទុកនូវកំណត់ហេតុអង្គប្រជុំ និងផ្តល់លិខិតចតចំលងនៃសេចក្តីសម្រេចរបស់តុលាការ
- មានកាតព្វកិច្ចរក្សាទុកនូវសំណៅឯកសារ និងសំណុំរឿងដែលបានបញ្ចប់ស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រឡាបញ្ជីនាយក
- កត់ត្រា និងរៀបចំជាកំណត់ហេតុដែលចុះហត្ថលេខាដោយចៅក្រមក្នុងពេលសវនាការ និងក្នុងពេលសួរចម្លើយផ្សេងៗ
- ជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ
- ទទួល និងចុះបញ្ជីនូវបណ្តឹងបន្ត
- កាន់កាប់បញ្ជីលិខិតថ្កោលទោស និងផ្តល់ជូននូវព្រឹត្តិប័ត្រលេខ ២ និង លេខ ៣
- អនុវត្តមុខងារផ្នែករដ្ឋបាល និងកិច្ចការគណនេយ្យគរដែលជាប់ពាក់ព័ន្ធដល់ការគ្រប់គ្រងក្រឡាបញ្ជីក្រោមអំណាចនាយកក្រឡាបញ្ជី និងក្រោមការដឹកនាំរបស់ប្រធានតុលាការ
- រៀបចំរបាយការណ៍ស្ថិតិប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ជានូវភាពអចិន្ត្រៃយ៍សម្រាប់សេវាតាមផ្នែកនីមួយៗ ជាពិសេសនាពេលចុងសប្តាហ៍ និងថ្ងៃឈប់សម្រាក
- តាមរយៈសារាចររបស់ក្រសួងយុត្តិធម៌ ឬតាមយន្តការសេចក្តីណែនាំផ្ទៃក្នុងនៃយុត្តាធិការ ការបញ្ជាក់ ឬការកែតម្រូវ ការអនុវត្តន៍ផ្សេងៗ អាចជាផ្នែកមួយនៃការប្រតិបត្តិតួនាទីរបស់ក្រឡាបញ្ជី
- កាលបណ្ឌិតសភាវិជ្ជាជីវៈតុលាការអាចចេញជាសេចក្តីណែនាំកំណត់ទិសដៅវិជ្ជាជីវៈដែលពាក់ព័ន្ធដល់ការប្រតិបត្តិរបស់ក្រឡាបញ្ជី។

មាត្រា ៣ .-

ក្រឡាបញ្ជីមិនមានសិទ្ធិផ្តល់ប្រឹក្សា ឬធ្វើជាតំណាងភាគីផ្សេងៗដែលជាសមត្ថកិច្ចរបស់មេធាវីនោះទេ។ ការមិនគោរពតាមបញ្ញត្តិនេះនឹងនាំឱ្យមានមោឃភាពលើលិខិតដែលបានចេញនោះ។



Downloaded from http://www.khmerlaws.org

# គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា

អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី ស្តីអំពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស នាទីក្រុង ហាវ៉ាណា នៃប្រទេសគុយបា នៅថ្ងៃទី ២៧ ខែ សីហា ដល់ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩០ ។

*ដោយហេតុថា* នៅក្នុងធម្មនុញ្ញរបស់អង្គសហប្រជាជាតិ ប្រជាពលរដ្ឋគ្រប់ជាតិសាសន៍នៅលើពិភពលោក បានអះអាងពីការប្តេជ្ញាចិត្តរបស់ខ្លួន ថានឹងបង្កើតនូវលក្ខខណ្ឌដែលអាចរក្សាបាននូវភាពយុត្តិធម៌ និងបានប្រកាសតាមគោលបំណងមួយក្នុងចំណោមគោលបំណងទាំងឡាយរបស់ខ្លួនអំពីការធ្វើឱ្យបានសម្រេចនូវកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការលើកស្ទួយ និងលើកទឹកចិត្តដល់ការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដោយឥតមានការបែងចែកពូជសាសន៍ ភេទ ភាសា ឬសាសនាឡើយ

*ដោយហេតុថា* សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស បានតំកល់ទុកនូវគោលការណ៍សមភាពចំពោះមុខច្បាប់ ការសន្មត់ជាមុនថាគ្មានទោសពៃរ៍ និងសិទ្ធិទទួលការជំនុំជំរះក្តីដ៏ត្រឹមត្រូវ និងជាសាធារណៈមួយ ពីតុលាការឯករាជ្យ និងមិនលំអៀង

*ដោយហេតុថា* ជាញឹកញាប់ នៅមានចន្លោះមួយរវាងទស្សនៈយល់ឃើញវែងឆ្ងាយដែលកំណត់គោលការណ៍ទាំងនោះជាមូលដ្ឋាន និងស្ថានការណ៍ពិត

*ដោយហេតុថា* ការរៀបចំ និងការគ្រប់គ្រងយុត្តិធម៌ នៅតាមបណ្តាប្រទេសទាំងឡាយ ត្រូវតែធ្វើតាមគោលការណ៍ទាំងនោះ ហើយត្រូវខិតខំប្រឹងប្រែងធ្វើការបកស្រាយគោលការណ៍ទាំងនោះឱ្យក្លាយជាការពិតយ៉ាងពេញលេញ

*ដោយហេតុថា* ព្រះរាជអាជ្ញាមានតួនាទីដ៏សំខាន់ក្នុងការគ្រប់គ្រងយុត្តិធម៌ និងវិធានច្បាប់នានា ដែលទាក់ទងទៅនឹងការអនុវត្តតាមការទទួលខុសត្រូវដ៏សំខាន់របស់ខ្លួន គួរតែលើកស្ទួយការគោរព និងការប្រតិបត្តិតាមរបស់ខ្លួនចំពោះគោលការណ៍ទាំងឡាយដែលបានពោលខាងលើ ដូច្នេះនាំឱ្យមានការចូលរួមចំណែកដើម្បីភាពយុត្តិធម៌ខាងព្រហ្មទណ្ឌដ៏សមរម្យ សមភាព និងដើម្បីប្រជាពលរដ្ឋ ឱ្យមានប្រសិទ្ធិភាពប្រឆាំងនឹងឧក្រិដ្ឋកម្ម ។

*ដោយហេតុថា* ជាការចាំបាច់ត្រូវធានាថា ព្រះរាជអាជ្ញាមានលក្ខណៈសម្បត្តិជំនាញដែលតម្រូវក្នុងការបំពេញមុខងាររបស់ខ្លួនឱ្យបានសម្រេច តាមរយៈរូបមន្តនៃការជ្រើសរើសដ៏ល្អប្រសើរ និងការហ្វឹកហ្វឺនផ្នែកច្បាប់ និងជំនាញ ហើយ និងតាមរយៈការផ្តល់នូវគ្រប់មធ្យោបាយចាំបាច់ ដើម្បីគោលការណ៍ណែនាំដូចមានចែងខាងក្រោមនេះ ដែលត្រូវបានរៀបចំឡើងយ៉ាងជាក់លាក់ដើម្បីជួយដល់រដ្ឋជាសមាជិកក្នុងការងាររបស់ខ្លួន ដើម្បីធានា និងលើកស្ទួយប្រសិទ្ធិភាព ភាពមិនលំអៀង និងភាពត្រឹមត្រូវរបស់ព្រះរាជអាជ្ញានៅក្នុងរឿងក្តីព្រហ្មទណ្ឌ គប្បីត្រូវបានគោរពតាម និងយកទៅពិចារណាដោយរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនៃនីតិកម្មជាតិ និងការអនុវត្តន៍របស់ខ្លួនហើយគួរតែផ្សព្វផ្សាយដល់ព្រះរាជអាជ្ញាព្រមទាំងអ្នកឯទៀតៗ ដូចជាចៅក្រម មេធាវី សមាជិកសាខាអង្គនីតិប្រតិបត្តិ អង្គនីតិបញ្ញត្តិ និងសាធារណៈជនជាទូទៅ ។ គោលការណ៍ណែនាំ បច្ចុប្បន្នត្រូវបានរៀបចំឡើងជាសំខាន់គឺសំដៅចំពោះព្រះរាជអាជ្ញាសាធារណៈ ក៏ប៉ុន្តែគោលការណ៍ ទាំងនេះអនុវត្ត

បានដោយស្មើភាពគ្នា ក្នុងលក្ខណៈសមស្របចំពោះព្រះរាជអាជ្ញាទាំងឡាយដែលត្រូវបានតែងតាំងឡើងនៅលើមូលដ្ឋានពិសេសផងដែរ ។

## លក្ខណសម្បត្តិ ការជ្រើសរើស និងការហ្វឹកហ្វឺន

១. ជនទាំងឡាយដែលត្រូវបានជ្រើសរើសធ្វើជាព្រះរាអាជ្ញា ត្រូវតែជាឯកត្តជនដែលមានសេចក្តីសុច្ចរិត និងមានសមត្ថភាព ព្រមទាំងមានការហ្វឹកហ្វឺន និងលក្ខណសម្បត្តិសមរម្យផង ។

២. រដ្ឋទាំងឡាយត្រូវធានាថា :

(ក) លក្ខណៈជ្រើសរើសព្រះរាជអាជ្ញា ត្រូវមានការការពារមិនឱ្យមានការតែងតាំងទាំងឡាយណាដែលឈរលើភាពលំអៀង ឬបុរេនិច្ឆ័យ ដោយបំបាត់ចោលនូវរាល់ការរើសអើងណាមួយ ប្រឆាំងនឹងបុគ្គលនៅលើមូលដ្ឋានពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត សញ្ជាតិដើម ឋានៈសង្គម ឬជាតិពន្ធ ទ្រព្យសម្បត្តិ ដើមកំណើត ឋានៈសេដ្ឋកិច្ច ឬឋានៈដទៃទៀត លើកលែងតែការតំរូវឱ្យបេក្ខជនសំរាប់ការិយាល័យអយ្យការនោះត្រូវតែមានសញ្ជាតិនៃប្រទេសសាមីប៉ុណ្ណោះ ដែលគេមិនត្រូវចាត់ទុកថាជាការរើសអើងឡើយ ។

(ខ) ព្រះរាជអាជ្ញាត្រូវមានការអប់រំ និងការហ្វឹកហ្វឺនត្រឹមត្រូវ ហើយត្រូវអោយយល់ដឹងអំពីឧត្តមគតិ និងករណីយកិច្ចប្រកបដោយសីលធម៌នតួនាទីរបស់ខ្លួន យល់ដឹងអំពីការការពាររដ្ឋធម្មនុញ្ញនឹងច្បាប់ចំពោះសិទ្ធិរបស់ជនជាប់សង្ស័យ និងជនរងគ្រោះ ហើយក៏ត្រូវយល់ដឹងអំពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលទទួលស្គាល់ដោយច្បាប់ជាតិនិងច្បាប់ អន្តរជាតិផង ។

## ឋានៈ និងលក្ខខណ្ឌនៃសេវាកម្ម

៣. ក្នុងនាមជាភ្នាក់ងារដ៏សំខាន់ក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ព្រះរាជអាជ្ញាត្រូវរក្សាខ្ជាប់គ្រប់ពេលវេលានូវកិត្តិយស និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈរបស់ខ្លួន ។

៤. រដ្ឋត្រូវធានាថា ព្រះរាជអាជ្ញាមានលទ្ធភាពអាចបំពេញមុខងារតាមវិជ្ជាជីវៈរបស់ខ្លួន ដោយគ្មានការបំភិតបំភ័យ ការបង្អាក់ ការយាយីរំខាន ការជ្រៀតជ្រែកមិនសមស្រប ឬដាក់ឱ្យទទួលខុសត្រូវខាងរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬវិស័យដទៃទៀតដោយមិនសមហេតុផល ។

៥. ព្រះរាជអាជ្ញា និងក្រុមគ្រួសាររបស់គេ ត្រូវតែមានកិច្ចការពារខាងផ្លូវកាយពីសំណាក់អាជ្ញាធរនៅពេលណាដែលសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេទទួលនូវការគំរាមកំហែង ដោយសារតែការបំពេញមុខងារជាព្រះរាជអាជ្ញានោះ ។

៦. ការកំណត់លក្ខខណ្ឌសេវាកម្មដ៏សមហេតុផលរបស់ព្រះរាជអាជ្ញា ប្រាក់ទូទាត់គ្រប់គ្រាន់ សំរាប់ការងារដែលបានធ្វើ និងនៅទីណាដែលអាចអនុវត្តបាន រយៈពេលកាន់មុខតំណែង ប្រាក់សោធន និងអាយុចូលនិវត្តន៍ ត្រូវតែមានចែងក្នុងច្បាប់ ឬវិធាន ឬបទបញ្ជាទាំងឡាយដែលបានចេញផ្សាយ ។

៧. ការតម្លើងឋានៈព្រះរាជអាជ្ញា នៅទីណាក៏ដោយដែលមានប្រព័ន្ធបែបនេះ ត្រូវផ្អែកលើកត្តាសត្យានុម័តនានាជាពិសេសគឺលក្ខណសម្បត្តិខាងវិជ្ជាជីវៈ សមត្ថភាព សេចក្តីសុច្ចរិត និងបទពិសោធន៍ ហើយត្រូវសំរេចឱ្យបានស្របតាមនីតិវិធីត្រឹមត្រូវ និងមិនលំអៀង ។

## សេរីភាពក្នុងការបញ្ចេញមតិ និងបង្កើតសមាគម

៨. ព្រះរាជអាជ្ញា ក៏ដូចជាប្រជាពលរដ្ឋដទៃទៀតដែរ គឺមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ជំនឿ ការបង្កើតសមាគម និងការប្រជុំ ។ ជាពិសេសព្រះរាជអាជ្ញាមានសិទ្ធិចូលរួមចំណែកក្នុងការពិភាក្សាជាសាធារណៈនូវរាល់បញ្ហាដែលទាក់ទង និងច្បាប់ ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ការជំរុញ និងការពារសិទ្ធិមនុស្ស ព្រមទាំងការចូលរួម ឬបង្កើតអង្គការប្រចាំតំបន់ អង្គការជាតិ ឬអន្តរជាតិ និងចូលរួមការប្រជុំរបស់គេ ដោយគ្មានការទទួលរងនូវការបាត់បង់ផលប្រយោជន៍ខាងវិជ្ជាជីវៈដោយសារតែមូលហេតុនៃសកម្មភាពស្របច្បាប់ ឬដោយសារសមាជិកភាពរបស់គេនៅក្នុងអង្គការស្របច្បាប់ណាមួយនោះឡើយ ។ ក្នុងការប្រើប្រាស់នូវសិទ្ធិទាំងអស់នេះ ព្រះរាជអាជ្ញាជានិច្ចជាកាលត្រូវប្រតិបត្តិខ្លួនឱ្យស្របតាមច្បាប់ និងបទដ្ឋានព្រមទាំងក្រមសីលធម៌ទាំងឡាយនៃវិជ្ជាជីវៈរបស់ខ្លួនដែលត្រូវបានគេទទួលស្គាល់ ។

៩. ព្រះរាជអាជ្ញា មានសិទ្ធិសេរីភាពក្នុងការចូលរួម និងបង្កើតសមាគមវិជ្ជាជីវៈ ឬអង្គការដទៃទៀត ដើម្បីតំណាងឱ្យផលប្រយោជន៍របស់ខ្លួន ដើម្បីលើកស្ទួយការហ្វឹកហ្វឺនវិជ្ជាជីវៈ ហើយ និងដើម្បីការពារឋានៈរបស់ខ្លួន ។

## តួនាទីព្រះរាជអាជ្ញាក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ

១០. តួនាទីអយ្យការត្រូវតែចែកឱ្យដាច់ពីមុខងារតុលាការ

១១. ព្រះរាជអាជ្ញាត្រូវដើរតួយ៉ាងសកម្មក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ រួមទាំងស្ថាប័នអយ្យការ ដែលច្បាប់អនុញ្ញាត ឬស្របតាមការអនុវត្តន៍ក្នុងស្រុក ក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ពិនិត្យមើលនីត្យានុកូលភាពក្នុងការស៊ើបអង្កេតនានា ពិនិត្យមើលការអនុវត្តន៍សាលក្រម និងការបំពេញតួនាទីផ្សេងៗទៀត ដោយតំណាងឱ្យផលប្រយោជន៍សាធារណៈ ។

១២. ព្រះរាជអាជ្ញាត្រូវបំពេញតួនាទីភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់ និងឱ្យបានឆាប់រហ័ស ស្របតាមច្បាប់កំណត់ ហើយត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស និងលើកកំពស់សិទ្ធិមនុស្ស ហេតុដូច្នេះ ត្រូវរួមជាវិភាគទានក្នុងការធានាដល់កិច្ចដំណើរការនៃប្រព័ន្ធយុត្តិធម៌ឱ្យបានត្រឹមត្រូវ និងមានភាពរលូន ។

១៣. ក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាត្រូវ :

(ក) អនុវត្តមុខនាទីរបស់ខ្លួន ដោយមិនលំអៀង និងជៀសវាងរាល់ការរើសអើងភេទ វប្បធម៌ ជាតិសាសន៍ សាសនា ឋានៈសង្គម នយោបាយ ឬការរើសអើងណាមួយផ្សេងទៀត ។

(ខ) ការពារផលប្រយោជន៍សាធារណៈ យកចិត្តទុកដាក់ចំពោះជនសង្ស័យ និងជនរងគ្រោះដោយមិនលំអៀង និងត្រូវប្រុងប្រយ័ត្នគ្រប់ស្ថានភាពដែលពាក់ព័ន្ធទាំងអស់ ទោះជាស្ថានភាពនោះមានប្រយោជន៍ ឬឥតមានប្រយោជន៍ដល់ជនសង្ស័យក៏ដោយ ។

(គ) រក្សារឿងក្តីជាការសម្ងាត់ លើកលែងតែត្រូវបំពេញភារកិច្ច ឬបើពុំដូច្នោះទេ គឺជាតំរូវការរបស់តុលាការដើម្បីបញ្ជាក់ពីភាពយុត្តិធម៌ ។

(ឃ) ពិនិត្យមើលពីទិដ្ឋភាពទូទៅ និងក្តីបារម្ភរបស់ជនរងគ្រោះ នៅពេលដែលមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគេ និងបញ្ជាក់ប្រាប់ពីសិទ្ធិរបស់ជនរងគ្រោះដល់ជនរងគ្រោះ ដើម្បីឱ្យស្របតាមសេចក្តីប្រកាស្តីពីគោលការណ៍យុត្តិធមិជាមូលដ្ឋានរបស់ជនរងគ្រោះ ក្នុងរឿងព្រហ្មទណ្ឌ និងការរំលោភអំណាច ។

១៤. ព្រះរាជអាជ្ញាមិនត្រូវផ្តើមគំនិតចោទប្រកាន់ ឬបន្តចោទប្រកាន់ ឬមិនត្រូវខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីតំកល់រឿងមិនចាត់ការ នៅពេលដែលការស៊ើបអង្កេតដោយលំអៀងមួយ បង្ហាញឱ្យឃើញថា ការចោទប្រកាន់នេះពុំមានមូលដ្ឋាន ។

១៥. ព្រះរាជអាជ្ញា ត្រូវផ្តល់ការយកចិត្តទុកដាក់លើការធ្វើបណ្តឹងអាជ្ញាចំពោះមន្ត្រីសាធារណៈដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ជាពិសេសពីអំពើពុករលួយ ការរំលោភអំណាច ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ឬបទឧក្រិដ្ឋដទៃៗទៀតដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ ហើយ និងការស៊ើបអង្កេតអំពីបទល្មើសទាំងនេះ នៅទីណាដែលមានការអនុញ្ញាតិដោយច្បាប់ ឬស្របទៅនឹងការអនុវត្តន៍តាមតំបន់ ។

១៦. នៅពេលណាដែលព្រះរាជអាជ្ញាទទួលបាននូវភស្តុតាងប្រឆាំងចំពោះជនជាប់សង្ស័យ ដែលគេដឹង ឬមានជំនឿលើមូលដ្ឋានសមហេតុផលថា ភស្តុតាងទាំងនោះបានមកដោយប្រើប្រាស់វិធីមិនស្របច្បាប់ ដែលអាចចាត់ទុកបានថាជាការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្សរបស់ជនជាប់សង្ស័យ ជាពិសេសទាក់ទងទៅនឹងការធ្វើទារុណកម្ម ឬទណ្ឌកម្ម ឬប្រព្រឹត្តកម្មកាចសាហាវអមនុស្សធម៌ និងបន្ថោកបន្ទាប ឬការរំលោភសិទ្ធិមនុស្សផ្សេងៗទៀតនោះ ព្រះរាជអាជ្ញាត្រូវបដិសេធ មិនប្រើភស្តុតាងបែបនោះប្រឆាំងនឹងជនណាម្នាក់ឡើយ ក្រៅពីអ្នកដែលបានប្រើវិធីបែបនោះខ្លួនឯង ឬត្រូវជំរាបដល់តុ លាការតាមនោះ ហើយត្រូវចាត់គ្របវិធានការចាំបាច់ទាំងអស់ដើម្បីធានាថា អ្នកដែលទទួលខុសត្រូវចំពោះការប្រើវិធី បែបនោះ ត្រូវបាននាំខ្លួនមកកាន់តុលាការ ។

## មុខងារឆន្ទានុសិទ្ធិ

១៧. នៅបណ្តាប្រទេសទាំងឡាយដែលព្រះរាជអាជ្ញាត្រូវបានប្រគល់ឱ្យនូវមុខការឆន្ទានុសិទ្ធិ ច្បាប់វិធាន ឬបទបញ្ជាទាំងឡាយដែលបានចេញផ្សព្វផ្សាយ ត្រូវមានចែងអំពីគោលការណ៍ណែនាំដើម្បីលើកស្ទួយភាពយុត្តិធម៌ត្រឹមត្រូវ និងមិនប្រែប្រួលនៃវិធីធ្វើសេចក្តីសំរេចនានា ក្នុងដំណើរការធ្វើបណ្តឹងអាជ្ញា ដោយរួមទាំងការចាប់អនុវត្តន៍ ឬការលប់ចោលបណ្តឹងអាជ្ញានោះផង ។

## ជំរើសផ្សេងៗក្នុងការធ្វើបណ្តឹងអាជ្ញា

១៨. ស្របតាមច្បាប់ជាតិ ព្រះរាជអាជ្ញាត្រូវធ្វើការពិចារណាសមស្រប ក្នុងការលប់ចោលបណ្តឹងអាជ្ញា បញ្ឈប់ការរឿងក្តីដោយមានភ្ជាប់លក្ខ័ណ ឬដោយឥតលក្ខ័ណ ឬដោយបង្វែររឿងព្រហ្មទណ្ឌចេញពីប្រព័ន្ធយុត្តិធម៌ជាផ្លូវការ ដោយគោរពយ៉ាងពេញលេញដល់សិទ្ធិរបស់ជនជាប់សង្ស័យ និងជនរងគ្រោះ ។ តាមគោលបំណងនេះ រដ្ឋទាំងឡាយត្រូវរិះរកលទ្ធភាពឱ្យបានពេញលេញក្នុងការអនុម័តយកតាមគំរោងការណ៍បង្វែរ ដែលមិនត្រឹមតែជួយសំរាលបន្ទុកដ៏ច្រើនលើសលប់របស់តុលាការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយជៀសវាងបាននូវភាពអាប់យសពីការឃុំខ្លួនមុនការជំនុំជំរះក្តីពីដីកាចោទប្រកាន់ និងពីការកាត់ឱ្យជាប់ទោស ព្រមទាំងពីផលមិនល្អដែលអាចកើតមានពីការដាក់ឱ្យជាប់ពន្ធនាគារទៀតផង ។

១៩. នៅបណ្តាប្រទេសទាំងឡាយដែលព្រះរាជអាជ្ញាត្រូវបានគេផ្តល់ឱ្យនូវមុខការឆន្ទានុសិទ្ធិដូចជាការសំរេចថាតើត្រូវបណ្តឹងអាជ្ញាចំពោះយុវជនប្រព្រឹត្តបទល្មើស ឬអត់នោះ គេត្រូវតែផ្តោតការពិចារណា ពិសេស១ទាំងឡាយទៅលើប្រភេទ និងទម្ងន់នៃបទល្មើស ទៅលើកិច្ចការពារសង្គម ទៅលើបុគ្គលិកលក្ខណៈ និងសាវតារបស់យុវជននោះសិន ។ ក្នុងការធ្វើសេចក្តីសំរេចនោះ ព្រះរាជអាជ្ញា ជាពិសេសត្រូវពិចារណាអំពីជំរើសផ្សេង១ដែលអាចមាន ដើម្បីជំនួសឱ្យការធ្វើបណ្តឹង អាជ្ញាក្រោមច្បាប់ និងនីតិវិធីទាំងឡាយដែលពាក់ព័ន្ធស្តីពីយុត្តិធម៌សំរាប់យុវជន ។ ព្រះរាជអាជ្ញាត្រូវព្យាយាមខិតខំឱ្យអស់ ពីលទ្ធភាពរបស់ខ្លួន ក្នុងការចាត់វិធានការធ្វើបណ្តឹងអាជ្ញាចំពោះអនីតិជនតែនៅពេលណាដែលចាំបាច់ជាអប្បបរិមាប៉ុណ្ណោះ ។

## ទំនាក់ទំនងជាមួយក្រសួង ឬស្ថាប័នផ្សេងៗរបស់រដ្ឋាភិបាល

២០. ដើម្បីធានាបាននូវភាពត្រឹមត្រូវ និងមានប្រសិទ្ធិភាពក្នុងការធ្វើបណ្តឹងអាជ្ញា ព្រះរាជអាជ្ញាត្រូវខិតខំឱ្យអស់ពីសមត្ថភាពក្នុងកិច្ចសហការជាមួយ នគរបាល តុលាការ មេធាវី អ្នកការពារក្តី សាធារណៈ ហើយ និងជាមួយក្រសួង ឬស្ថា ប័នផ្សេង១ទៀតរបស់រដ្ឋាភិបាល ។

## ដំណើរការដាក់ទណ្ឌកម្មផ្នែកវិន័យ

២១. បទល្មើសនឹងវិន័យរបស់ព្រះរាជអាជ្ញា ត្រូវផ្អែកទៅលើច្បាប់ ឬបទបញ្ញាស្របច្បាប់នានា ។ បណ្តឹងតវ៉ាប្រឆាំងនឹងព្រះរាជអាជ្ញាដែលចោទថា ព្រះរាជអាជ្ញានោះបានប្រព្រឹត្តយ៉ាងប្រត្យ័ក្សក្នុងលក្ខណៈមួយប្រាសចាកពីបទដ្ឋានវិជ្ជាជីវៈ ត្រូវតែដោះស្រាយឱ្យបានឆាប់រហ័ស និងត្រឹមត្រូវក្រោមនីតិវិធីសមស្រប ។ ព្រះរាជអាជ្ញាមានសិទ្ធិទទួលសវនាការដ៏ត្រឹមត្រូវមួយ ។ សេចក្តីសំរេច ត្រូវស្ថិតនៅក្រោមការពិនិត្យមើលឡើងវិញដែលប្រកបដោយឯករាជ្យភាព ។

២២. ដំណើរការដាក់ទណ្ឌកម្មផ្នែកវិន័យលើព្រះរាជអាជ្ញា ត្រូវធានានូវការវាយតម្លៃ និងការសំរេចដែលមានសត្យានុម័ត ។ ការដាក់ទណ្ឌកម្ម នឹងត្រូវកំណត់សំរេចដោយស្របតាមច្បាប់ ស្របតាមបទវិន័យវិជ្ជាជីវៈ និងស្របតាមបទដ្ឋាន និងក្រមសីលធម៌ឯទៀតដែលបានបង្កើតឡើង ហើយ និងស្របទៅតាមគោលការណ៍ណែនាំបច្ចុប្បន្ននេះផង ។

## ការប្រតិបត្តិតាមគោលការណ៍ណែនាំ

២៣. ព្រះរាជអាជ្ញាត្រូវគោរពតាមគោលការណ៍ណែនាំបច្ចុប្បន្ននេះ ។ គេក៏ត្រូវបង្ការ ព្រមទាំងប្រឆាំងឱ្យបានសកម្មទល់នឹងការរំលោភណាមួយដែលកើតមាន ឱ្យអស់ពីលទ្ធភាពដែលខ្លួនអាចធ្វើទៅបានផងដែរ ។

២៤. ព្រះរាជអាជ្ញាទាំងឡាយណាដែលជឿដោយមានហេតុផលគួរជឿថា មានការរំលោភណាមួយទៅលើគោលការណ៍ណែនាំបច្ចុប្បន្នបានកើតឡើង ឬជិតនឹងកើតឡើងនោះ ត្រូវរាយការណ៍អំពីបញ្ហានោះដល់អាជ្ញាធរថ្នាក់លើរបស់ខ្លួន ហើយនៅទីណាដែលចាំបាច់ ត្រូវរាយការណ៍ដល់អាជ្ញាធរ ឬអង្គការសមស្របនានា ដែលត្រូវបានគេប្រគល់អំណាចឱ្យដើម្បីដោះស្រាយ ឬដើម្បីពិនិត្យមើលឡើងវិញ ។

RULE

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

| អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ | |
|---|---|
| ចូល | លេខ........ <br> ថ្ងៃទី........ខែ........ឆ្នាំ <br> ម៉ោង........................នាទី |

## ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ អាយុ ឆ្នាំ មានទីលំនៅផ្ទះលេខ អឺ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានី ។

**សូមគោរពចូលមក**

**ឯកឧត្តមព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ**

**សូមមេត្តាជ្រាប**

**កម្មវត្ថុៈ** សំណើសុំប្តឹង ១.ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជនជាតិ និង ២.ឈ្មោះ ភេទស្រី អាយុ ឆ្នាំ ជនជាតិ ដែលមានទីលំនៅ ភូមិ ឃុំ ស្រុក ពីបទ **រំលោភលើទំនុកចិត្ត និងឆបោកប្រាក់** ចំនួន ។

**មូលហេតុៈ** កាលពីអំឡុងឆ្នាំ ខ្ញុំបាទ រួមនិងឪពុករបស់ខ្ញុំបាទ បានចូលហ៊ុនរកស៊ីទិញលក់ដើមកៅស៊ូនៅខេត្ត ជាមួយក្រុមហ៊ុន ដែលឈ្មោះ ជាអគ្គនាយកក្រុមហ៊ុន ហើយបានព្រមព្រៀងគ្នាដោយភាគីឈ្មោះ ទទួលបាន % ចំណែករូបខ្ញុំបាទ និងឪពុកទទួលបាន % ការរកស៊ីទិញលក់ដើមកៅស៊ូខាងលើនេះ គឺរូបខ្ញុំ និងឪពុកជាអ្នកចំណាយប្រាក់ទាំងអស់ រីឯឈ្មោះ គ្រាន់តែឈរឈ្មោះតែប៉ុណ្ណោះ ។ បន្ទាប់ពីមានការព្រមព្រៀងគ្នារួចហើយ ខ្ញុំបាទ និងឪពុកបានផ្ញើប្រាក់ឲ្យទៅក្រុមហ៊ុន តាមរយៈធនាគារ និងធនាគារ ដែលមានឈ្មោះ , ឈ្មោះ និងឈ្មោះ ជាអ្នកទទួលសាច់ប្រាក់ដោយផ្ទាល់សរុបចំនួន ។ ក្រោយពីទទួលប្រាក់រួចហើយ ឈ្មោះ បានដំណើរការកាប់ដើមកៅស៊ូយកទៅលក់ជាបន្តបន្ទាប់ ប៉ុន្តែមិនបានបង្វិលប្រាក់ដើម និងប្រាក់ចំណេញមកឲ្យខ្ញុំបាទឡើយ ដោយពួកគេមានចេតនាគេចវេស និងគេចខ្លួនរហូត ។




ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
ខេត្តកំពង់ស្ពឺ
លេខ៖ ១៩៨៦ អ.យ/២១

# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

យើង [redacted] តំណាងអយ្យការ អមសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ៖ ១១៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញ ពាក្យបណ្ដឹង ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២១ របស់[1]ឈ្មោះ [redacted]។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**យល់ឃើញថា មានតម្រុយសន្និដ្ឋានថា៖**

-នាម-គោត្តនាម: [redacted] ហៅ [redacted] ហៅ [redacted] ភេទប្រុស អាយុ៥៥ឆ្នាំ មុខរបរនាយរងទីចាត់ការអភិវឌ្ឍ អគ្គបញ្ជាការដ្ឋាន នៃក្រសួងការពារជាតិ ទីលំនៅបច្ចុប្បន្ននៅភូមិតាព្រហ្ម សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ (គ្មានខ្លួន)

បានប្រព្រឹត្តអំពើដូចតទៅ[2]៖ កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ វេលាម៉ោង០៩ព្រឹក ឈ្មោះ [redacted] ភេទស្រី អាយុ៤១ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ៥៥ឆ្នាំ បានជិះរថយន្តជាមួយគ្នា គោលបំណងទៅកងរាជអាវុធហត្ថខេត្តកណ្ដាល ដោយឈ្មោះ [redacted] ជាអ្នកបើករថយន្ត លុះពេលធ្វើដំណើរជិតដល់រង្វង់មូលក្រុងតាខ្មៅ ឈ្មោះ [redacted] និងឈ្មោះ [redacted] បានទាស់ពាក្យសំដីជាមួយគ្នា ស្រាប់តែឈ្មោះ [redacted] ខឹង ក៏បានឈប់រថយន្ត រួចធ្វើសកម្មភាពវាយទៅលើឈ្មោះ [redacted] ជាច្រើនដៃត្រូវចំមុខ, ភ្នែក, ថ្ពាម, ចង្កា និងទ្រូង ព្រមទាំងយកកាំភ្លើងគំរាមបាញ់បំបាក់ជើងឈ្មោះ [redacted] ថែមទៀត ប្រសិនបើឈ្មោះ [redacted] ហ៊ានចុះពីលើរថយន្ត។ បន្ទាប់មកឈ្មោះ [redacted] បានបើករថយន្តដឹកឈ្មោះ [redacted] ឡើងមកភ្នំពេញ រួចបន្តដំណើរមកដល់សង្កាត់កណ្ដាលជុំ ខេត្តកំពង់ស្ពឺ ដោយពេលធ្វើដំណើរតាមផ្លូវឈ្មោះ [redacted] បានវាយធ្វើបាបឈ្មោះ [redacted] ជាច្រើនដៃបន្ថែមទៀត បណ្ដាលឱ្យមានរបួសស្នាម និងបានដឹកឈ្មោះ [redacted] បន្តមកផ្ទះកូនចៅរបស់ខ្លួនឈ្មោះ [redacted] ស្ថិតនៅភូមិទឹកចេញ ឃុំ

---

១.បណ្ដឹងផ្ទាល់

២.សេចក្ដីសង្ខេបអង្គហេតុ

ព្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ និងបានបង្ខាំងឈ្មោះ [redacted] ទុកនៅក្នុងបន្ទប់នៃផ្ទះនោះ តាំងពីម៉ោង១៥ និង០០នាទីរសៀល ដល់ម៉ោង១៩ និង០០នាទី ដោយឈ្មោះ [redacted] អង្គុយនៅមុខផ្ទះ មិនឲ្យឈ្មោះ [redacted] ចេញពីផ្ទះនោះទេ រហូតដល់មានសមត្ថកិច្ចនគរបាលមកដល់ ទើបសមត្ថកិច្ចបាននាំឈ្មោះ [redacted] ចេញពីផ្ទះនោះមកព្យាបាលរបួសនៅមន្ទីរពេទ្យ។ ក្រោយចេញពីមន្ទីរពេទ្យ ឈ្មោះ [redacted] ក៏បានមកដាក់ពាក្យបណ្ដឹងនៅអយ្យការខេត្តកំពង់ស្ពឺ ចាត់ការតាមនីតិវិធីច្បាប់។

-អំពើខាងលើជាបទល្មើសៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងបង្ខាំងដោយខុសច្បាប់ ប្រព្រឹត្តនៅក្រុងតាខ្មៅ ខេត្តកណ្ដាល និងនៅខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា ២៥៣ ចំណុច១ នៃក្រមព្រហ្មទណ្ឌ។

បានឃើញ មាត្រា ៨៨ និងមាត្រា ១២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**<u>សម្រេច</u>**

-បើកការស៊ើបសួរលើអង្គហេតុខាងលើ និង ៖

☑ ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ[៣] ៖

-ឈ្មោះ [redacted] ហៅ [redacted] ហៅ [redacted] ភេទប្រុស អាយុ៥៥ឆ្នាំ។

<u>ពីបទ</u>ៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងបង្ខាំងដោយខុសច្បាប់ តាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា ២៥៣ ចំណុច១ នៃក្រមព្រហ្មទណ្ឌ។

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៤] ៖ ..............................។

☑ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន[៥] ៖ *លើឈ្មោះ ខាងលើដើម្បីបង្ការ ឬបញ្ចប់បទល្មើស កុំឱ្យកើតឡើងជាថ្មី និងធានាវត្តមានជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ។*

*ថ្ងៃ អង្គារ ៥ កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤*

*កំពង់ស្ពឺ ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០២១*

**តំណាងអយ្យការ**

[redacted]

---

៣.ឈ្មោះជនត្រូវចោទ

៤.កាតព្វកិច្ចណាមួយដែលមានចែងនៅក្នុងមាត្រា ២២៣

៥.មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នដែលមានចែងក្នុងមាត្រា ២០៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រឡាបញ្ជី
បន្ទប់អក្សរ "ហ" ជាន់ទី៥

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ហ"

លេខ.......ហ.ព្រទ

# លិខិតជូនដំណឹង
# ស្តីពីការបិទបញ្ចប់ការស៊ើបសួរ

**យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ**

បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: អ.យ.គ ចុះថ្ងៃទី ខែ ឆ្នាំ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ សំណុំរឿងស៊ើបសួរលេខ: ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

ជម្រាបមក តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ជ្រាបថា:

ត្បិតសំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ នោះយើងបានចាត់ការស៊ើបសួរចប់សព្វគ្រប់ហើយ ។

ហេតុដូច្នេះសូម តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ជ្រាបជាដំណឹង ។

ថ្ងៃអង្គារ ១៣រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩
**ចៅក្រមស៊ើបសួរ**

**យោបល់របស់តំណាងអយ្យការ**

[illegible]..........

..........

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៩
**ជ.ព្រះរាជអាជ្ញា**
[illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**បន្ទប់ស៊ើបសួរ "ហ"**

# ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ

លេខ ...... "ហ" ព្រទ **យើង** **ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ**

បានឃើញ មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: អ.យ.គ ចុះថ្ងៃទី ខែ ឆ្នាំ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ សំណុំរឿងស៊ើបសួរលេខ: ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

*ដែលទាក់ទងនឹងជនត្រូវចោទ៖*

១-ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជនជាតិ មុខរបរ ទីកន្លែងកំណើត ភូមិ ឃុំ ស្រុក ខេត្ត ទីលំនៅបច្ចុប្បន្ន ភូមិ ឃុំ ស្រុក ខេត្ត ប្រពន្ធឈ្មោះ មានកូនចំនួន នាក់ ឪពុកឈ្មោះ "ស្លាប់" ម្ដាយឈ្មោះ "ស្លាប់" ជានីតិជន។

-ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ។

២-ឈ្មោះ ភេទស្រី អាយុ ឆ្នាំ ជនជាតិ មុខរបរ ទីកន្លែងកំណើត ភូមិ ឃុំ ស្រុក ខេត្ត ទីលំនៅបច្ចុប្បន្ន ភូមិ ឃុំ ស្រុក ខេត្ត ប្ដីឈ្មោះ មានកូនចំនួន នាក់ ឪពុកឈ្មោះ "រស់" ម្ដាយឈ្មោះ "រស់" ជានីតិជន។

-ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ។

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ: ឆបោក ប្រព្រឹត្តនៅ កាលពីឆ្នាំ តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

បញ្ជាឱ្យបញ្ជូនសំណុំរឿងស៊ើបសួរនេះទៅព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្ដីសន្និដ្ឋាន ឬផ្ដល់យោបល់ទៅតាមនីតិវិធី។

ថ្ងៃ...១៥...ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី...ខែកក្កដា ឆ្នាំ២០១៩

បានទទួលអនុវត្ត

ក្រឡាបញ្ជី

...រ

៩៩
31-7-2019

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
មន្ទីរស៊ើបសួរលេខ(គ)
លេខ ១៣៦៤/៤

## លិខិតជូនដំណឹងជនត្រូវចោទ

យើង ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល។

ជូនដំណឹងជនត្រូវចោទឈ្មោះ   ភេទប្រុស អាយុ ៣០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកធនាគារ អេស៊ីលីដា ទីលំនៅបច្ចុប្បន្ននៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល ។

ជ្រាបថា: ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល បានបិទការស៊ើបសួរសំណុំរឿងលេខ: ១៤៥០ អ.ក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ពីបទ: **ជេរប្រមាថជាសាធារណៈ និងហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៣០៧ និងមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។ ចៅក្រមស៊ើបសួរ បានបញ្ចប់ការស៊ើបសួរហើយ ។

អាស្រ័យហេតុនេះ សូមជ្រាបជាដំណឹង។

ថ្ងៃ...... ខែ...... ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
កណ្ដាល, ថ្ងៃទី២២ ខែ     ឆ្នាំ២០១៨
**ចៅក្រមស៊ើបសួរ**

យើង   បានប្រគល់លិខិត ជូនដំណឹងនេះដល់ឈ្មោះ
ទីលំនៅភូមិ   ឃុំ   ស្រុក   ខេត្ត   នៅថ្ងៃទី
ខែ   ឆ្នាំ   ផ្ដាល់ដៃរួច ហើយ។
ធ្វើនៅថ្ងៃទី   ខែ   ឆ្នាំ២០១៨
អ្នកទទួល   អ្នកប្រគល់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
បន្ទិរស៊ើបសួរលេខ(គ)
លេខ ១៣៦៦.......

## លិខិតជូនដំណឹងដើមបណ្ដឹងរដ្ឋប្បវេណី

យើង ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល។

ជូនដំណឹងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ភេទស្រី អាយុ ៤៤ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិព្រៃបាំង ឃុំស៊ីធរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។

ជ្រាបថា: ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល បានបិទការស៊ើបសួរសំណុំរឿងលេខ: ១៤៥០ អ.ក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ពីបទ: **ជេរប្រមាថជាសាធារណៈ និងហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៣០៧ និងមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។ ចៅក្រមស៊ើបសួរ បានបញ្ចប់ការស៊ើបសួរហើយ ។

អាស្រ័យហេតុនេះ សូមជ្រាបជាដំណឹង។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
កណ្ដាល ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨
**ចៅក្រមស៊ើបសួរ**

យើង...............................បានប្រគល់លិខិត ជូនដំណឹងនេះដល់ឈ្មោះ.............................
ទីលំនៅភូមិ......................ឃុំ......................ស្រុក......................ខេត្ត......................នៅថ្ងៃទី.......
ខែ...............ឆ្នាំ..........ផ្ដាល់ដៃរួច ហើយ។

ធ្វើនៅថ្ងៃទី..........ខែ................ឆ្នាំ២០១៨

អ្នកទទួល

អ្នកប្រគល់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូង ខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខៈ អ.ក

ចុះថ្ងៃទី**១២** ខែ**សីហា** ឆ្នាំ**២០២០**

**លេខៈ................ដក.សព.២១**

# ដីកាសន្និដ្ឋានស្ថាពរ

**យើង តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល**

–បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខៈ **១១០៣** អ.ក ចុះថ្ងៃទី**១៩** ខែ**សីហា** ឆ្នាំ**២០១៩**

–បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ **៣៣១** ដកសស.**២០** ចុះថ្ងៃទី**២៣** ខែ**មីនា** ឆ្នាំ**២០២០**

–បានឃើញ សំណុំរឿងស៊ើបសួរលេខៈ **០៨៥** សស ចុះថ្ងៃទី**៣០** ខែ**មីនា** ឆ្នាំ**២០២០** របស់សាលាដំបូងខេត្តកណ្តាល

–បានឃើញ លិខិតជូនពត៌មានបញ្ចប់ការស៊ើបសួរលេខៈ **៧៥៣** ចុះថ្ងៃទី**០២** ខែ**មីនា** ឆ្នាំ**២០២១**

–បានឃើញ ដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យលេខៈ **៨០៩** ចុះថ្ងៃទី**០៤** ខែ**មីនា** ឆ្នាំ**២០២១**

**ក្រោយពិនិត្យឯកសារខាងលើ**

**ឃើញថាៈ**

**នាម-គោត្តនាមៈ** ភេទស្រី អាយុ៦៥ឆ្នាំ មានទីលំនៅបច្ចុប្បន្នបុរីក្រែនជ្រោយចង្វារ ផ្ទះលេខ T48 ផ្លូវលេខ២ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ (ក្រៅឃុំ)

ត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យពីបទៈ **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិព្រែកសំរោង២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ។

**<u>ឃើញថា៖</u>**

កាលពីអំឡុងឆ្នាំ២០១៦ ឈ្មោះ ភេទស្រី អាយុ៣៨ឆ្នាំ បានទៅមើលថែឈ្មោះ ដែលត្រូវជាឪពុករបស់ឈ្មោះ ក្រោយមកឈ្មោះ និងឈ្មោះ ក៏មានទំនាក់ទំនងស្នេហាជាមួយគ្នា និងបានសាងសង់ផ្ទះមួយកន្លែងលើដីរបស់ឈ្មោះ និងបានបើកហាងលក់ដូរ ដែលស្ថិតនៅភូមិព្រែកសំរោង២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ។ លុះក្រោយមក ឈ្មោះ បានចេញទៅក្រៅប្រទេសបាត់។ រហូតដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ ឈ្មោះ ដែលត្រូវជាម្តាយរបស់ឈ្មោះ បានមកបណ្តេញឈ្មោះ ឱ្យចុះចេញពីផ្ទះដែល សាងសង់នោះ និងសន្យាថាមិនឱ្យឈ្មោះ ដើរចេញដោយដៃទទេនោះទេ។ លុះដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ស្រាប់តែឈ្មោះ រានចាក់សោរទ្វារផ្ទះរបស់ឈ្មោះ និងបានរុះរើឥវ៉ាន់ចេញពីផ្ទះ និងធ្វើឱ្យបាត់បង់ទ្រព្យសម្បត្តិមួយចំនួនទៀត។

## បានឃើញ:

–បានឃើញ ឯកសារដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង

–បានឃើញ ពាក្យបណ្តឹងរបស់ឈ្មោះ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩។

–បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: **៣៣១** ដកសស.២០ ចុះថ្ងៃទី**២៣ ខែមីនា** ឆ្នាំ**២០២០**

–បានឃើញ ដីកាបង្គាប់ចូលខ្លួន ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០

## យល់ឃើញថា៖

–តាមពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចបញ្ជាក់បានថា នៅថ្ងៃកើតហេតុជនត្រូវចោទឈ្មោះ ភេទស្រី អាយុ៦៥ឆ្នាំ ពិតជាបាន ប្រព្រឹត្តបទល្មើស **ធ្វើឱ្យខូចខាតដោយចេតនា** ពិតប្រាកដមែន ។

–អំពើប្រព្រឹត្តរបស់ជនត្រូវចោទ មានចេតនាទុច្ចរិតដែលធ្វើប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ និង ប៉ះពាល់ដល់របៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ ដែលច្បាប់បញ្ញត្តិអំពើនេះជាបទល្មើសព្រហ្មទណ្ឌ ។

–ជនត្រូវចោទជានីតិជន មានស្មារតីទទួលខុសត្រូវនូវអំពើ និងព្យសនកម្មដែលកើតចេញពីការប្រព្រឹត្តរបស់ខ្លួន ។

–មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ ភេទស្រី អាយុ៦៥ឆ្នាំ និង ពីបទ៖ **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិព្រែកសំរោង២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **៤១០** នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ

**ប្តឹងសុំទៅចៅក្រមស៊ើបសួរ:**

– បញ្ជូនជនត្រូវចោទ ឈ្មោះ ភេទស្រី អាយុ៦៥ឆ្នាំ (ក្រៅឃុំ)

ពីបទ៖ **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិព្រែកសំរោង២ ឃុំតាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានបញ្ញត្តិ ឱ្យផ្តន្ទាទោសតាមមាត្រា **៤១០** នៃក្រមព្រហ្មទណ្ឌ ទៅជំនុំជម្រះ ។

**ថ្ងៃ..........................ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤**

**ធ្វើនៅកណ្តាល, ចុះថ្ងៃទី............ខែមីនា ឆ្នាំ២០២១**

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**
លេខ................/២០

# ដីកាដំណោះស្រាយ

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ។

ដោយមានលោក ជាក្រឡាបញ្ជីអមផង។

**-បានឃើញ** បញ្ញត្តិមាត្រា **២៤៧**ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧,មាត្រា៣៦៨,មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ។

**-បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខៈ **១៨៣៨ អក** ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **១៣៦៣ ដកសស.២០** ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ ។

**-បានឃើញ** សំណុំរឿងស៊ើបសួរលេខៈ **៥១៨ សស** ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្ត កណ្តាល។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខៈ **៣២៦ ដក.សព** ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ ។

## ក្រោយពីបានស៊ើបសួរមូលចប់សព្វគ្រប់លើជនត្រូវចោទហើយ ឃើញថាៈ

ឈ្មោះ ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិព្រែកស្លែង ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី០៣ថ្មី ឪពុកឈ្មោះ ម្តាយឈ្មោះ នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (គេចខ្លួន)

ពបទ ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិត្រឡោកបែក ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១២ និង៣០នាទី សមត្ថកិច្ចបានទទួលព័ត៌មានថា មានមុខសញ្ញាកំពុងធ្វើសកម្មភាពជួញដូរគ្រឿងញៀនយ៉ាងសកម្ម នៅចំណុចភូមិត្រឡោកបែក ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល។ ក្រោយទទួលបានព័ត៌មាន សមត្ថកិច្ចបានចុះបង្ក្រាបដល់ទីតាំងរោងចាំចម្ការដែល ជនសង្ស័យស្នាក់នៅ ពេលឃើញសមត្ថកិច្ច ជនសង្ស័យឈ្មោះ បានជិះម៉ូតូរត់គេចខ្លួនបាត់ ដោយបន្សល់ទុកនៅវត្ថុតាង ថ្នាំញៀន ០១ កញ្ចប់ធំ ( ទម្ងន់ ៥,៣៨ ក្រាម) និងសម្ភារៈសម្រាប់ប្រើប្រាស់គ្រឿនញៀនមួយចំនួន។

## សំអាងហេតុ

១.ពិតជាមាននូវអំពើ ជួញដូរគ្រឿងញៀន ប្រាកដមែន ដោយកាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ ស្ថិតនៅភូមិត្រឡោកបែក ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល ជនត្រូវចោទឈ្មោះ បានធ្វើសកម្មភាពជួញដូរគ្រឿងញៀន។

២. តាមចម្លើយរបស់សាក្សីឈ្មោះ បានឆ្លើយថា ៖ ឈ្មោះ ត្រូវជាប្អូនជីដូនមួយរបស់ខ្លួន បានមកសុំខ្លួនស្នាក់នៅជាមួយបានប្រហែលកន្លះខែមុនថ្ងៃកើតហេតុ។ វាមកនៅជាមួយខ្លួន វាដេកនៅខាងក្រោមផ្ទះ ចំណែកខ្លួនដេកនៅខាងលើផ្ទះ។ ឈ្មោះ ពេលខ្លះហូបបាយ និងស្នាក់នៅជាមួយ តែពេលខ្លះវាមិននៅផ្ទះនោះទេ តែខ្លួនក៏មិនដឹងថាវាទៅណាដែរ។ នៅមុនពេលកើតហេតុប្រហែលជាបីបួនថ្ងៃ ឈ្មោះ បានទៅធ្វើរោងស្នាក់នៅម្នាក់ឯងនៅខាងក្រោយផ្ទះរបស់ខ្លួន ចម្ងាយប្រហែល១០០ម៉ែត្រ ពីផ្ទះរបស់ខ្លួន។ ឈ្មោះ ពេលនៅជាមួយខ្លួន គឺមិនមានប្រកបមុខរបរអ្វីនោះទេ គឺឃើញតែនៅផ្ទះ។ នៅពេលយូៗម្តង ខ្លួនឃើញមានគេមកជួបវានៅខាងក្រោមផ្ទះរបស់ខ្លួន តែក៏មិនដឹងថាគេមកជួបវាពីរឿងអ្វីនោះដែរ។ ពេលស្នាក់នៅជាមួយខ្លួន ពេលខ្លួនអត់មាន

លុយទិញម្ហូប ឈ្មោះ បានឲ្យលុយខ្លួនចំនួន ប្រាំពាន់រៀល ឬ មួយម៉ឺនរៀល ដើម្បីឲ្យខ្លួនទិញម្ហូបហូបទាំងអស់គ្នា។ នៅថ្ងៃកើតហេតុ ពេលហូបបាយថ្ងៃត្រង់រួច ខ្លួនបានឡើងទៅលើផ្ទះ ចំណែកឯឈ្មោះ បានជិះម៉ូតូចេញទៅបាត់។ បន្ទាប់មកមានកម្លាំងសមត្ថកិច្ចចុះមកផ្ទះរបស់ខ្លួន ហើយសួររកឈ្មោះ ហោយខ្លួនប្រាប់ថា វាទៅណាបាត់ហើយ ខ្លួនមិនដឹងនោះទេ។ សមត្ថកិច្ចបានសុំខ្លួនដើម្បីឆែកឆេរផ្ទះ ហើយបានរកឃើញថ្នាំញៀនចំនួនមួយកញ្ចប់ធំល្មមនៅក្នុងហោប៉ៅខោរបស់ឈ្មោះ ដែលព្យួរទុកនៅខាងក្រោមផ្ទះរបស់ខ្លួន និងសម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួនទៀត ព្រមទាំងកូនកាំបិតចំនួនបីដើម។

៣. ទាំងចម្លើយសាក្សី និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងនានាដែលឯកសារពាក់ព័ន្ធ មានភាពស៊ីសង្វាក់គ្នាដែលកំណត់បានថា ជនត្រូវចោទពិតជាបានប្រព្រឹត្តបទល្មើសប្រាកដមែន ។

៤. អំពើប្រព្រឹត្តរបស់ជនត្រូវចោទបានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និង របៀបរៀបរយសង្គម ។

៥.ជនត្រូវចោទជានីតិជន មានសមត្ថភាព និងលក្ខណៈសម្បត្តិគ្រប់គ្រាន់យល់ដឹងពីបច្ច័យដែលខ្លួនបានប្រព្រឹត្ត ជននេះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌចំពោះទង្វើរបស់ខ្លួន ដែលបានធ្វើសកម្មភាពប៉ះពាល់ដល់សង្គម ។

៦.មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ ដែលមានសាវតាជាតិដូចខាងលើពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិត្រឡោកបែក ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១១.តាមដីកាសន្និដ្ឋានស្ថាពរលេខ **៣២៦** ដកសព ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២០ ឃើញថាមាន សំអាងហេតុគ្រប់គ្រាន់ក្នុងការដាក់បន្ទុកលើជនត្រូវចោទ គប្បីតុលាការលើកយកមកពិចារណា ។

## ហេតុដូច្នេះសម្រេច

១. ចោទប្រកាន់ និងបញ្ជូនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិព្រែកស្លែង ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី០៣ថ្មី ឪពុកឈ្មោះ ម្តាយឈ្មោះ នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (គេចខ្លួន)

ពីបទ ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិត្រឡោកបែក ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ទៅជំនុំជម្រះតាមច្បាប់។

**២**.បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខៈ **១៨៣៨** អក ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ និងឯកសារជាភស្តុតាងដែលពាក់ព័ន្ធក្នុងសំណុំរឿងនេះទៅជំនុំជម្រះតាមច្បាប់។

ថ្ងៃ.................................ខែ.............ឆ្នាំជូត ទោសស័ក.ពស ២៥៦៤

ធ្វើនៅខេត្តកណ្តាល.ថ្ងៃទី.........ខែ............ឆ្នាំ២០២០

**ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

ថ្ងៃ.........................ខែ..........ឆ្នាំជូត ទោស័ក.ពស២៥៦៤

ធ្វើនៅខេត្តកណ្តាល.ថ្ងៃទី.........ខែ............ឆ្នាំ២០២០

**តំណាងអយ្យការ**

37/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ហ"

លេខ. ......ហ" ព្រទ

## លិខិតជូនដំណឹង
## ពីដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: អ.យ.ផ ចុះថ្ងៃទី ខែ ឆ្នាំ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**<u>សូមជម្រាបមក:</u>** លោក ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ និងឈ្មោះ មានការិយាល័យស្ថិតផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

ត្បិតសំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី ខែ ឆ្នាំ ដែលបានប្ដឹងចោទប្រកាន់ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ ឆ្នាំ ពីបទ: ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

នោះយើងបានចាត់ការស៊ើបសួរចប់សព្វគ្រប់អស់ហើយ និងបានបញ្ជូនសំណុំរឿងទៅជំនុំជម្រះតាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ... ... "ហ" ដជ ចុះថ្ងៃទី.......ខែកញ្ញា ឆ្នាំ២០១៩ រួចហើយ ។

អាស្រ័យហេតុនេះ សូមជ្រាបជាព័ត៌មាន ។

ថ្ងៃ ព្រហស្បតិ៍ ៧កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៥..ខែកញ្ញា ឆ្នាំ២០១៩
ចៅក្រមស៊ើបសួរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ ២៤៣០ ប-ដជ

ស្មន

# ដីកាសម្រេចលើកលែងចោទប្រកាន់

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

-បានឃើញ មាត្រា ២៤៧ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៥៧២៨ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២៤៦៩ អយម ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០១៧ ។

-បានឃើញសំណុំរឿងស៊ើបសួរលេខ ២៤៤០ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ។

-បានឃើញដីកាសន្និដ្ឋានស្ពាពរលេខ ១២១២ អយម ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

ក្រោយពីបានស៊ើបសួរ និងពិនិត្យសំណុំរឿងចប់សព្វគ្រប់ ៖

## សំអាងហេតុ

១. បច្ចុប្បន្ន ត្រូវបានតំណាងអយ្យការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃនៅក្នុងអំឡុងឆ្នាំ២០១២បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

២-តាមដីកាសន្និដ្ឋានស្ពាពរលេខ ១២១២ អយម ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្ដឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចលើកលែងចោទប្រកាន់លើជនត្រូវចោទខាងលើ ។

៣-ជនត្រូវចោទនៅតែពុំអាចរកអត្តសញ្ញាណឃើញ ដូចនេះតាមមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរត្រូវចេញដីកាលើកលែងចោទប្រកាន់តាមនីតិវិធី ។

## ហេតុដូច្នេះសម្រេច

-លើកលែងចោទប្រកាន់លើ បច្ចុប្បន្ន ត្រូវបានតំណាងអយ្យការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ ឆបោក ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃនៅក្នុងអំឡុងឆ្នាំ២០១២បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

ថ្ងៃ សុក្រ ១ កើត ខែពិសាខ ឆ្នាំចសំរឹទ្ធិស័ក ព.ស ២៥៦

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៨

ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ

លេខ: ១០៦៤ អ.យ.ម

បានទទួលដំណឹង

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៨

ឧ. ព្រះរាជអាជ្ញា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
ខេត្តបាត់ដំបង
លេខៈ...១៤១៥.........

# ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

យើង តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង

- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ១០២៦ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៦ ។
- បានឃើញមាត្រា ៤៣, ៤៦, ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

**ឃើញថា**

១-នាម-គោត្តនាមៈ ហៅ ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ មុខរបរ ជាងជួសជុលម៉ូតូ កើតនៅភូមិថ្កាស្លា ឃុំចំការសំរោង ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង កាន់សាសនាព្រះពុទ្ធ សព្វថ្ងៃរស់នៅភូមិអូរតាគាំ១ សង្កាត់ទួលតាឯក ក្រុង-ខេត្តបាត់ដំបង ឪពុកឈ្មោះ -រ- ម្ដាយឈ្មោះ -រ- នៅលីវ ជានីតិជន ទោសពីមុន គ្មាន កំរិតវប្បធម៌ថ្នាក់ទី ១០ ។

២-នាម-គោត្តនាមៈ ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ មុខរបរ ស៊ីឈ្នួលបើកបរ កើតនៅភូមិទួលតាឯក ឃុំទួលតាឯក ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង កាន់សាសនាព្រះពុទ្ធ សព្វថ្ងៃរស់នៅភូមិអូរតាគាំ១ សង្កាត់ទួលតាឯក សង្កាត់ស្វាយប៉ោ ខេត្តបាត់ដំបង ឪពុកឈ្មោះ -ស- ម្ដាយឈ្មោះ -រ- នៅលីវ ជា នីតិជន ទោសពីមុន គ្មាន កំរិតវប្បធម៌ថ្នាក់ទី ៨ ។

ត្រូវបានចោទប្រកាន់ពីបទ *ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន* ប្រព្រឹត្តនៅចំណុចក្រុមទី០៥ ភូមិអូរតាទៀក ឃុំតាគោក ស្រុកសំឡូត ខេត្តបាត់ដំបង កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតត្រាគ្រឿងញៀន ។

**ឃើញថា ៖** កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ វេលាម៉ោង ២១:០០នាទី ស្ថិតនៅចំណុចក្រុមទី៥ ភូមិអូរតាទៀង ឃុំតាគោក ស្រុកសំឡូត ខេត្តបាត់ដំបង កំលាំងអធិការដ្ឋាននគរបាលស្រុកកំរៀង បានធ្វើការបង្ការ បង្ក្រាប និងត្រួតពិនិអាវុធជាតិផ្ទុះ បង្ក្រាបបានករណី ប្រើប្រាស់គ្រឿងញៀន មួយករណី ហើយឃាត់ខ្លួនបានជនសង្ស័យបានចំនួន២នាក់ មានឈ្មោះ ហៅ ភេទប្រុស និងឈ្មោះ ភេទប្រុស រួចឆែកឆេររកឃើញថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន៤កូនថង់តូច ។ បន្ទាប់មកបានកសាងសំណុំរឿងបញ្ជូនជនសង្ស័យទាំងពីរនាក់មកកាន់តុលាការ ។

បានឃើញ

- របាយការណ៍លេខ ៧៥០ របក.នប ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ។

- ចម្លើយជនត្រូវចោទឈ្មោះ ហៅ នៅនគរបាល និងនៅអយ្យការមានន័យប្រហាក់ប្រហែលគ្នាថា៖ កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ខ្លួនបានទិញថ្នាំញៀនចំនួន២ទៅ៣ កញ្ចប់តូច ពីឈ្មោះ ញៀន ពេលទិញបានហើយ ខ្លួនក៏បានជិះឡានជាមួយឈ្មោះ ដើម្បីទៅប្រើប្រាស់ថ្នាំញៀន បន្ទាប់មកក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនបានតែម្តង ។

- ចម្លើយជនត្រូវចោទឈ្មោះ នៅនគរបាល និងនៅអយ្យការមានន័យប្រហាក់ប្រហែលគ្នាថា៖ កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ខ្លួនបានចូលលុយគ្នាជាមួយឈ្មោះ ហៅ ដើម្បីទិញថ្នាំញៀនយកប្រើប្រាស់ ពេលឈ្មោះ ហៅ ទិញបានហើយ ខ្លួននិងឈ្មោះ ហៅ បានជិះឡានទៅស្រុកសំឡូត ដើម្បីប្រើប្រាស់ថ្នាំញៀន រួចក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង ។

- កំណត់ហេតុទទួលវត្ថុតាងលេខ៖ ២០១វ.ត ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងខេត្តបាត់ដំបង ។

- សំណុំឯកសារមួយចំនួនទៀតដែលពាក់ព័ន្ធនឹងសំណុំរឿងទាំងមូល ។

## យល់ឃើញថា

- តាមចម្លើយរបស់ឈ្មោះ ហៅ និងឈ្មោះ បានឆ្លើយបញ្ជាក់ថា ៖ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ពួកខ្លួនបានចូលលុយគ្នាទិញថ្នាំញៀនពីឈ្មោះ ដើម្បីយកទៅប្រើប្រាស់ ពិតប្រាកដមែន ។ ប៉ុន្តែពួកខ្លួនមិនទាន់បានប្រើប្រាស់គ្រឿងផងស្រាប់តែត្រូវសមត្ថកិច្ចចាប់ឃាត់តែម្តង ។

- តាមរបាយការណ៍លេខ ៧៥០ របក.នប ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង , ចម្លើយសារភាពរបស់ជនត្រូវចោទ និងវត្ថុតាង សបញ្ជាក់បានថា៖ កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ឈ្មោះ ហៅ ភេទប្រុស និងឈ្មោះ ភេទប្រុស ពិតជាបានប៉ុនប៉ងប្រើប្រាស់គ្រឿងញៀន ប្រាកដមែន ។

-អំពើប្រព្រឹត្តរបស់ឈ្មោះ ហៅ ភេទប្រុស អាយុ ២១ឆ្នាំ និងឈ្មោះ ភេទប្រុស អាយុ ៣១ឆ្នាំ ជាបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចក្រុមទី០៥ភូមិអូរតាទៀក ឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតត្រាគ្រឿងញៀន ។

-ទង្វើរបស់ជននេះ ធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និងការរស់នៅសេចក្តីថ្លៃថ្នូរ របស់ប្រជាពលរដ្ឋ និងច្បាប់រដ្ឋ ។

- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើ

១ឈ្មោះ ហៅ ភេទប្រុស អាយុ ២១ឆ្នាំ

២-ឈ្មោះ ភេទប្រុស អាយុ ៣១ឆ្នាំ

ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចក្រុមទី០៥ ភូមិអូរតាទៀក ឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតត្រាគ្រឿងញៀន ។

ហើយបាននិយាយឌឺដងគ្នាក៏ឈ្មោះ នេះបានជេរប្រមាថលើកូនស្រីខ្លួនដូចនេះតែម្តង ខ្លួនបានប្តឹងទៅភូមិ-ឃុំឲ្យសំរបសំរួលដែរតែពុំត្រូវគ្នា ។

- ចម្លើយរបស់ជនរងគ្រោះឈ្មោះ ហៅ ភេទស្រី អាយុ១៧ឆ្នាំ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ ឆ្លើយថា នៅថ្ងៃទី១០ ខែសីហា ឆ្នា២០១៦ ខ្លួន និងបងស្រីកំពុងរើសឃោអាវដែលគេឈប់លក់ ក្មួយប្រុសខ្លួនបានមកដែរហើយបានទារទិញអាវទ្រនាប់ ខ្លួននិយាយថាក្មួយពាក់អាវទ្រនាប់ប្រយត្ន័កើតខ្ទើយទេក្មួយខ្លួននៅតែទារ ពេលនោះឈ្មោះ ក៏នៅទីនោះដែរគេក៏និយាយថា ម៉េចខ្ទើយនឹងទាស់ក្បាលអីង៉ែង និងបានជេរប្រមាថនូវពាក្យអសុរសមួយចំនួនទៀតដូចជាមីចោក **មីង៉ែងឲ្យអញចុយអញមិនចុយផង មីង៉ែងឲ្យប្រុសចុយអស់ហើយ ដើមមិនដឹងយកកូនចេញអស់ប៉ុន្មាននោះទេ ទៅភូមិក្រោមឲ្យគេបុកគេមិនបុកផង** ពេលនោះបងស្រីខ្លួនក៏នៅទីនោះដែរ ខ្លួនគ្មានចេតនាថាឲ្យឈ្មោះ ទេ ហើយគ្រួសារខ្លួននិងគ្រួសារឈ្មោះ នេះមិនត្រូវគ្នាទេ ។

- ចម្លើយរបស់ជនសង្ស័យឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ឆ្លើយថា នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ ខ្លួននិងបងស្រីបានមករើសខោអាវជុះដែលគេដឹកលក់នៅមុនផ្ទះ ក៏ជួបនឹងឈ្មោះ និងបងស្រីគេដែរ ពេលនោះបងស្រីខ្លួននិងបងស្រីឈ្មោះ បានឈ្លោះប្រកែកគ្នា ហើយឈ្មោះ **ស្រីនាង** ក៏និយាយថា ប្រុសសម័យឥលូវស្រលាញ់ប្រុសគ្នា ខ្ទើយមួយជាតិ បងស្រីខ្លួនក៏តបថា បើចង់ដឹងខ្ទើយមិនខ្ទើយសាកទៅ ខ្លួនក៏តបវិញថា**មីង៉ែងឲ្យអញចុយអញមិនចុយផង មីង៉ែងឲ្យប្រុសចុយអស់ហើយ ដើមមិនដឹងយកកូនចេញអស់ប៉ុន្មាននោះទេ ទៅភូមិក្រោមឲ្យគេបុកគេមិនបុកផង** ការឈ្លោះប្រកែកគ្នានេះប្រហែលរយៈពេលមួយម៉ោង ទើបបំបែកគ្នាទៅផ្ទះរៀងខ្លួន ។

- ដីការអមលេខ០៣/១៦ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ របស់ឃុំឃ្លាំងមាស ។

- សំណុំឯកសារមួយចំនួនទៀតដែលពាក់ព័ន្ធនឹងសំណុំរឿងទាំងមូល ។

## យល់ឃើញថា

- តាមចម្លើយរបស់ដើមបណ្តឹង,ចម្លើយរបស់ជនរងគ្រោះ បានឆ្លើយមានលក្ខណៈប្រហាក់ប្រហែលគ្នា ថាកាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ ឈ្មោះ បានជេរប្រមាថនូវពាក្យអសុរសជាច្រើនមកលើខ្លួនដូចជា **មីចោក មីង៉ែងឲ្យអញចុយអញមិនចុយផង មីង៉ែងឲ្យប្រុសចុយអស់ហើយ ដើមមិនដឹងយកកូនចេញអស់ប៉ុន្មាននោះទេ ទៅភូមិក្រោមឲ្យគេបុកគេមិនបុកផង** ។

- ចម្លើយរបស់ជនសង្ស័យឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ ឆ្លើយថា នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ ពេលដែលកំពុងទិញខោអាវនៅមុខផ្ទះនោះខ្លួន និងឈ្មោះ **ណន ស្រីនាង** បានឈ្លោះប្រកែកពាក្យសំដីនឹងគ្នា ដោយមានពាក្យតបតទៅគ្នាទៅវិញទៅមក ដូចជា**មីង៉ែងឲ្យអញចុយអញមិនចុយផង មីង៉ែងឲ្យប្រុសចុយអស់ហើយ ដើមមិនដឹងយកកូនចេញអស់ប៉ុន្មាននោះទេ ទៅភូមិក្រោមឲ្យគេបុកគេមិនបុកផង** ប្រាកដមែន ។

- តាមឯកសារដីការអមលេខ០៣/១៦ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ របស់ឃុំឃ្លាំងមាស ដោយមានពាក្យបណ្តឹង របាយការណ៍មេភូមិព្រៃធំ និងកំណត់ហេតុសំរុះសំរួល បានបញ្ជាក់ថា ពិតជាមានករណី **ជេរប្រមាថជាសាធារណៈ**ដែលបង្កឡើងដោយឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ ប្រាកដមែន ។

- អំពើប្រព្រឹត្តរបស់ឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ ជាបទ **ជេរប្រមាថជាសាធារណៈ** បទល្មើសព្រហ្មទណ្ឌដែលត្រូវបានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ។

- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ ពីបទ **ជួញដូរគ្រឿងញៀនដោយខុសច្បាប់** ប្រព្រឹត្តនៅចំណុចភូមិព្រៃធំ ឃុំឃ្លាំងមាស ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា **៣០៧** នៃក្រមព្រហ្មទណ្ឌ ។

- បទ **ជួញដូរគ្រឿងញៀនដោយខុសច្បាប់** បទល្មើសព្រហ្មទណ្ឌដែលត្រូវបានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា **៣០៧** នៃក្រមព្រហ្មទណ្ឌ **ជាបទលហុ** ដូចបានកំណត់នៅមាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌ (និយមន័យនៃបទលហុ) គប្បីចោទប្រកាន់តាមនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ (មាត្រា ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។

## <u>ហេតុដូច្នេះ សម្រេច</u>

១- បញ្ជូនជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ ពីបទ **ជួញដូរគ្រឿងញៀនដោយខុសច្បាប់** ប្រព្រឹត្តនៅចំណុចភូមិព្រៃធំ ឃុំឃ្លាំងមាស ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ទៅសាលាដំបូង **ដើម្បីជំនុំជម្រះ** ។

២- បញ្ជូនសំណុំរឿងនេះ ទៅចៅក្រមជំនុំជម្រះ ដើម្បីចាត់ការតាមនីតិវិធី ។

**ធ្វើនៅបាត់ដំបង, ថ្ងៃទី** ១៦ **ខែ** កុម្ភៈ **ឆ្នាំ២០១៧**

**ព្រះរាជអាជ្ញារង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
ខេត្តបាត់ដំបង
លេខៈ ២៨១....ឆស

## ដីកាសន្និដ្ឋាន
## បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

យើង តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង

- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៧៥៩ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ។
- បានឃើញមាត្រា ៤៣, ៤៦, ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

**ឃើញថា**

-នាម-គោត្តនាមៈ ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ នីតិជន មុខរបរ នៅផ្ទះ កើតនៅភូមិនិគម ឃុំជ្រោយស្តៅ ស្រុកថ្មគោល ខេត្តបាត់ដំបង កាន់សាសនា ព្រះពុទ្ធ សព្វថ្ងៃរស់នៅភូមិព្រៃធំ ឃុំឃ្លាំងមាស ស្រុកបវេល ខេត្តបាត់ដំបង នៅលីវ ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ (រ) ទោសពីមុន **គ្មាន** ។

ត្រូវបានចោទប្រកាន់ពីបទ **ជេរប្រមាថជាសាធារណៈ** ប្រព្រឹត្តនៅភូមិព្រៃធំ ឃុំឃ្លាំងមាស ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា **៣០៧** នៃក្រមព្រហ្មទណ្ឌ។

**ឃើញថា**

កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ វេលាម៉ោង៩:០០នាទីព្រឹក ស្ថិតនៅភូមិព្រៃធំ ឃុំឃ្លាំងមាស ស្រុកបវេល ខេត្តបាត់ដំបង ឈ្មោះ អាយុ១៧ឆ្នាំ និងបងស្រីឈ្មោះ ភេទស្រី អាយុ២៥ឆ្នាំ បានឈររើសខោអាវជជុះដែលគេឈប់លក់លើថ្នល់មុខផ្ទះឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ ពេលនោះក្មួយប្រុសខ្លួនក៏បានសុំឲ្យឈ្មោះ ទិញអាវទ្រនាប់ឲ្យហើយឈ្មោះ ក៏និយាយទៅក្មួយវិញថា ក្មួយឯងចង់ទិញអាវទ្រនាប់ប្រយត្ន័កើតខ្ទើយ ឈ្មោះ បានលឺដូចនេះក៏និយាយពីផ្ទះថា **មីចោក មីងែងឲ្យអញចុយអញមិនចុយផង មីងែងឲ្យប្រុសចុយអស់ហើយ ដើមមិនដឹងយកកូនចេញអស់ប៉ុន្មាននោះទេ ទៅភូមិក្រោមឲ្យគេបុកគេមិនបុកផង** ។

**បានឃើញ**

- ពាក្យបណ្តឹងរបស់ឈ្មោះ ភេទប្រុស អាយុ៤៥ឆ្នាំ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ ។
- ចម្លើយរបស់ដើមបណ្តឹងឈ្មោះ ភេទប្រុស អាយុ ៥៦ឆ្នាំ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ ឆ្លើយថា នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ ពេលខ្លួនត្រលប់មកពីចំការវិញ កូនស្រីខ្លួនបានប្រាប់ថាឈ្មោះ បានជេរប្រមាថមើលងាយនូវពាក្យអសុរសជាច្រើន ដូចជាមីចោក **មីងែងឲ្យអញចុយអញមិនចុយផង មីងែងឲ្យប្រុសចុយអស់ហើយ ដើមមិនដឹងយកកូនចេញអស់ប៉ុន្មាននោះទេ** ទៅភូមិក្រោមឲ្យគេបុកគេមិនបុកផង មូលហេតុដែលគេជេរលើកូនស្រីខ្លួន ដោយសារកូនស្រីខ្លួនបានហៅម៉ូតូដែលដឹកខោអាវជជុះ លក់តាមផ្លូវហើយឈប់នៅមុខផ្ទះគេ

ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្រុមទី០៥ភូមិអូរតាទៀក ឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតត្រាគ្រឿងញៀន ។

**<u>ហេតុដូច្នេះ សម្រេច</u>**

- បញ្ជូនជនជាប់ចោទ

១-ឈ្មោះ ហៅ ភេទប្រុស អាយុ ២១ឆ្នាំ

២-ឈ្មោះ ភេទប្រុស អាយុ ៣១ឆ្នាំ

ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្រុមទី០៥ ភូមិអូរតាទៀក ឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតត្រាគ្រឿងញៀន ។

- បញ្ជូនសំណុំរឿងនេះ ទៅចៅក្រមជំនុំជម្រះ ដើម្បីចាត់ការតាមនីតិវិធី ។

ធ្វើនៅបាត់ដំបង ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦

**ព្រះរាជអាជ្ញារង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តកណ្តាល

លេខ៖ កសបបខក

# កំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែសីហា ថ្ងៃទីម្ភៃប្រាំបី វេលាម៉ោងដប់បួន និងសាមសិបនាទី

**យើង** **តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។**

- **បានឃើញ** មាត្រា ៤៣ , ៤៧ , ៤៨ , ២៩១ , ២៩២ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។
- **បានឃើញ** របាយការណ៍សុបលេខៈ ០២០ រ.ប.ក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ នៃក្រសួងមហាផ្ទៃ។
- **បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

<u>បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោមៈ</u>

-នាមត្រកូល ភេទស្រី អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខៈ ១៩០៣៣៩៥២៩ ទីកន្លែងកំណើត ភូមិព្រៃសណ្តែក ឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខៈ ១៣០ ផ្លូវលំបេតុង ភូមិព្រែកតាពៅ១ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល មុខរបរផលិតករ និងអាជីវករលក់ថ្នាំលាបស្បែក(ឡេ) នៅលើវ ឪពុកឈ្មោះ "ស" ម្តាយឈ្មោះ "ស" ទោសពីមុន គ្មាន ។ ( **ឃាត់ខ្លួន** )

<u>យើងបានប្រាប់ដល់បុគ្គលនេះនូវអង្គហេតុដែលខ្លួនត្រូវបានចោទប្រកាន់មានដូចតទៅៈ</u>

កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង១០និង០០នាទី មានករណីៈ **ក្លែងផលិតផលទំនិញដែលជាកម្មវត្ថុធ្វើពាណិជ្ជកម្ម ឬ ទុកសម្រាប់ធ្វើពាណិជ្ជកម្ម** បង្កឡើងដោយឈ្មោះ កើតឡើងនៅចំណុចទីតាំងផ្ទះរបស់ជនបង្កហេតុ ស្ថិតក្នុងភូមិព្រែកតាពៅ១ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល បាន



អាស័យដ្ឋានៈ ផ្លូវជាតិលេខ២ ភូមិតាខ្មៅ២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល
Address: National Road2, Phum Takhmao2, Sangkat Takhmao, Takhmao City, Kandal Province

ធ្វើសកម្មភាពផលិត វេចខ្ចប់ រក្សាទុក លក់ និងចែកចាយថ្នាំលាបស្បែក (ឡេ) ដោយពុំមានច្បាប់អនុញ្ញា...
និងចុះបញ្ជិកាជាមួយ ក្រសួងសុខាភិបាល ហើយផលិតផលថ្នាំលាបស្បែកនោះសង្ស័យថាជាផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់ និងមានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពអ្នកប្រើប្រាស់ ។ លុះក្រោយមកជនបង្កត្រូវបានឃាត់ខ្លួន រួមទាំងវត្ថុតាងដែលចាប់បានបញ្ជូនមកក្រសួងមហាផ្ទៃតែម្តង ។

**<u>អង្គហេតុនេះជាបទល្មើស៖</u>**" ក្លែងផលិតផលទំនិញដែលជាកម្មវត្ថុធ្វើពាណិជ្ជកម្ម ឬ ទុកសម្រាប់ធ្វើពាណិជ្ជកម្ម " ប្រព្រឹត្តនៅ ចំណុចទីតាំងផ្ទះរបស់ជនបង្កហេតុ ស្ថិតក្នុងភូមិព្រែកតាពៅ១ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង១០និង០០នាទី តាមបញ្ញត្តិមាត្រា **១៧** និង **៦៣** នៃច្បាប់ស្តីពី **ការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និង សេវា។**

**យើងបានទទួលចម្លើយជននេះដូចទៅ៖**

- *ជនជាប់ចោទឈ្មោះ* បានសុំរក្សាចម្លើយដែលបានឆ្លើយនៅកងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ទុកនៅដដែលទាំងស្រុង និង សុំសារភាពថាៈ ពិតជាបានយកផ្ទះរបស់ខ្លួនមកធ្វើជាទីតាំងផលិត វេចខ្ចប់ រក្សាទុក លក់ និងចែកចាយថ្នាំលាបស្បែក (ឡេ) ដោយពុំមានច្បាប់អនុញ្ញាតិ និងចុះបញ្ជិកាជាមួយ ក្រសួងសុខាភិបាល ប្រាកដមែន។

**យើងបានប្រាប់ជននេះថា៖** ខ្លួនមានសិទ្ធិសុំពឹងមេធាវី តាមការជ្រើសរើសរបស់ខ្លួន ឬស្នើសុំឱ្យមានការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់ ។

<u>ជននេះបានឆ្លើយថា:</u>

- ☐ ខ្ញុំជ្រើស-លោក/លោកស្រីមេធាវី..............................................................................។
- ☐ ខ្ញុំសូមស្នើសុំឱ្យមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។
- ☐ ខ្ញុំមិនត្រូវការមេធាវីទេក្នុងពេលនេះ ។

<u>យើងបានបញ្ជាក់ថា:</u>

- ☐ លោក/លោកស្រីមេធាវី......................................អាចពិនិត្យសំណុំរឿងនិងទាក់ទងជាមួយជនជាប់ចោទ ។
- ☐ យោងលើសំណើសុំ ឱ្យមានការចាត់តាំងមេធាវី ស្របតាមបញ្ញត្តិច្បាប់ ស្តីពីលក្ខន្តិកៈមេធាវី តំណាងគណៈមេធាវីត្រូវបានជូនដំណឹងភ្លាម ។
- ☐ លោក/លោកស្រីមេធាវី.................................................................................អវត្តមាន ។

---

**បញ្ជាក់:** និទ្ទេសនៃទម្រង់ការទាំងនេះត្រូវចុះនៅក្នុងកំណត់ហេតុ បើពុំដូច្នេះទេ នីតិវិធីត្រូវទុកជាមោឃៈ ។

## សម្រេច

បញ្ជូនជនជាប់ចោទឈ្មោះ ភេទស្រី អាយុ៣២ឆ្នាំ ទៅតុលាការដើម្បីធ្វើការជំនុំជម្រះតាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ចំពោះអង្គហេតុ និងបទល្មើសដូចខាងលើ ។

ក្រោយពីបានអាន ជនជាប់ចោទបានផ្តិតមេដៃជាមួយយើង ។

**ជនជាប់ចោទ** **តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ ៣១៩៣
ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៩
លេខ ......1821...... អ.យ.ន

# ដីកាតម្កល់រឿងទុកឥតចាត់ការ

យើង តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៣១៩៣ ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាចាត់តាំងតំណាងអយ្យការលេខ ៣២៧៨ អ.យ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

យល់ឃើញថា:

១. អវត្តមានបទល្មើស

☐ ១.១.អវត្តមានបទល្មើស

២. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

☐ ២.១.ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣. មូលហេតុគតិយុត្ត

☐ ៣.១.ការដកពាក្យបណ្តឹង

☐ ៣.២.ការលើកលែងទោសជាទូទៅ

☐ ៣.៣.មរណភាពជនល្មើស

☐ ៣.៤.ផុតអាជ្ញាយុកាល

☐ ៣.៥.និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

☐ ៣.៦.អាជ្ញាអស់ជំនុំ

☐ ៣.៧.ការសម្របសម្រួលជាមួយរដ្ឋ

☐ ៣.៨.ការបង់ប្រាក់ពិន័យសរុប ឬពិន័យសម្របសម្រួល

☐ ៣.៩.អភ័យឯកសិទ្ធិ

☐ ៣.១០.អនិយ័តភាពនៃនីតិវិធី

☐ ៣.១១.ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

៤. ការចោទប្រកាន់មិនផ្តល់ប្រយោជន៍

☐ ៤.១.ការស្វែងរកមិនបានផល

☐ ៤.២.ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង

[1] ដូចជាមូលហេតុផ្សេងៗទៀត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

☐ ៤.៣.ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

☐ ៤.៤.ការខកខានរបស់ដើមបណ្ដឹង

☐ ៤.៥.អាកប្បកិរិយារបស់ជនរងគ្រោះ

☐ ៤.៦.ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

☐ ៤.៧.និយ័តកម្មដោយឯកឯង[3]

☐ ៤.៨.ល្បួងកម្ម ឬការខានតិចតួចបង្កដោយបទល្មើស

៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា

☐ ៥.១.ការជួសជុលការខូចខាតដោយ/ដល់អនីតិជន

☐ ៥.២.សន្ទានកម្ម[4]

☐ ៥.៣.អធិបញ្ញាផ្ដល់ការព្យាបាល

☐ ៥.៤.ជនរងគ្រោះ/ដើមបណ្ដឹងបោះបង់បណ្ដឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា

☐ ៥.៥.និយ័តកម្មតាមសំណើរបស់ព្រះរាជអាជ្ញា

☐ ៥.៦.ការរំលឹកពីអត្ថបទច្បាប់/ការព្រមាន[5]

☐ ៥.៧.ការកំណត់ទិសដៅចំពោះចេនាសម្ព័ន្ធនៃសុខភាពនៃសង្គម ឬនៃវិជ្ជាជីវៈ

☐ ៥.៨.ការសម្រុះសម្រួលព្រហ្មទណ្ឌ[6]

៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងទៀត

☐ ៦.១.ការចោទប្រកាន់ ឬទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

៧. ជនល្មើសមិនត្រូវបានស្គាល់

☐ ៧.១.ជនល្មើសមិនត្រូវបានស្គាល់

៨. ជំនួយការអប់រំ

☐ ៨.១.ការផ្ដល់ជំនួយការអប់រំជំនួសការចោទប្រកាន់

**ការសង្កេតផ្សេងៗឃើញថា៖** តាមពាក្យបណ្ដឹងរបស់ឈ្មោះ [redacted] ភេទប្រុស ឆ្នាំកំណើត១៩៧២ ប្ដឹងមកលើឈ្មោះ [redacted] ជាមន្ត្រីអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ពីបទល្មើសព្រហ្មទណ្ឌ បង្កើតសំណុំរឿងអនុវត្តលេខ ១៤៣ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ ក្លែងក្លាយ,រៀបចំគម្រោងទុច្ចរិត ដើម្បីធ្វើស៊ី ឬចង់បានផ្ទះ(ផ្ទះលេខ៦២E₀E₁E₂ផ្លូវលេខ៥៥៨ ភូមិ៥ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ),អន្តរាគមន៍ដោយខុសច្បាប់ទៅលើមន្ត្រីសាធារណៈតាមរយៈការចេញលិខិតរបស់អាជ្ញាសាលា(ស៊ុន លៀងហេង) លេខ០៧ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៥ និងបទរំលោភបំពានច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជាដូចជារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

## **បានឃើញ**

-បានឃើញ ពាក្យបណ្ដឹង ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted] ភេទប្រុស អាយុ ៤៧ ឆ្នាំ ជនជាតិខ្មែរ

-បានឃើញ ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៤៧ឆ្នាំ បានឆ្លើយបំភ្លឺថា: មូលហេតុដែលខ្លួនបានប្ដឹងទៅលើឈ្មោះ [redacted] គឺដោយសារតែឈ្មោះនេះបានបង្កើតនូវសំណុំរឿងអនុវត្តលេខ ១៤៣ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ ដែលមិនពាក់ព័ន្ធទៅនឹងរឿងក្ដីអនុវត្តរបស់ខ្លួនដែលបានដោះស្រាយតាមផ្លូវ

---

[2] ដើមបណ្ដឹងឈប់ប្ដឹង

[3] សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និងស្ដារស្ថានភាពឡើងវិញ

[4] ករណីចែងដោយច្បាប់

[5] ព្រះរាជអាជ្ញាព្រមានអំពីអំពើដែលជាបទល្មើសតាមកំណត់ច្បាប់ និងធ្វើការព្រមាន ឲ្យឈប់ប្រព្រឹត្ត

[6] ករណីចែងដោយច្បាប់

តុលាការនៅកំឡុងឆ្នាំ២០០៥ ទាល់តែសោះ ហើយឈ្មោះនេះបានចុះអនុវត្តដោយចេញលិខិតលេខ០៧ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ដើម្បីស្នើសុំអាជ្ញាធរមានសមត្ថកិច្ចចុះអនុវត្តបែងចែកអចលនទ្រព្យសម្បត្តិរបស់ខ្លួនតែម្តង ដោយខ្លួនមិនយល់ថា តើហេតុអ្វីបានជារឿងក្តីរបស់ខ្លួនចាប់ផ្តើមដំណើរការនៅឆ្នាំ២០០៥ ហេតុអ្វីបានជាឈ្មោះ [redacted] ទៅចុះសំណុំរឿងអនុវត្តនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ ទៅវិញ តើបានលេខសំណុំរឿងអនុវត្ត ១៤៣ មកពីណា?សូមបញ្ជាក់ថានៅកំឡុងឆ្នាំ២០១៩ ខ្លួនមានវិវាទជាមួយឈ្មោះ [redacted] ពាក់ព័ន្ធនឹងករណីដែលខ្លួនបានទិញឡាយសិនឬបខ្សាច់ពីឈ្មោះ [redacted] ដោយចំណាយទឹកប្រាក់ចំនួន២៥០០០០USA តែឈ្មោះ [redacted] បានយកលុយរួចហើយតែមិនបានចេញឡាយសិននេះឱ្យខ្លួននោះទេ ហើយថែមទាំងប្តឹងរូបខ្លួនអំពីករណីចេញសែកគ្មានសាច់ប្រាក់ថែមទៀត ទើបឈានទៅដល់មានសំណុំរឿងអនុវត្តតែម្តង ។

-បានឃើញ ចម្លើយរបស់ជនសង្ស័យឈ្មោះ [redacted] ឆ្លើយនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា៖ ខ្លួនសូមបដិសេធចោលទាំងស្រុងនូវពាក្យបណ្តឹង ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ ដែលបានប្តឹងចោទប្រកាន់មកលើរូបខ្លួនពីករណីបង្កើតសំណុំរឿងអនុវត្តលេខ១៤៣ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ ក្លែងក្លាយ, រៀបចំគម្រោងការទុច្ចរិត ដើម្បីធ្វើស៊ី ឬចង់បានផ្ទះ(ផ្ទះលេខ៦២$E_0E_1E_2$ ផ្លូវលេខ៥៥៨ ភូមិ៥ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ), អន្តរាគមន៍ដោយខុសច្បាប់ទៅលើមន្ត្រីសាធារណៈតាមរយៈការចេញលិខិតរបស់អាជ្ញាសាលា ([redacted]) លេខ០៧ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ និងករណីរំលោភបំពានច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា ដូចជារដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដោយហេតុថាការលើកឡើងនៅក្នុងពាក្យបណ្តឹងនេះ គឺពុំមែនជាការពិតទេ ដោយសារតែនៅក្នុងលិខិតលេខ០៧ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ និងលិខិតលេខ១៧ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ របស់មន្ត្រីអាជ្ញាសាលាប្រចាំសាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចយោងទី២ ដែលបានសរសេរថា សំណុំរឿងអនុវត្តលេខ១៤៣ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ នោះគឺកើតចេញពីកំហុសបច្ចេកទេស ដែលការពិតសំណុំរឿងនោះគឺជាសំណុំរឿងអនុវត្តលេខ ១៤៣ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥ ដែលមានម្ចាស់បំណុលនៃការអនុវត្តឈ្មោះ [redacted] និងកូនបំណុលនៃការអនុវត្តឈ្មោះ [redacted] (ដូចមានបញ្ជាក់នៅក្នុងសៀវភៅចុះលេខសំណុំរឿងអនុវត្តសាលក្រម សាលដីកា និងដីការសម្រេចរបស់តុលាការ ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ) ករណីនេះខ្លួនបានធ្វើស្នើសុំធ្វើការកែតម្រូវបញ្ហាបច្ចេកទេសទៅសាលាខណ្ឌទួលគោករួច រាល់ហើយដែរ ដូចមានបញ្ជាក់នៅក្នុងលិខិតលេខ ២០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ របស់ខ្លួន។ តាមការការចេញលិខិត លេខ ០៧ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ និងលិខិតលេខ ១៧ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ របស់ខ្លួន ដើម្បីស្នើសុំកម្លាំងឲ្យចូលរួមអនុវត្ត គឺពុំមែនជាការអន្តរាគមន៍ដោយខុសច្បាប់ទៅលើមន្ត្រីសាធារណៈទេ ប៉ុន្តែផ្ទុយទៅវិញ វាការអនុវត្តច្បាប់យ៉ាងត្រឹមត្រូវក្នុងមុខតំណែងជា អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ដោយហេតុថា តាមបញ្ញត្តិនៃមាត្រា ៣៣៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា "ប្រសិនបើអាជ្ញាសាលាជួបប្រទះនឹងការប្រឆាំងនៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលានោះអាចប្រើកម្លាំង ឬអាចសុំជំនួយពីនគរបាល ឬ កងកម្លាំងផ្សេងទៀតដែលមានសមត្ថកិច្ច ដើម្បីបំបាត់នូវការប្រឆាំងនោះបាន"។ ករណីនេះ កូនបំណុលនៃការអនុវត្តឈ្មោះ [redacted] តែងតែប្រឆាំងនិងរារាំងការអនុវត្តតាមគ្រប់មធ្យោបាយ ហើយមានពេលខ្លះភាគីកូនបំណុលនៃការអនុវត្ត បានយកសាំងមកគម្រាមដុតខ្លួនក៏មាន ហេតុដូចនេះដើម្បីធានាសុវត្ថិភាព និងរារាំងការប្រឆាំងនឹងការអនុវត្តដែលអាចនឹងកើតមានខ្លួនបានស្នើសុំកម្លាំងឲ្យចូលរួមអនុវត្ត ដូចមានបញ្ជាក់ក្នុងលិខិតទាំងពីរខាងស្រាប់។

- បានឃើញឯកសារសំខាន់ផ្សេងៗដែលបានភ្ជាប់មកជាមួយនៅក្នុងសំណុំរឿង។

**យល់ឃើញថា**

-តាមសៀវភៅចុះលេខសំណុំរឿងអនុវត្តសាលក្រម សាលដីកា និងដីកាសម្រេចរបស់តុលាការ ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ គឺបញ្ជាក់ឲ្យឃើញថា សំណុំរឿងអនុវត្តដែលមានកម្មវត្ថុឲ្យឈ្មោះ [redacted] ប្រគល់ផ្ទះលេខ៦២$E_0E_1E_2$ ផ្លូវលេខ៥៥៨ ភូមិ៥ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទៅឲ្យម្ចាស់បំណុលនៃការអនុវត្តឈ្មោះ [redacted] ពិតជាមានសំណុំរឿងអនុវត្តប្រាកដមែនគឺ សំណុំរឿងអនុវត្តលេខ ១៤៣ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥របស់សាលាដំបូងរាជធានីភ្នំពេញ ។

-តាមកំណត់ហេតុស្តីពីការអនុវត្តដីកាសម្រេច ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៧, កំណត់ហេតុស្តីពីការអនុវត្តឲ្យប្រគល់អចលនវត្ថុដោយបង្ខំ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៨, លិខិតលេខ ២០០ អយជ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ

២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បញ្ជាក់ឲ្យឃើញថា សំណុំរឿងអនុវត្តលេខ ១៤៣ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥ ត្រូវបានចាប់ផ្តើមដឹកនាំការអនុវត្តដោយព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងបន្តរហូតដល់ឈ្មោះ ជាមន្ត្រីអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ប្រាកដមែន។

-តាមការពិនិត្យលើសេចក្តីបំភ្លឺ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩, លិខិតលេខ ២០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ របស់លោក និងភស្តុតាងជាឯកសារផ្សេងៗទៀតដែលមាននៅក្នុងសំណុំរឿង ឃើញថា លិខិតលេខ ០៧ ចុះថ្ងៃទី២៦ ខែមេសាឆ្នាំ២០១៩ ដើម្បីស្នើសុំកម្លាំងឱ្យចូលរួមអនុវត្ត ដោយបានចុះលេខសំណុំរឿងអនុវត្ត ១៤៣ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ ប៉ុន្តែឆ្លងតាមការពិនិត្យទៅលើបញ្ជីសំណុំរឿងអនុវត្តរបស់សាលាដំបូងរាជធានីភ្នំពេញ បញ្ជាក់ថាសំណុំរឿងអនុវត្តលេខ ១៤៣ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥ ហើយសំណុំរឿងអនុវត្តនេះគឺអនុវត្តទៅលើវិវាទរដ្ឋប្បវេណីដែលកើតឡើងក្នុងអំឡុងឆ្នាំ២០០៩ ហេតុនេះមិនមានហេតុផលអ្វីត្រូវមានសំណុំរឿងអនុវត្តចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ នោះទេ ដូច្នេះ សំណុំរឿងអនុវត្តលេខ១៤៣ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ គឺជាកំហុសផ្នែកបច្ចេកទេសរបស់មន្ត្រីអនុវត្តត្រង់ចំណុចឆ្នាំនៃការបង្កើតវាងឆ្នាំ២០១៥ និងឆ្នាំ២០០៥ ហើយឈ្មោះ បានធ្វើការកែតម្រូវដោយបានចេញលិខិតលេខ ២០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ រួចហើយ។

- តាមមាត្រា ៣៣៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺបានផ្តល់សិទ្ធិឲ្យអាជ្ញាសាលាស្នើសុំកម្លាំងឲ្យចូលរួមសហការអនុវត្ត តំណាងអយ្យការយល់ឃើញថា ការចេញលិខិត លេខ ០៧ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ របស់ឈ្មោះ ពុំមែនជាការអន្តរាគមន៍ដោយខុសច្បាប់លើមន្ត្រីសាធារណៈនោះទេ ពោលគឺវាជាការអនុវត្តច្បាប់។

-តាមលិខិតលេខ ០៥ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ ដែលអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញបានស្នើសុំទៅឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីរាយការណ៍និងសុំគោលការណ៍ណែនាំពាក់ព័ន្ធនឹងការអនុវត្តនៅក្នុងសំណុំរឿងអនុវត្តលេខ ១៤៣ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥ គឺបញ្ជាក់ឲ្យឃើញថា ឈ្មោះ មន្ត្រីអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ពិតជាបានអនុវត្តត្រឹមត្រូវស្របតាមប្រការ ៣ នៃប្រកាសលេខ ០៦២ កយ.ប្រក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងយុត្តិធម៌ប្រាកដមែន ដូច្នេះបង្ហាញឱ្យឃើញថាឈ្មោះ មិនបានធ្វើសកម្មភាពផ្ទុយទៅនឹងច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជានោះឡើយ។

-អង្គហេតុខាងលើនេះ ពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ដែលអាចឲ្យតំណាងអយ្យការធ្វើការចោទប្រកាន់ទៅលើឈ្មោះ ពីករណី បង្កើតសំណុំរឿងអនុវត្តលេខ១៤៣ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ ក្លែងក្លាយ ,អន្តរាគមន៍ដោយខុសច្បាប់ទៅលើមន្ត្រីសាធារណៈ និងបទរំលោភបំពានច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជាបានឡើយ ដូច្នេះគប្បីតំណាងអយ្យការតម្កល់សំណុំរឿងនេះទុកឥតចាត់ការ តាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

-តម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ ៣១៩៣ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ ទុកឥតចាត់ការចាប់ពីពេលនេះតទៅ។

ថ្ងៃ...ចន្ទ ១៣កើត... ខែ ស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី...... ខែសីហា ឆ្នាំ ២០១៩

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តកណ្តាល

លេខ៖ ...៣៣៥........ លជណ

## លិខិតជូនដំណឹង[1]

**យើង តំណាងអយ្យការ អមសាលាដំបូងខេត្តកណ្តាល**

ជម្រាបមកឈ្មោះ                    ភេទស្រី អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ១៣៣ ផ្លូវលំ ភូមិបុរី១០០ខ្នង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ **ដើមបណ្តឹងរដ្ឋប្បវេណី ។**

ត្បិតពាក្យបណ្តឹងចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ របស់លោកស្រីដែលបានប្តឹងពីឈ្មោះ
និងឈ្មោះ            ពាក់ព័ន្ធនឹងករណី **ហិង្សាដោយចេតនា និង ក្លែងបន្លំឯកសារ** កើតឡើងនៅភូមិស្ទឹង ឃុំរលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១។

នោះយើងបានសម្រេចតម្កល់ទុកឥតចាត់ការ នូវសំណុំរឿងព្រហ្មទណ្ឌលេខៈ **៣៤៩អ.ក** ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ តាមដីកាសម្រេចលេខៈ៣១៧.**ដកមចក** ចុះថ្ងៃទី២០. ខែឧសភា ឆ្នាំ២០២១ រួចហើយ។

ប្រសិនបើអ្នកមិនសុខចិត្ត លោកមានសិទ្ធិប្តឹងតវ៉ាទៅនឹង ដីកាតម្កល់រឿងទុកឥតចាត់ការខាងលើក្នុងរយៈពេល ២ ខែ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងនេះ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
ខេត្តកណ្តាល ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១
**តំណាងអយ្យការ**

---

[1] ជូនដំណឹងដោយមាត្រា ៦ និងមាត្រា៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧

សាលាដំបូងខេត្តកណ្ដាល

ចូល: 1196

27 05 ២០21

14 10

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្ដឹងតវ៉ា**

នាងខ្ញុំឈ្មោះ [redacted] ជាតិខ្មែរ អាយុ៣៥ ឆ្នាំ មានទីលំនៅបច្ចុប្បន្នស្ថិតនៅ ផ្ទះលេខ១៣៣ ផ្លូវលំ ភូមិបុរី១០០ខ្នង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**សូមគោរពជូន**

**ឯកឧត្តមព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល**

**កម្មវត្ថុ ៖** ប្ដឹងតវ៉ានឹងដីកាសម្រេចលេខ ៣១៧ ដកមចក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

**យោង ៖** មាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

លិខិតជូនដំណឹងលេខ ៣៣២ លជណ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមគោរព និងជម្រាបជូន **ឯកឧត្តមព្រះរាជអាជ្ញា** មេត្តាជ្រាបថា ៖ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ អយ្យការអមសាលាដំបូងខេត្តកណ្ដាល បានចេញដីកាសម្រេចលេខ ៣១៧ ដកមចក ដោយបានសម្រេចតម្កល់រឿងទុកឥតចាត់ការលើពាក្យបណ្ដឹងរបស់នាងខ្ញុំ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ ដែលការសម្រេចតម្កល់រឿងទុកឥតចាត់ការខាងលើនេះ គឺផ្ដល់ភាពអយុត្តិធម៌ណាស់សម្រាប់នាងខ្ញុំដែលជាជនរងគ្រោះ ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមព្រះរាជអាជ្ញា** មេត្តាទទួលពាក្យបណ្ដឹងតវ៉ា និងចាត់ការតាមនីតិវិធីច្បាប់ដោយអនុគ្រោះ ។

សូម **ឯកឧត្តមព្រះរាជអាជ្ញា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

ខេត្ត កណ្ដាល ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១

ស្នាមមេដៃស្ដាំ

[redacted]

អយ្យការអម

សាលាដំបូងខេត្តកណ្ដាល

ខ: ...1636............ ដក

# ដីកាបញ្ជូន

**<u>សូមគោរពជូន</u>**

## ឯកឧត្តមអគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ

| លេខរៀង | រាយឈ្មោះលិខិត | ចំនួន | សេចក្ដីផ្សេងៗ |
|---|---|---|---|
| ០១ | -សំណុំរឿងព្រហ្មទណ្ឌលេខ: ៣៨៥អ.ក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល ។ | ០១សំណុំរឿង (ច្បាប់ដើម) | ដើម្បីចាត់ការបន្ត តាមនីតិវិធីច្បាប់ |

ថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ខេត្តកណ្ដាល, ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១

តំណាងអយ្យការ

មហាអយ្យការ អមសាលាឧទ្ធរណ៍

បានទទួល សំណុំរឿង

ថ្ងៃទី...28... ខែ...05... ឆ្នាំ...2021

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មហាអយ្យការអមសាលាឧទ្ធរណ៍**
លេខ...១២៧......សត.ប្រក.០១៦

## សេចក្ដីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការ

បានឃើញ មាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ១០-០៨-២០០៧ ស្ដីពី «ការតម្កល់រឿងទុកឥតចាត់ការ»។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៥០៣៨ ចុះថ្ងៃទី ២១-១២-២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ សំណុំរឿង «តម្កល់រឿងទុកឥតចាត់ការ» ចុះបញ្ជីនៅមហាអយ្យការអមសាលាឧទ្ធរណ៍លេខ ៥៧ ចុះថ្ងៃទី ២៣-០៣-២០១៦ ។

បានឃើញ ពាក្យបណ្ដឹង ចុះថ្ងៃទី ២១-១២-២០១៥ របស់ឈ្មោះ ភេទប្រុស អាយុ ៤២ឆ្នាំ ជនជាតិខ្មែរ ជា មានទីលំនៅសព្វថ្ងៃផ្ទះលេខ ២៤៨ ផ្លូវលេខ ១៥៦ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្ដឹងចោទប្រកាន់លើឈ្មោះ ហោ ណាំហុង ភេទប្រុស អាយុ ៨០ឆ្នាំ ជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពីបទៈ បរិហារកេរ្តិ៍ជាសាធារណៈ និងញុះញង់ឱ្យមានការរើសអើង ។

បានឃើញ ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ៧៩ អ.យ.ង ចុះថ្ងៃទី ២៩-០១-២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ សេចក្ដីសុំប្ដឹងតវ៉ាលេខ ០៣១ ចុះថ្ងៃទី ២១-០៣-២០១៦ របស់ឈ្មោះ
ប្ដឹងតវ៉ានឹងដីកាតម្កល់រឿងទុកឥតចាត់ការខាងលើ ។

បានឃើញ កំណត់ហេតុសួរយកចម្លើយឈ្មោះ នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា៖ កាលពីថ្ងៃទី ០៧-១២-២០១៥ ឈ្មោះ បានធ្វើសន្និសីទព័ត៌មានបានប្រើពាក្យថា៖ "...ជាពិសេសគណបក្សនៃ.. នៅអាមេរិក ដែលកន្លងមករហូតដល់មានសមាជិករបស់គេធ្វើអំពើភេរវកម្មនៅកម្ពុជាផង" ដែលពាក្យនេះធ្វើឱ្យប៉ះពាល់ដល់ទឹកចិត្តអ្នកគាំទ្រ និងធ្វើឱ្យការគាំទ្រមកលើគណបក្សមានការថយចុះ ដែលធ្វើឱ្យគណបក្សមានការលំបាកក្នុងការកសាងកំលាំងថ្មី ហើយបានធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់គណបក្សខ្លួន ។ កន្លងមក ខ្លួន និងសមាជិករបស់ខ្លួនពិតជាត្រូវបានតុលាការកម្ពុជាផ្ដន្ទាទោសដាក់ពន្ធនាគារពីបទៈ រួមគំនិតក្បត់ ប៉ុន្តែរូបខ្លួន និងសមាជិកត្រូវបានព្រះមហាក្សត្រចេញព្រះរាជក្រឹត្យលើកលែងទោសរួចហើយ ។ ខ្លួន និងសមាជិកមិនដែលមានពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើភេរវកម្មនោះទេ ។

បានឃើញ កំណត់ហេតុសួរយកចម្លើយឈ្មោះ ឆ្លើយនៅអយ្យការអមសាលា

ដំបូងរាជធានីភ្នំពេញថា៖ កាលពីថ្ងៃទី ០៧-១២-២០១៥ ខ្លួនពិតជាបានជួបជាមួយអ្នកសារព័ត៌មាន ហើយបាននិយាយថាមានគណបក្សជាច្រើននៅកម្ពុជា គឺនិយាយជារួម មិនសំដៅតែលើគណបក្ស                នោះទេ ហើយក៏គ្មានចេតនាបរិហារកេរ្តិ៍ទៅលើឈ្មោះ                និងគណបក្សរបស់គេដែរ គឺក្នុងន័យបង្កប់ផ្តល់ព័ត៌មាន មិនមែនមានគោលបំណងបរិហារកេរ្តិ៍អ្នកណាទេ ព្រោះពេលនោះ ខ្លួនជួបអង្គទូតនៅភ្នំពេញ ខ្លួននិយាយពីសភាពការណ៍នយោបាយនៅកម្ពុជាជារួម ។ ខ្លួននិយាយថា សមាជិករបស់គេធ្វើអំពើភេរវកម្មនៅកម្ពុជា ដោយសំអាងហេតុថាមានសាលក្រម និងសាលដីការបស់តុលាការ ដែលបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារលើបុគ្គល

និងបក្ខពួក ពីបទៈ រួមគំនិតក្បត់ និងញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ប៉ុន្តែខ្លួននិយាយត្រឹមពាក្យភេរវកម្ម ដែលស្រាលជាងពាក្យរួមគំនិតក្បត់ទៅទៀត ។ មូលហេតុដែលខ្លួននិយាយដូច្នេះ ដោយហេតុថាមានសេចក្តីសម្រេចរបស់តុលាការ ដែលធ្វើឡើងជាសាធារណៈ ដែលប្រជាពលរដ្ឋទូទៅបានដឹងឮ ព្រមទាំងត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ហើយឈ្មោះ

ខ្លួនឯងក៏បានដឹងឮរឿងនេះដែរ ហើយឈ្មោះ                ប្តឹងខ្លួន គឺមានចេតនាប្តឹងមូលបង្កាច់កេរ្តិ៍ដល់រូបខ្លួនសុទ្ធសាធ ។

បានឃើញ ឯកសារផ្សេងៗពាក់ព័ន្ធក្នុងសំណុំរឿង ។

យល់ឃើញថា ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ៧៩ អ.យ.ង ចុះថ្ងៃទី ២៩-០១-២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ មានសំអាងហេតុ សំអាងច្បាប់ និងសេចក្តីសម្រេចសមស្របតាមគតិច្បាប់ហើយ គប្បីតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះសម្រេច

តម្កល់ដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការលេខ ៧៩ អ.យ.ង ចុះថ្ងៃទី ២៩-០១-២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ ២០១៦

**អគ្គព្រះរាជអាជ្ញា**

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**មហាអយ្យការអមសាលាឧទ្ធរណ៍**

លេខ ១២៧ ល.ជ.ណា/០១៦

សំណុំរឿងតម្កល់ទុកឥតចាត់ការលេខ ៥៧

ចុះថ្ងៃទី ២៣-០៣-២០១៦

## លិខិតជូនដំណឹង

## យើង អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍

## ជម្រាបមក

ឈ្មោះ ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិខ្មែរ ជាប្រធាន មានទីលំនៅសព្វថ្ងៃផ្ទះលេខ ២៨៤ ផ្លូវលេខ ១៥៦ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

អំពីបណ្តឹងតវ៉ារបស់លោក ប្តឹងពីដីកាតម្កល់រឿងទុកឥតចាត់ការលេខ ៧៩ អ.យ.ង ចុះថ្ងៃទី ២៩-០១-២០១៦ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៥០៣៨ ចុះថ្ងៃទី ២១-១២-២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ពីដំណើររឿង បរិហារកេរ្តិ៍ជាសាធារណៈ និងញុះញង់ឱ្យមានការរើសអើង នោះ យើងបានតម្កល់សេចក្តីសម្រេចរបស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ដោយសេចក្តីសម្រេចនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ តាមសេចក្តីសម្រេចរបស់យើងលេខ ១២៧ សត.ប្រក.០១៦ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៦ ។

ហេតុនេះ សូមលោក ជ្រាប ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៦

**អគ្គព្រះរាជអាជ្ញា**

យើង.................................មុខងារ......................បាន

ប្រគល់លិខិតជូនដំណឹងនេះអោយឈ្មោះ ..............................

ទីលំនៅសព្វថ្ងៃនៅ...........................ឃុំ.សង្កាត់...................

ស្រុក.ខណ្ឌ...................................ខេត្ត.រាជធានី......................

នៅថ្ងៃទី...............ខែ.............ឆ្នាំ ២០១៦ រួចហើយ។

អ្នកទទួល អ្នកប្រគល់